ក្រសួងអប់រំ យុវជន និងកីឡា
Ministry of Education, Youth and Sports

វិទ្យាស្ថានជាតិអប់រំ
National Institute of Education

# និក្ខេបបទ

# ឧត្តមានុវត្តនៃការដឹកនាំនិងគ្រប់គ្រងរបស់នាយកសាលាវេស្ទើនអន្តរជាតិ "ករណីសិក្សា៖ សាលាវេស្ទើនអន្តរជាតិសាខា ស្ដេឌៀម"

# The best practices of school principal's leadership and management at Western international school "A case study of Western international school in Stadium Campus."

ដោយ/**By**

**ឌី ភារុន**

**DY PHEARUN**

**ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់**
**ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០**
**ឯកទេស ៖ គ្រប់គ្រងអប់រំ**

**ឆ្នាំសិក្សា ២០២១-២០២៣**

ក្រសួងអប់រំ យុវជន និងកីឡា
Ministry of Education, Youth and Sports

វិទ្យាស្ថានជាតិអប់រំ
National Institute of Education

# និក្ខេបបទ

# ឧត្តមានុវត្តនៃការដឹកនាំនិងគ្រប់គ្រងរបស់នាយកសាលាវេស្ទើនអន្តរជាតិ " ករណីសិក្សា៖ សាលាវេស្ទើនអន្តរជាតិសាខា ស្ដេឌៀម"

# The best practices of school principal’s leadership and management at Western international school “A case study of Western international school in Stadium Campus.”

ដោយ/**By**


**ឌី ភារុន**

DY PHEARUN


**ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់**
**ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០**
**ឯកទេស ៖ គ្រប់គ្រងអប់រំ**
**ឆ្នាំសិក្សា ២០២១-២០២៣**

**គ្រូណែនាំគោល ៖ បណ្ឌិត សៀង សុវណ្ណា**
**គ្រូណែនាំរង ៖ លោក ម៉ៅ សារឿន**

# សេចក្តីប្រកាសអះអាងរបស់បេក្ខជន

ខ្ញុំបាទ **ឌី ភារុន** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជំនាន់ទី១០ ឯកទេស**គ្រប់គ្រងអប់រំ** នៃវិទ្យាស្ថានជាតិអប់រំ។

សូមធ្វើការអះអាងថា ខ្លឹមសារក្នុងនិក្ខេបបទស្តីពី «**ឧត្តមានុវត្តនៃការដឹកនាំ និងគ្រប់គ្រងរបស់នាយកសាលារៀនអន្តរជាតិ (ករណីសិក្សា៖សាលារៀនអន្តរជាតិសាខា ស្តេឿម)**» គឺជាស្នាដៃស្រាវជ្រាវផ្ទាល់របស់ខ្ញុំពិតៗ ដោយមិនបានក្លែងបន្លំ ឬពាក់ព័ន្ធជាមួយនឹងនិក្ខេបបទ ឬស្នាដៃស្រាវជ្រាវរបស់អ្នកដទៃទេ ក្នុងការសរសេរបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ដើម្បីទទួលបានសញ្ញាបត្រនេះ។ ទិន្នន័យ និងលទ្ធផលនៃការសិក្សាស្រាវជ្រាវ ដែលបានលើកឡើងនៅក្នុងនិក្ខេបបទនេះ គឺជាទិន្នន័យ និងលទ្ធផលថ្មី ហើយមិនទាន់មានជនណាម្នាក់យកទៅប្រើប្រាស់ក្នុងនិក្ខេបបទរបស់គេឡើយ។

ខ្ញុំបាទ សូមសន្យាថា និក្ខេបបទនេះ មិនមានការក្លែងបន្លំ និងមិនមានការលួចចម្លងពីនិស្សិត ឬស្នាដៃអ្នកដទៃ។ ក្នុងករណីដែលវិទ្យាស្ថានជាតិអប់រំពិនិត្យឃើញថា មានករណីខាងលើកើតឡើងពិតប្រាកដមែន ខ្ញុំបាទសូមទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន។

ថ្ងៃសុក្រ ១១រោច ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២៣

**ហត្ថលេខា**

**ឌី ភារុន**

# លិខិតបញ្ជាក់

**ឈ្មោះ** **បណ្ឌិត** **សៀង សុវណ្ណា** ជាគ្រូណែនាំគោល

**ឈ្មោះ** **លោក** **ម៉ៅ សារឿន** ជាគ្រូណែនាំរង

## សូមបញ្ជាក់ និងទទួលស្គាល់ថា

លោក **ឌី នារុន** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០ នៃវិទ្យាស្ថានជាតិអប់រំ ពិតជាបានសរសេរនិក្ខេបបទស្រាវជ្រាវ «**ឧត្តមានុវត្តនៃការដឹកនាំ និងគ្រប់គ្រងរបស់នាយកសាលារៀនស្ទើនអន្តរជាតិ (ករណីសិក្សា៖សាលារៀនស្ទើនអន្តរជាតិសាខា ស្ពៅឡៀម)**» ប្រាកដមែន។

ថ្ងៃសុក្រ ១១រោច ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២៣

.................................................... ....................................................

**បណ្ឌិត សៀង សុវណ្ណា** **ម៉ៅ សារឿន**

គ្រូណែនាំគោល គ្រូណែនាំរង

# លិខិតឧទ្ទេសនាមគណកម្មការវាយតម្លៃការការពារនិក្ខេបបទ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

លេខ: [illegible] អយក.

(ការសម្ងាត់)

## លិខិតឧទ្ទេសនាម
## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

**យោង៖** - បទប្បញ្ញត្តិស្តីពីការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។

- ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០ ឆ្នាំសិក្សា ២០២២-២០២៣ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២។
- សំណើសុំដូរកាលបរិច្ឆេទរៀបចំការការពារនិក្ខេបបទស្រាវជ្រាវបញ្ចប់ការសិក្សារបស់និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០ ឆ្នាំសិក្សា២០២២-២០២៣ នៅវិទ្យាស្ថានជាតិអប់រំ។

ថ្នាក់ដឹកនាំ និងបុគ្គលិកអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការមេប្រយោគ** សម្រាប់ការការពារនិក្ខេបបទស្រាវជ្រាវបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី០៨-០៩ ខែធ្នូ ឆ្នាំ២០២៣ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | | |
|---|---|---|---|
| ១-ឯកឧត្តមបណ្ឌិតសភាចារ្យ | ហង់ជួន ណារ៉ុន | ក្រសួង អយក | ប្រធាន |
| ២-ឯកឧត្តម | អ៊ុង បូរាត | ក្រសួង អយក | អនុប្រធាន |
| ៣-ឯកឧត្តម | លាង សេងហាក់ | ក្រសួង អយក | សមាជិក |
| ៤-ឯកឧត្តមបណ្ឌិត | ឌី ខាំបូលី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៥. ឯកឧត្តមបណ្ឌិត | សៀង សុវណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៦-ឯកឧត្តមបណ្ឌិត | សិត សេង | វិទ្យាស្ថានគរ.ភ្នំពេញ | សមាជិក |
| ៧-លោកបណ្ឌិត | នូវ វីរ៉ា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៨-លោក | ឌី បុណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៩-លោកស្រី | ប៊ុន សុផានី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១០-លោក | ថៃ ហេង | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១១-លោកបណ្ឌិត | ឈូក ច័ន្ទធាយា | នាយកដ្ឋានបវ. | សមាជិក |
| ១២-លោកបណ្ឌិត | នី រដ្ឋា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៣-លោក | ម៉ន មុនិន្ទ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៤-លោកបណ្ឌិត | ឈាង សង្វាត | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៥-លោកបណ្ឌិត | ម៉ម ចាន់សៀន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ: www.moeys.gov.kh

ឯកឧត្តម លោក លោកស្រី ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារនិក្ខេបបទរបស់និស្សិតនៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២៣ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅ នៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃព្រហស្បតិ៍ ១៣រោច ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២៣

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**

- អគ្គនាយកដ្ឋានរ.ហិ អគ្គនាយកដ្ឋានឧស.
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី
- គ្រប់អង្គភាពក្រោមឱវាទអយកដែលមានការពាក់ព័ន្ធ "ដើម្បីជ្រាបជាព័ត៌មាន"
- សាមីខ្លួន " ដើម្បីអនុវត្ត "
- កាលប្បវត្តិ
- ឯកសារៈ វិទ្យាស្ថានជាតិអប់រំ

# គណៈកម្មការវាយតម្លៃការការពារនិក្ខេបបទស្រាវជ្រាវបញ្ចប់

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**លេខ** ៤៥០១ **អយក.**[illegible]

(**ការសម្ងាត់**)

**លិខិតឧទ្ទេសនាម**
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**យោង៖** - បទប្បញ្ញត្តិស្តីពីការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។
- ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០ ឆ្នាំសិក្សា២០២២-២០២៣ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២។
- សំណើសុំដូរកាលបរិច្ឆេទរៀបចំការការពារនិក្ខេបបទស្រាវជ្រាវបញ្ចប់ការសិក្សារបស់និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០ ឆ្នាំសិក្សា២០២២-២០២៣ នៅវិទ្យាស្ថានជាតិអប់រំ។

បុគ្គលិកអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការការពារនិក្ខេបបទស្រាវជ្រាវបញ្ចប់** ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី០៨-០៩ ខែធ្នូ ឆ្នាំ២០២៣ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | |
|---|---|---|
| ១. ឯកឧត្តមបណ្ឌិត ជ័យ សារិន | អគ្គាធិការដ្ឋាន | ប្រធាន |
| ២. លោកស្រីបណ្ឌិត បូ ច័ន្ទគុលិកា | នាយកដ្ឋានគោលនយោបាយ | អនុប្រធាន |
| ៣. លោកបណ្ឌិត កាន់ ពុទ្ធី | នា.បឋមសិក្សា អយក. | សមាជិក |
| ៤. លោក ម៉ៅ សារឿន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៥. លោកស្រី សាំង សុចិន្តា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៦. លោកបណ្ឌិត មាឃ ចាន់ថេង | នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ | សមាជិក |
| ៧. លោកបណ្ឌិត អែ សុងហ៊ាង | SEAMEO TED អយក | សមាជិក |
| ៨. ឯកឧត្តមបណ្ឌិត ប៊ិច សៀង | វិ.បច្ចេកវិទ្យាកំពង់ឈើទាល | សមាជិក |
| ៩.លោកបណ្ឌិត លី គឹមឡុង | សាកលវិទ្យាល័យភូមិន្ទភ្នំពេញ | សមាជិក |
| ១០.លោក ចាប រតនា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១១.លោក លឹម វ៉ាន់ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១២. លោកបណ្ឌិត អាន វ៉ូប្រាវ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៣. លោកស្រី នូ ចន្ទី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៤. លោកស្រី បណ្ឌិត ឡឹយ សុខគា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៥. លោកបណ្ឌិត អ៊ឹម គឿន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៦. លោកបណ្ឌិត ទី សុផល | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៧. លោកបណ្ឌិត គួយ សុគាន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៨. លោកបណ្ឌិត សោន វណ្ណៈ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៩. លោកបណ្ឌិត ឈន ថន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២០. លោកបណ្ឌិត សឿង សុផា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២១. លោក ចាន់ ធឿន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

| | | |
|---|---|---|
| ២២. លោកបណ្ឌិត សោកទ្រា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៣. លោក ឡុច ចាន់ថន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៤. លោក ចាន់ រ៉ាដា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

លោក និងលោកស្រី ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារនិក្ខេបបទរបស់និស្សិត នៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២៣ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅ នៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃព្រហស្បតិ៍ ៣រោច ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៣

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**

- អគ្គនាយកដ្ឋានរ.ហិ អគ្គនាយកដ្ឋានឧស.
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី
- គ្រប់អង្គភាពក្រោមឱវាទអយកដែលមានការពាក់ព័ន្ធ "ដើម្បីជ្រាបជាព័ត៌មាន"
- សាមីខ្លួន " ដើម្បីអនុវត្ត "
- កាលប្បវត្តិ
- ឯកសារ៖ វិទ្យាស្ថានជាតិអប់រំ

# សេចក្តីថ្លែងអំណរគុណ

ជាបឋម ខ្ញុំបាទ សូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុត ចំពោះលោកឪពុក **ភួ ម៉ៅ** អ្នកម្តាយ **គៀត ស៊ីណូន** ដែលបានផ្តល់កំណើត និងចិញ្ចឹមបីបាច់ថែរក្សា ទំនុកបម្រុងដល់រូបកូនឱ្យបានទទួលការសិក្សារហូតមានថ្ងៃនេះ។

ខ្ញុំបាទ សូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុត ចំពោះគណៈកម្មការគ្រប់គ្រងការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ នៃវិទ្យាស្ថានជាតិអប់រំ ព្រមទាំងសាស្ត្រាចារ្យទាំងអស់ ដែលបានខិតខំចំណាយពេលវេលាដ៏មមាញឹក និងមានតម្លៃបំផុត មកបង្ហាត់បង្រៀន និងពន្យល់គ្រប់មេរៀនដល់យើងខ្ញុំទាំងអស់គ្នា។ ជាពិសេស ខ្ញុំបាទ សូមគោរពថ្លែងអំណរគុណ ចំពោះឯកឧត្តមបណ្ឌិត **សៀង សុវណ្ណារ៉ា** គ្រូណែនាំគោល ដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការពិនិត្យវាយតម្លៃ ជួយណែនាំ និងផ្តល់យោបល់ដល់រូបខ្ញុំបាទក្នុងការសរសេរនិក្ខេបបទ ស្តីពី«**ឧត្តមានុវត្តនៃការដឹកនាំនិងគ្រប់គ្រងរបស់នាយកសាលារៀនស្ទើនអន្តរជាតិ (ករណីសិក្សាៈសាលារៀនស្ទើនអន្តរជាតិសាខាស្តេឡៀម)**»។ ខ្ញុំបាទ ក៏សូមថ្លែងអំណរគុណដល់លោក **ម៉ៅ សារឿន** គ្រូណែនាំរង ដែលតែងតែផ្តល់នូវកម្លាំងចិត្ត ចំណេះដឹង ចែករំលែកបទពិសោធន៍ ហើយធ្វើឱ្យរូបខ្ញុំទទួលបានជោគជ័យនាថ្ងៃនេះ។

ខ្ញុំបាទសូមថ្លែងអំណរគុណដល់គណៈគ្រប់គ្រងរបស់សាលារៀនស្ទើនអន្តរជាតិសាខា ស្តេឡៀម ដែលបានអនុញ្ញាត និងចូលរួមសហការធ្វើឱ្យការសិក្សាស្រាវជ្រាវនេះទទួលបានជោគជ័យ។

ជាទីបញ្ចប់ ខ្ញុំបាទសូមប្រសិទ្ធពរជ័យ ជូនចំពោះឯកឧត្តម លោក/លោកស្រីសាស្ត្រាចារ្យ លោកលោកស្រី នាងកញ្ញា និងមិត្តរួមជំនាន់ទាំងអស់ សូមទទួលបាននូវព្រះពុទ្ធពរទាំង៤ប្រការ គឺ **អាយុ វណ្ណៈ សុខៈ និងពលៈ** កុំបីឃ្លៀងឃ្លាតឡើយ។

# មូលន័យសង្ខេប

ការសិក្សានេះ មានគោលបំណងសិក្សាពីឧត្តមានុវត្តនៃការដឹកនាំ និងគ្រប់គ្រងរបស់នាយកសាលាវេស្ទើនអន្តរជាតិ សាខាស្ពេខៀមដោយប្រើប្រាស់ស្តង់ដាសាលាគំរូដើម្បីធ្វើការវាស់វែងពីរបៀបគ្រប់គ្រង និងបទពិសោធន៍គ្រប់គ្រងរបស់គណៈគ្រប់គ្រងសាលារៀន។ គោលបំណងនៃការស្រាវជ្រាវនេះគឺដើម្បីស្វែងយល់ពីៈ (១) ឧត្តមានុវត្តនៃការដឹកនាំ និងគ្រប់គ្រងបុគ្គលិករបស់នាយកសាលាវេស្ទើនអន្តរជាតិ (២) របៀបប្រើប្រាស់វិធីសាស្ត្រក្នុងការគ្រប់គ្រងគ្រូបង្រៀន និងទាក់ទាញអ្នកអាណាព្យាបាលឱ្យបញ្ជូនកូនមករៀននៅសាលាវេស្ទើនអន្តរជាតិ សាខាស្ពេខៀម។

ការសិក្សានេះ ប្រើប្រាស់វិធីសាស្ត្រស្រាវជ្រាវចម្រុះ (គុណវិស័យ និងបរិមាណវិស័យ) សម្រាប់ប្រមូល និងវិភាគទិន្នន័យ ហើយលទ្ធផលនៃការស្រាវជ្រាវបានបង្ហាញថា សាលាវេស្ទើនអន្តរជាតិសាខាស្ពេខៀមពិតជាសាលាដែលមានកេរ្តិ៍ឈ្មោះល្បីមានសិស្សច្រើនរហូតដល់២២១៣នាក់ក្នុងឆ្នាំសិក្សា ២០២២-២០២៣។ ការដឹកនាំរបស់នាយកគឺពោរពេញទៅដោយទេពកោសល្យក្នុងការដឹកនាំដែលអាចទទួលបានពិន្ទុសរុប២៤៤ពិន្ទុ។ តាមគោលការណ៍ សាលារៀនមួយចាត់ទុកថាបំពេញបាននូវស្តង់ដាអប្បបរមាកម្មវិធីសាលារៀនគំរូ លុះត្រាតែសាលានោះមានពិន្ទុសរុបយ៉ាងតិច២១៣ពិន្ទុ។ ដូច្នេះ គេអាចនិយាយបានថាសាលាវេស្ទើនអន្តរជាតិសាខាស្ពេខៀមគឺបានជាប់ជាស្តង់ដាសាលាគំរូ។ យ៉ាងណាមិញ បើស្តង់ដាណាមួយមិនមានពិន្ទុអប្បបរមា នោះមិនចាត់ទុកថា ជាសាលាជាប់ស្តង់ដាអប្បបរមាសាលារៀនគំរូឡើយ ហើយពិន្ទុសរុបនៅក្នុងស្តង់ដាទី៥របស់សាលាវេស្ទើនអន្តរជាតិសាខាស្ពេខៀមគឺទទួលបានត្រឹមតែ២២ពិន្ទុ ក្រោមពិន្ទុអប្បបរមាដែលបានកំណត់២ពិន្ទុ ដូចនេះសាលាវេស្ទើនអន្តរជាតិសាខាស្ពេខៀមមិនទាន់បំពេញបានគ្រប់លក្ខខណ្ឌដើម្បីជាប់ជាស្តង់ដាសាលាគំរូនៅឡើយទេ។

# Abstract

This study aims to focus on the best practices of school principal’s leadership and management at Western international school in Stadium Campus. Model School Standard will be applied to measure how to lead and manage the staffs and teachers in the campus effectively. Interestingly, two objectives of this research will show as following:

(1) the best practices of school principal’s leadership and management at Western international school in Stadium Campus.

(2) The strategies of leading teachers and staffs effectively and the ways to attract the guardians to send their kids to school.

The mixed methods (qualitative research and quantitative research) will be applied into this research and use to collect data and to analyze the result. Through this study, the result has shown that Western International school in Stadium Campus has a good brand name which has 2213 students in academic years 2022-2023. Also, the leadership from of school principal is very talented because he could get 244 scores from interview of Model Schools Standard. Base on the requirement of Model School Standard, the schools can become the standard one unless they get minimum 213 scores. So, we can say that Western International school can be a standard school. However, if one standard among the five standards didn’t get the minimum scores as requirement, those schools can’t pass the standard one. Western International school gets total score only 22 scores from standard number 5 while the minimum requirement is 24 scores. Therefor Western International school in Stadium Campus can’t fully become the standard school yet.

# មាតិកា

**សេចក្តីប្រកាសអះអាងរបស់បេក្ខជន** ...... i

**លិខិតបញ្ជាក់** ...... ii

**លិខិតឧទេសនាមគណកម្មការវាយតម្លៃការការពារនិក្ខេបបទ** ...... iii

**គណកម្មការវាយតម្លៃការការពារនិក្ខេបបទស្រាវជ្រាវបញ្ចប់** ...... v

**សេចក្តីថ្លែងអំណរគុណ** ...... vii

**មូលន័យសង្ខេប** ...... viii

Abstract ...... ix

**មាតិកា** ...... x

**ជំពូកទី១ សេចក្តីផ្តើម** ...... 1

១.១ លំនាំបញ្ហានៃការស្រាវជ្រាវ ...... 1

១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ ...... 3

១.៣ គោលបំណងនៃការស្រាវជ្រាវ ...... 4

១.៤ សំណួរនៃការស្រាវជ្រាវ ...... 4

១.៥ សារៈសំខាន់នៃការស្រាវជ្រាវ ...... 4

១.៦ វិសាលភាពនិងដែនកំណត់នៃការស្រាវជ្រាវ ...... 5

១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ...... 5

**ជំពូក២ រំលឹកទ្រឹស្តី** ...... 7

២.១ និយមន័យនៃពាក្យគន្លឹះ ...... 7

២.១.១ ឧត្តមានុវត្ត ...... 7

២.១.២ ការដឹកនាំ និងគ្រប់គ្រង ...... 7

២.២ នាយកសាលាសតវត្សរ៍ទី២១ ....... 7

២.២.១.ស្តង់ដាសមត្ថភាពនាយកសាលាគរុកោសល្យ ....... 8

២.៣ ស្តង់ដានាយកសាលារៀនកម្ពុជា ....... 9

២.៤.៦ ទម្រង់នៃកំណែទម្រង់សាលារៀន ....... 18

**ជំពូក៣ វិធីសាស្ត្រស្រាវជ្រាវ** ....... 36

៣ ១.ការជ្រើសរើសវិធីសាស្ត្រស្រាវជ្រាវ ....... 36

៣.២ វិធីសាស្ត្រជ្រើសរើសសំណាក ....... 36

៣.៤ វិធីសាស្ត្រប្រមូលទិន្នន័យ ....... 37

៣.៥ វិធីសាស្ត្រវិភាគទិន្នន័យ ....... 37

៣.៦ ក្រមសីលធម៌នៃការស្រាវជ្រាវ ....... 38

**ជំពូក៤_លទ្ធផល និងការពិភាក្សា** ....... 39

៤.១. ឧត្តមមានុវត្តនៃការដឹកនាំនិងគ្រប់គ្រងរបស់នាយកសាលាវេស្ទើនអន្តរជាតិសាខាស្ពៃឡៀម .... 39

៤.២ ការពិភាក្សាលើលទ្ធផលស្រាវជ្រាវ ....... 48

៤.២.១ ស្តង់ដាទី១ ....... 48

៤.២.២ ស្តង់ដាទី២ ....... 49

៤.២.៣ ស្តង់ដាទី៣ ....... 49

៤.២.៤ ស្តង់ដាទី៤ ....... 49

៤.២.៥ ស្តង់ដាទី៥ ....... 50

**ជំពូក៥ សេចក្តីសន្និដ្ឋាន និងសំណូមពរ** ....... 51

៥.១ សេចក្តីសន្និដ្ឋាន ....... 51

៥.២ សំណូមពរ ....... 52

**ឯកសារយោង** ....... 53

**ឧបសម្ព័ន្ធទី១ លិខិតបញ្ជាប់ការ** ....................................................................................55

**ឧបសម្ព័ន្ធទី២ លិខិតចាត់តាំងគ្រូដឹកនាំ** .......................................................................60

**ឧបសម្ព័ន្ធទី៣ លិខិតអនុញ្ញាតរបស់ក្រសួង** ...................................................................62

**ឧបសម្ព័ន្ធទី៤ កម្រងសំណួរ**......................................................................................63

# ជំពូក១

# សេចក្តីផ្តើម

# ជំពូកទី១
# សេចក្តីផ្តើម

ជំពូកនេះនឹងធ្វើការបកស្រាយអំពីសេចក្តីផ្តើមនៃការស្រាវជ្រាវ ពន្យល់បកស្រាយអំពីលំនាំបញ្ហានៃការស្រាវជ្រាវ ចំណោទបញ្ហានៃការស្រាវជ្រាវ គោលបំណងនៃការស្រាវជ្រាវ សំណួរស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ វិសាលភាពនិងដែនកំណត់នៃការស្រាវជ្រាវ និងរចនាសម្ព័ន្ធនៃការស្រាវជ្រាវ។

## ១.១ លំនាំបញ្ហានៃការស្រាវជ្រាវ

ប្រទេសមួយដែលរីកចម្រើនទៅបាន អាស្រ័យទៅលើធនធានមនុស្សនៅក្នុងប្រទេសនោះ។ វិស័យអប់រំបានដើរតួនាទីយ៉ាងសំខាន់សម្រាប់ផ្គត់ផ្គង់មនុស្សទៅក្នុងសង្គមទាំងមូល។ ភាពជាអ្នកដឹកនាំនៅគ្រឹះស្ថានអប់រំ មានភាពចាំបាច់ណាស់ក្នុងការសម្រេចបានទៅតាមផែនការប្រតិបត្តិប្រចាំឆ្នាំ និងបង្ហាញលទ្ធផលពីប្រសិទ្ធភាពរបស់អង្គភាព។ ក្រសួងទទួលបន្ទុកវិស័យអប់រំ បានកំណត់គោលនយោបាយអប់រំជាអាទិភាពចំនួនពីរ ក្នុងនោះអាទិភាពទី២គឺផ្តោតលើការលើកកម្ពស់គុណភាពនិងប្រសិទ្ធភាពនៃការដឹកនាំនិងគ្រប់គ្រងរបស់នាយកសាលា ក្នុងបរិបទកំណែទម្រង់អប់រំរបស់ប្រទេស កម្ពុជា (នា.គោលនោយបាយ,២០១៨)។ លើសពីនេះទៅទៀត ការខិតខំរបស់ប្រមុខរាជរដ្ឋាភិបាលលើវិស័យអប់រំ គឺមានគោលបំណងកសាងធនធានមនុស្សឱ្យក្លាយជាមនុស្សពេញលេញឬមូលធនមនុស្ស ដើម្បីអភិវឌ្ឍប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតទាបនាពេលបច្ចុប្បន្ន ទៅជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងទៅជាប្រទេសអភិវឌ្ឍន៍នៅឆ្នាំ ២០៥០។

នាយកសាលារៀនមានសារៈសំខាន់ណាស់ក្នុងការយល់ដឹងពីសមត្ថភាពរបស់ខ្លួនសម្រាប់បំពេញតួនាទីនិងភារកិច្ចឱ្យបានជោគជ័យ (SEAMEO INNOTECH, 2016)។ សមត្ថភាពរបស់នាយកសាលាសំដៅទៅលើបំណិន ចំណេះដឹង ឥរិយាបថ និងគុណតម្លៃ ដែលសម្តែងចេញតាមរយៈការបំពេញការងារនិងការប្រាស្រ័យទាក់ទងជាដើម។ នៅក្នុងការអភិវឌ្ឍក្របខ័ណ្ឌសមត្ថភាពនាយកសាលារៀននៅអាស៊ីអាគ្នេយ៍ ក្រុមការងារបានបង្កើតនូវប្រវត្តិការងារស្តីពីសមត្ថភាពជោគជ័យ ដែលជាកិច្ចការចាំបាច់សម្រាប់

នាយកសាលារៀនក្នុងការផ្ដល់នូវលទ្ធផលចំពោះគ្រូបង្រៀន សិស្សានុសិស្ស មាតាបិតា និងអ្នកពាក់ព័ន្ធផ្នែកអប់រំដទៃទៀត។

ចំពោះប្រទេសកម្ពុជាវិញ រាជរដ្ឋាភិបាលក៏បានកំណត់វិស័យអប់រំជាចំណុចអាទិភាពមួយក្នុងចំណោមវិស័យអាទិភាពជាច្រើន។ វិស័យនេះ ត្រូវបានបញ្ចូលទៅក្នុងមុំមួយនៃយុទ្ធសាស្ត្របញ្ចកោណរបស់រាជរដ្ឋាភិបាល (យុទ្ធសាស្ត្របញ្ចកោណរបស់រាជរដ្ឋាភិបាល២០២៣-២០២៨)។ ក្រសួងអប់រំ យុវជន និងកីឡា ជាសេនាធិការ របស់រាជរដ្ឋាភិបាលបាននឹងកំពុងខិតខំធ្វើកំណែទម្រង់មានលក្ខណៈស៊ីជម្រៅលើផ្នែកអប់រំទាំងតាមបែបវិមជ្ឈការ និងវិសហមជ្ឈការ ដើម្បីជំរុញឲ្យមានដំណើរការអនុវត្តការអប់រំនៅថ្នាក់ក្រោមជាតិ ដោយផ្ដល់ឱកាសឱ្យពួកគាត់ធ្វើផែនការ ធ្វើការគ្រប់គ្រង ធ្វើការអនុវត្ត និងធ្វើការពិនិត្យតាមដានជាដើម។ រាជរដ្ឋាភិបាលកម្ពុជា ចាប់តាំងពីឆ្នាំ២០១៤ រហូតមក តាមរយៈក្រសួងអប់រំ យុវជន និងកីឡាបានធ្វើការកែទម្រង់ចំណុចអាទិភាពក្នុងវិស័យអប់រំ យុវជន និងកីឡាចំនួន១៥ចំណុចរួមមានៈ ១.ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ២.ការពង្រាយគ្រូបង្រៀន ៣. ការកែទម្រង់មជ្ឈមណ្ឌលបណ្ដុះបណ្ដាលគ្រូបង្រៀន ៤. ការលើក កម្ពស់គុណវុឌ្ឍិគ្រូបង្រៀន ៥. ការងារអធិការកិច្ច ៦.ការវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស ៧. ការធ្វើកំណែទម្រង់ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ៨.ការធ្វើកំណែទម្រង់កម្មវិធីសិក្សានិងសៀវភៅសិក្សាគោល ៩. ការសាងសង់អគារសិក្សា និងការជួសជុល ១០.ការវាយតម្លៃគ្រឹះស្ថានឧត្តមសិក្សា ១១. ការលើកកម្ពស់វិស័យកីឡា ១២.ការអនុវត្តផែនការសកម្មភាពគោលនយោបាយយុវជន ១៣.ការអប់រំបច្ចេកទេស ១៤.ការបង្កើតសាលារៀនជំនាន់ថ្មី ១៥.ការរៀបចំគន្លងអាជីពនិងបណ្ដុះបណ្ដាលនាយកសាលា។ ចំណុចទាំងនេះ ត្រូវបានបង្កើតឡើងដើម្បីលើកកម្ពស់វិស័យអប់រំនៅ កម្ពុជា ក្នុងគោលបំណងផ្ដល់សេវាកម្មដល់កុមារ និងយុវជនឲ្យទទួលបានសមត្ថភាព បំណិន និងឥរិយាបថល្អ ក្នុងការបំពេញតម្រូវការរបស់ប្រទេសជាតិ។

សាលារៀនមួយដែលទទួលបានជោគជ័យ លុះត្រាតែសាលារៀននោះមានចក្ខុវិស័យ បេសកកម្ម គោលបំណង និងគោលដៅច្បាស់លាស់ ហើយនាយកសាលាគឺជាអ្នករៀបចំចាត់ចែងរឿងទាំងអស់នោះ។ ការអប់រំបានអភិវឌ្ឍបុគ្គលិក លក្ខណៈពេញលេញរបស់មនុស្ស ពង្រឹងការគោរពសិទ្ធិមនុស្ស និង

សេរីភាពជាមូលដ្ឋានរបស់មនុស្ស (UNESCO, 2011)នាយកសាលារៀនជាបុគ្គលមួយរូប ដែលត្រូវមានសមត្ថភាព និងផែនការច្បាស់លាស់ ក្នុងការបង្កើតនូវចំណុចអភិវឌ្ឍសាលារៀនឲ្យមានភាពរីកចម្រើន និងឆ្លើយតបទៅនឹងតម្រូវការចំណេះដឹងរបស់សិស្ស។ ការបង្កើតក្របខ័ណ្ឌសមត្ថភាពនាយកសាលានៅអាស៊ីអាគ្នេយ៍គឺក្នុងគោលបំណងលើកកម្ពស់វិស័យអប់រំឲ្យមានសន្ទុះទៅមុខឆ្លើយតបទៅនឹងតម្រូវការទីផ្សារ និងការធ្វើសមាហរណកម្មសេដ្ឋកិច្ច និងវប្បធម៌នៅក្នុងតំបន់។ ដូចនេះ វិស័យអប់រំជាផ្នែកមួយយ៉ាងសំខាន់ដែលរាជ រដ្ឋាភិបាលនៅតំបន់អាស៊ានបានយកចិត្តទុកដាក់ ហើយចាត់ទុកថាជាវិស័យស្នូល។ ប្រទេសកម្ពុជាកំពុងតែបណ្តុះភាពជាអ្នកដឹកនាំដល់នាយកសាលាក៏ដូចជាអ្នកសិក្សាទូទៅ។ សមត្ថភាពរបស់នាយកសាលា ជះឥទ្ធិពលដល់ឥរិយាបថបំពេញការងាររបស់គ្រូបង្រៀន ក៏ដូចជាភាពប្រសើរឡើងនៃលទ្ធផលសិក្សារបស់សិស្សានុសិស្ស។

ឧត្តមានុវត្តនៃការដឹកនាំនិងគ្រប់គ្រងបុគ្គលិករបស់នាយកសាលាវេស្ទើនអន្តរជាតិនៅសាខាស្តេឌៀមនឹងផ្តល់ជាសារប្រយោជន៍ដល់ការពង្រឹងគុណវុឌ្ឍិ សមត្ថភាព និងភាពជាអ្នកដឹកនាំរបស់នាយកសាលាក្នុងគ្រឹះស្ថានឯកជនលើក្របខ័ណ្ឌគោលនយោបាយអប់រំ និងការបញ្ជ្រាបការដឹកនាំដោយប្រើប្រាស់បច្ចេកវិទ្យាក្នុងសាលារៀនផងដែរ។

## ១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ

ឆ្លើយតបទៅនឹងការធានាគុណភាព ក្នុងបរិបទកំណែទម្រង់វិស័យអប់រំនៅកម្ពុជា ភាពជាអ្នកដឹកនាំនៅតាមគ្រឹះស្ថានសិក្សារដ្ឋនិងឯកជនបានឈានដល់កម្រិតប្រកួតប្រជែងយកស្នាដៃតាមរយៈការផ្តល់ពានរង្វាន់នាយកសាលាល្អ នាយកសាលាគំរូ និងនាយកសាលាឆ្នើម ដោយមានសូចនាករយ៉ាងត្រឹមត្រូវ ដើម្បីវាស់លើស្តង់ដានាយកសាលា សំដៅលើកកម្ពស់គុណភាពសិស្សានុសិស្ស បុគ្គលិកអប់រំ និងកម្រិតនៃការចូលរួមរបស់សហគមន៍ជាមួយសាលារៀនផងដែរ។ លើសពីនេះទៅទៀត នៅគ្រឹះស្ថានសិក្សាឯកជនការប្រកួតប្រជែងយកស្នាដៃ គឺវាយតម្លៃដោយឈរលើចំនួននៃការចុះឈ្មោះចូលរៀនរបស់សិស្ស និងប្រសិទ្ធផលទៅតាមវដ្តរបស់អាជីវកម្មនៃការអប់រំ។ ក្នុងន័យនេះ ឧត្តមានុវត្តនៃការដឹកនាំ និងគ្រប់គ្រងបុគ្គលិករបស់នាយកសាលាវេស្ទើនអន្តរជាតិនៅសាខាស្តេឌៀម នឹងត្រូវលើកយកមកធ្វើការសិក្សា

ស្រាវជ្រាវ ដើម្បីបង្ហាញពីលទ្ធផលលេចធ្លោរក្នុងការផ្តល់សេវាអប់រំដល់សហគមន៍ និងការពង្រឹងគុណភាពធនធានមនុស្សតាមរយៈការអប់រំលើវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា។

## ១.៣ គោលបំណងនៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះ មានគោលបំណងសិក្សាស្វែងយល់ពីចំណុចសំខាន់ៗមួយចំនួនដូចខាងក្រោម៖

១.៣.១. ស្វែងយល់ពីឧត្តមានុវត្តនៃការដឹកនាំ និងគ្រប់គ្រងបុគ្គលិករបស់នាយកសាលាវេស្ទើនអន្តរជាតិនៅសាខា ស្តេខៀម។

១.៣.២. រកឱ្យឃើញពីរបៀបប្រើប្រាស់វិធីសាស្ត្រក្នុងការគ្រប់គ្រងគ្រូបង្រៀន និងទាក់ទាញអ្នកអាណាព្យាបាលឱ្យបញ្ជូនកូនមករៀននៅសាលាវេស្ទើនអន្តរជាតិ សាខាស្តេខៀម។

## ១.៤ សំណួរនៃការស្រាវជ្រាវ

ដើម្បីឆ្លើយតបទៅនឹងគោលបំណងនៃការស្រាវជ្រាវខាងលើ សំណួរស្រាវជ្រាវចំនួនពីរ ត្រូវបានបង្កើតឡើងដូចខាងក្រោម៖

១. តើអ្វីទៅជាឧត្តមានុវត្តនៃការដឹកនាំ និងគ្រប់គ្រងបុគ្គលិករបស់នាយកសាលាវេស្ទើនអន្តរជាតិសាខាស្តេខៀម?

២. តើនាយកសាលាវេស្ទើនអន្តរជាតិសាខាស្តេខៀមប្រើវិធីសាស្ត្របែបណាខ្លះក្នុងការគ្រប់គ្រងគ្រូបង្រៀន និងទាក់ទាញអ្នកអាណាព្យាបាលឱ្យបញ្ជូនកូនមករៀន?

## ១.៥ សារៈសំខាន់នៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះ មានសារៈសំខាន់ណាស់ក្នុងការផ្តល់បទពិសោធន៍ល្អៗដល់គណៈគ្រប់គ្រងសាលារៀនទាំងក្នុងស្ថាប័នរដ្ឋនិងឯកជនដើម្បីផ្តល់សេវាអប់រំប្រកបដោយគុណភាពនិងភាពឆ្លើយតបហើយដើរស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការជំរុញកំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងនិរន្តរភាព ក៏ដូចជាឆ្លើយតបទៅនឹងគោលនយោបាយទី២របស់ក្រសួងអប់រំ យុវជន និងកីឡាពិសេសកម្មវិធីកំណែទម្រង់ទាំងបួនដំណាក់កាល។

## ១.៦ វិសាលភាពនិងដែនកំណត់នៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះ គឺស្វែងយល់តែពីឧត្តមានុវត្តនៃការដឹកនាំនិងគ្រប់គ្រង វិធីសាស្ត្រក្នុងការគ្រប់គ្រងគ្រូបង្រៀននិង ទាក់ទាញអ្នកអាណាព្យាបាលឱ្យបញ្ជូនកូនមកសាលារៀននៅសាលាវេស្ទើនអន្តរជាតិសាខាស្តេខៀមតែប៉ុណ្ណោះ។ ចំនួនសំណាកដែលបានប្រើប្រាស់ក្នុងការសិក្សាស្រាវជ្រាវនេះ ក៏ផ្តោតតែទៅលើនាយកសាលាវេស្ទើនអន្តរជាតិនៅសាខាស្តេ ខៀម ក្នុងរាជធានីភ្នំពេញ មិនគ្របដណ្តប់ដល់គ្រប់សាខា និងនៅទូទាំងប្រទេសនោះទេ ដោយសារតែកត្តាធនធាននិងពេលវេលានៅមានកម្រិត។ ដូច្នេះអ្នកស្រាវជ្រាវជំនាន់ក្រោយ សូមពង្រីកឱ្យដល់គ្រប់សាលារបស់វេស្ទើនទាំងអស់ ដើម្បីបង្កើតជាភាពទូទៅមួយសម្រាប់សាលាវេស្ទើនទាំងមូល។

## ១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ ត្រូវបានបែងចែកជា៥ជំពូក។ ជំពូក១ បង្ហាញពីសេចក្តីផ្តើម រួមមានលំនាំបញ្ហានៃការស្រាវជ្រាវ បញ្ហានៃការស្រាវជ្រាវ គោលបំណងនៃការស្រាវជ្រាវ សំណួរស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ ដែនកំណត់ និងរចនាសម្ព័ន្ធនៃការស្រាវជ្រាវ។ ជំពូក២ ពន្យល់បកស្រាយពីរំលឹកទ្រឹស្តីដោយការបង្ហាញពីនិយមន័យពាក្យគន្លឹះ និយាយពីទ្រឹស្តីជាច្រើនជុំវិញការដឹកនាំ ស្តង់ដានាយកសាលាកម្ពុជាទាំងចំណោះទូទៅ និងគ្រឹះស្ថានបណ្តុះបណ្តាលគ្រូ ស្តង់ដានាយកសាលាអាស៊ាន ស្តង់ដាសាលារៀនគំរូសម្រាប់វិទ្យាល័យធនធាន លក្ខណៈសម្បត្តិរបស់អ្នកដឹកនាំ និងទ្រឹស្តីឧត្តមភាពបុគ្គលផ្សេងៗទៀត។ ជំពូក៣ បង្ហាញពីវិធីសាស្ត្រស្រាវជ្រាវ រួមមានការជ្រើសរើសវិធីសាស្ត្រ ការជ្រើសរើសសំណាកប្រភពទិន្នន័យ វិធីប្រមូលទិន្នន័យ វិធីសាស្ត្រវិភាគទិន្នន័យ និងក្រមសីលធម៌នៃការស្រាវជ្រាវ។ ជំពូក៤ ពន្យល់បកស្រាយពីលទ្ធផលស្រាវជ្រាវ (ឧត្តមានុវត្តនៃការដឹកនាំនិងគ្រប់គ្រង វិធីសាស្ត្រក្នុងការគ្រប់គ្រងគ្រូបង្រៀន និងទាក់ទាញអ្នកអាណាព្យាបាលឱ្យបញ្ជូនកូនមកសាលារៀន របស់នាយកសាលាវេស្ទើនអន្តរជាតិនៅសាខាស្តេខៀម) និងការវិភាគលទ្ធផលស្រាវជ្រាវ (ឧត្តមានុវត្តនៃការដឹកនាំនិងគ្រប់គ្រង វិធីសាស្ត្រក្នុងការគ្រប់គ្រងគ្រូបង្រៀន និងទាក់ទាញអ្នកអាណាព្យាបាលឱ្យបញ្ជូនកូនមកសាលារៀន របស់នាយកសាលាវេស្ទើនអន្តរជាតិនៅសាខាស្តេខៀម)។ ជំពូកទី៥ នឹងបង្ហាញពីសេចក្តីសន្និដ្ឋាន និង

អនុសាសន៍អំពីឧត្តមានុវត្តនៃការដឹកនាំ និងគ្រប់គ្រងបុគ្គលិករបស់នាយកសាលាវេស្ទើនអន្តរជាតិនៅសាខាស្តេឌៀម)

# ជំពូក២
# រំលឹកទ្រឹស្តី

# ជំពូក២

# រំលឹកទ្រឹស្តី

ជំពូកនេះនឹងពន្យល់បកស្រាយពីនិយមន័យពាក្យគន្លឹះ និងចំណុចគន្លឹះមួយចំនួនដែលទាក់ទងទៅនឹងប្រធានបទស្រាវជ្រាវ។ ជំពូកនេះ ក៏នឹងបង្ហាញពីឧត្តមានុវត្តនៃការដឹកនាំនិងគ្រប់គ្រងបុគ្គលិករបស់នាយកសាលាវេស្ទើនអន្តរជាតិនៅសាខាស្តេងមានជ័យផងដែរ។

## ២.១ និយមន័យនៃពាក្យគន្លឹះ

ការសិក្សានេះ បានលើកឡើងពីនិយមន័យនៃពាក្យគន្លឹះចំនួនពីរ រួមមាន«ឧត្តមានុវត្ត»និង«ការដឹកនាំ និងគ្រប់គ្រង»។ ពាក្យគន្លឹះទាំងពីរនេះ ត្រូវបានបកស្រាយដូចខាងក្រោម៖

### ២.១.១ ឧត្តមានុវត្ត

គឺជាការអនុវត្តនិងជាបទពិសោធន៍ដ៏ប្រសើរកន្លងមក (វចនានុក្រមខ្មែរ,២០២២)។

### ២.១.២ ការដឹកនាំ និងគ្រប់គ្រង

គឺជាសមត្ថភាពក្នុងការបណ្តុះបណ្តាល និងជំរុញមន្ត្រីទាំងអស់ ឬបុគ្គលិកក្រោមឱវាទឱ្យមានការរីកចម្រើន ធ្វើតាមបែបច្នៃប្រឌិត មានឆន្ទៈក្នុងការគិតរកគំនិតប្លែកៗ និងហ៊ានប្រថុយ ដើម្បីនាំទៅរកភាពជោគជ័យក្នុងការងារ (ការងារគ្រប់គ្រង និងភាពជាអ្នកដឹកនាំ ពីនាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ,២០១៦)។ ការដឹកនាំ និងគ្រប់គ្រងជាការរៀបចំផែនការមួយប្រកបដោយការខិតខំប្រឹងប្រែងដែលជះឥទ្ធិពលលើសកម្មភាពក្រុមខ្លួន ក្នុងការកំណត់គោលដៅ និងសមិទ្ធផលជាគោលដៅ(Stogdill,1950)។ ការដឹកនាំនិងគ្រប់គ្រង គឺជាដំណើរសកម្មភាពមួយនៃការផ្តល់គោលបំណង (ទិសដៅ) ទៅនឹងកិច្ចខិតខំប្រឹងប្រែងរួមគ្នាដោយស្ម័គ្រចិត្តដើម្បីសម្រេចគោលបំណង (Jacobs & Jaques, 1990)។

## ២.២ នាយកសាលាសតវត្សរ៍ទី២១

នាយកសាលាមានតួនាទីសំខាន់ក្នុងការដឹកនាំវង្វាយតម្លៃ ដើម្បីសម្រេចបានការកែលម្អលទ្ធផលសិក្សារបស់សិស្ស ជាពិសេសក្នុងការអនុវត្តកំណែទម្រង់នៅកម្រិតសាលារៀន។ នាយកសាលា ជាតួអង្គ

មួយសំខាន់ក្នុងការអនុវត្តកំណែទម្រង់វង្វាយតម្លៃដែលផ្តោតលើការអនុវត្តវិធីសាស្ត្រសហការ និងការលើកកម្ពស់ការរិះរកក្នុងថ្នាក់រៀន។ ក្នុងន័យនេះ នាយកសាលាត្រូវអនុវត្តក្របខ័ណ្ឌវង្វាយតម្លៃដោយអនុលោមតាមបរិបទនៃសាលារៀននីមួយៗ។ នេះបើតាមការលើកឡើងរបស់ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ក្នុងបាឋកថាទិវាជាតិអំណាន ស្តីពីវង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្ស ក្នុងបរិបទនៃការអប់រំក្នុងសតវត្សរ៍ទី២១។ ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន បានមានប្រសាសន៍ថា នាយកសាលាមានតួនាទីយ៉ាងសំខាន់ក្នុងការអនុវត្តកំណែទម្រង់វិស័យអប់រំ កម្រិតសាលារៀន ជាពិសេសកំណត់ថា តើសិស្សខ្សោយអ្វី? សាលាមានបញ្ហាអ្វី? ហើយយកលទ្ធផលសិក្សារបស់សិស្សមកកែលម្អ ពិភាក្សាជាមួយមាតាបិតា ហើយមាតាបិតាក៏ត្រូវតែគាំទ្រដល់កូនរបស់ខ្លួនផងដែរ។ ជាពិសេស នៅក្នុងបរិបទលើកកម្ពស់បំណិនសតវត្សរ៍ទី២១នេះ គឺទាមទារឱ្យពិនិត្យឡើងវិញ តើគ្រូបង្រៀន នាយកសាលារៀន ត្រូវកែលម្អវិធីសាស្ត្របង្រៀនយ៉ាងដូចម្តេច?

## ២.២.១.ស្តង់ដាសមត្ថភាពនាយកសាលាគរុកោសល្យ

បើតាមសៀវភៅស្តង់ដាសមត្ថភាពនាយកសាលាគរុកោសល្យ របស់ក្រសួងអប់រំ យុវជន និងកីឡា បោះពុម្ពឆ្នាំ ២០១០បានចែងថានាយកសាលាដែលអាចចាត់ទុកថាមានសមត្ថភាពលុះត្រាតែមានលក្ខណៈសម្បត្តិទាំង៦ដូចខាងក្រោម៖

១. ភាពជាអ្នកដឹកនាំ៖ គណៈគ្រប់គ្រងសាលាគរុកោសល្យ ត្រូវជំរុញឱ្យមានទំនាក់ទំនងល្អជាមួយសហគមន៍ក្នុងការអភិវឌ្ឍ និងរក្សាការអនុវត្តចក្ខុវិស័យ តាមបែបគោលវិធីសិស្សមជ្ឈមណ្ឌល សម្រាប់ការបណ្តុះបណ្តាលដែលជាមូលដ្ឋានគ្រឹះនៃគោលបំណងសាលាគរុកោសល្យ ព្រមទាំងចេះដឹកនាំរៀបចំគ្រូបង្រៀនដែលនឹងចេញថ្មីប្រកបដោយប្រសិទ្ធភាព និងជាអ្នករៀនពេញមួយជីវិត។

២. ការងាររដ្ឋបាល៖ គណៈគ្រប់គ្រងសាលាគរុកោសល្យ ត្រូវលើកទឹកចិត្តដល់គរុសិស្សទាំងអស់ដែលបំពេញការងារប្រកប ដោយជោគជ័យ។ ការងារគ្រប់គ្រងត្រូវធានាបាននូវការចាត់ចែងរៀបចំកិច្ចការសហការគ្នា រក្សាសណ្តាប់ធ្នាប់ បរិយាកាសសិក្សារបស់គរុសិស្ស មានទំនាក់ទំនងល្អ ព្រមទាំងមានបរិស្ថានល្អក្នុងទីធ្លាសាលាគរុកោសល្យ។

៣. សកម្មភាពសិក្សា៖ គណៈគ្រប់គ្រង គ្រូឧទ្ទេស និងបុគ្គលិកអប់រំទាំងអស់មានភារកិច្ចស្រាវជ្រាវវិធីសាស្ត្រថ្មីៗដើម្បីឱ្យការអនុវត្តនៅក្នុងការបង្រៀន និងរៀនប្រកបដោយគុណភាព និងប្រសិទ្ធភាព។

៤. អភិវឌ្ឍវិជ្ជាជីវៈបុគ្គលិកអប់រំ៖ នាយកសាលាគរុកោសល្យត្រូវសហការយ៉ាងជិតស្និទ្ធជាមួយក្រុមបច្ចេកទេស គ្រូឧទ្ទេសនិងបុគ្គលិក ដើម្បីធ្វើផែនការ និងអនុវត្តសកម្មភាពនៃការអភិវឌ្ឍវិជ្ជាជីវៈ ដោយជំរុញឱ្យមានការរីកចម្រើនទាំងបុគ្គលិក លក្ខណៈ និងការរៀបចំការងារ ព្រមទាំងដឹកនាំ ដើម្បីកែលម្អការបង្រៀន និងរៀនឱ្យកាន់តែប្រសើរឡើង។

៥.សម្ភារបរិក្ខារ៖ គណៈគ្រប់គ្រងសាលាគរុកោសល្យត្រូវមានទំនាក់ទំនងល្អជាមួយសហគមន៍ជាតិអន្តរជាតិ ក្នុងការគ្រប់ គ្រង ប្រើប្រាស់សម្ភារបរិក្ខារ សេវាកម្មផ្សេងៗ ដំណើរការតាមដាន និងធ្វើឱ្យប្រសើរនូវសេវាកម្មសុខភាពរបស់ស្ថាប័ន។ ស្ថាប័នបណ្ដុះបណ្ដាលគ្រូជាស្ថាប័នគំរូក្នុងការបណ្ដុះបណ្ដាលដែលជះឥទ្ធិពលទៅលើឥរិយាបថរបស់គរុសិស្ស ក្នុងការផលិត និងការប្រើប្រាស់សម្ភារឧបទេស។

៦. សីលធម៌វិជ្ជាជីវៈ៖ នាយកសាលាគរុកោសល្យត្រូវមានគុណធម៌ ផ្ដល់ជាកម្លាំងចិត្តដល់បុគ្គលិកអប់រំទាំងអស់ដែលបានបំពេញភារកិច្ច ដើម្បីជាផលប្រយោជន៍នៅក្នុងសាលាគរុកោសល្យ និងត្រូវគិតទៅដល់ប្រតិឃាត នៃពាក្យសម្ដីរបស់ខ្លួនដែលជះឥទ្ធិពលទៅដល់បុគ្គលិក សហគមន៍ និងពលរដ្ឋទូទៅ។

## ២.៣ ស្តង់ដានាយកសាលារៀនកម្ពុជា

បើតាមសៀវភៅស្តង់ដានាយកសាលារៀនរបស់នាយកដ្ឋានបណ្ដុះបណ្ដាល និងវិក្រឹតការ បោះពុម្ពឆ្នាំ២០១៧៖

### ស្តង់ដាទី១៖ *កម្រិតវប្បធម៌ និងបទពិសោធន៍ការងារ*

នាយកសាលាជាអ្នកដឹកនាំសាលារៀនមួយដែលមានកម្រិតវប្បធម៌ទាបបំផុតក៏កម្រិតបរិញ្ញាបត្រ និងមានវិញ្ញាបនបត្រវិជ្ជាជីវៈនាយកសាលា ព្រមទាំងមានចំណេះដឹងមូលដ្ឋានទូលំទូលាយ យល់ដឹងផ្នែកបច្ចេកវិទ្យាព័ត៌មាន។ លើសពីនេះនាយកសាលាក៏ត្រូវយល់ដឹងផ្នែកភាសាបរទេសដែលអាចធ្វើការប្រាស្រ័យទាក់ទងគ្នាបាន។ ចំណុចមួយទៀតដែលនាយកសាលាត្រូវមានគឺបទពិសោធន៍ការងារជាគ្រូបង្រៀនយ៉ាងតិចចំនួន៥ឆ្នាំ។

**ស្តង់ដាទី២៖** ***សមត្ថភាព និងគុណសម្បត្តិរបស់នាយកសាលារៀន***

នាយកសាលាត្រូវមានសមត្ថភាពលើសបុគ្គលិកទាំងផ្នែកចំណេះដឹង ជំនាញ និងប្រសិទ្ធភាពក្នុងការគ្រប់គ្រង និងគ្រប់គ្រងការងារ។ នាយកសាលាត្រូវបង្ហាញគុណសម្បត្តិរបស់ខ្លួនធ្វើជាគម្រូដល់បុគ្គលិកដោយប្រកាន់គោលការណ៍តម្លាភាព គណនេយ្យភាព និងយុត្តិធម៌។ លើសពីនេះនាយកសាលារៀនត្រូវអភិវឌ្ឍសមត្ថភាពដឹកនាំ និងគ្រប់គ្រងជាប្រចាំដូចជាស្វ័យសិក្សា ការស្រាវជ្រាវ និងមានទស្សនវិស័យច្បាស់លាស់សម្រាប់អនាគត។ សូចនាករសំខាន់ៗរួមមាន៖

- **ក្រមសីលធម៌វិជ្ជាជីវៈ៖** នាយកសាលាត្រូវប្រកាន់ភ្ជាប់នូវមនសិការវិជ្ជាជីវៈរបស់ខ្លួនដោយពង្រឹងសាមគ្គីភាព គោរពវិន័យការងារ មានចិត្តស្មោះត្រង់ចំពោះអង្គភាព មានសីលធម៌ល្អ ប្រកបដោយគុណធម៌ យុត្តិធម៌ សុក្រិនិច្ឆ័យ មានហេតុផលច្បាស់លាស់។
- **ភាពជាអ្នកដឹកនាំ៖** នាយកសាលាត្រូវសិក្សាស្រាវជ្រាវ និងស្វែងយល់ពីរបបគំហើញថ្មីៗទាក់ទងនឹងការដឹកនាំ និងគ្រប់គ្រងសាលារៀន។ នាយកសាលាជានិច្ចជាកាលត្រូវផ្តល់ឱកាស កិត្តិយស និងតម្លៃដល់សហការី ហើយលើកទឹកចិត្តពួកគាត់ឱ្យព្យាយាមបំពេញការងារបានល្អប្រសើរ។ មិនត្រឹមតែប៉ុណ្ណោះ ត្រូវលើកទឹកចិត្តពួកគាត់ឱ្យព្យាយាមបំពេញការងារបានល្អប្រសើរ។ នាយកសាលាត្រូវតែមានបំណិនប្រសព្វក្នុងការដោះស្រាយបញ្ហាផ្សេងៗប្រកបដោយប្រសិទ្ធភាព និងមានការចូលរួមពីអ្នកពាក់ព័ន្ធដើម្បីកសាងសាលារៀនដែលខ្លួនគ្រប់គ្រងឱ្យបានល្អ។ ការសម្រេចចិត្តរបស់នាយកសាលាបានត្រឹមត្រូវទៅលើការដោះស្រាយការងារក៏ជាកត្តាមួយដ៏សំខាន់ដែលធ្វើឱ្យការដឹកនាំនិងគ្រប់គ្រងមានប្រសិទ្ធភាពផងដែរ។
- **ការប្តេជ្ញាចិត្ត ៖** ដើម្បីឱ្យអង្គភាពមួយមានការអភិវឌ្ឍនិងរីកចម្រើន ថ្នាក់ដឹកនាំត្រូវមានការតាំងចិត្តខ្ពស់។ នាយកសាលាត្រូវប្តេជ្ញាចិត្តយ៉ាងមោះមុតប្រកបដោយឆន្ទៈទទួលខុសត្រូវ ហ៊ាននិយាយ ហ៊ានធ្វើ ដើម្បីឱ្យអង្គភាពមានការរីកចម្រើន។ បន្ថែមលើសពីនេះទៅទៀត នាយកសាលាត្រូវមានឆន្ទៈក្នុងការធ្វើឱ្យសាលារៀនមានបរិស្ថានស្អាត មានសណ្តាប់ធ្នាប់ និងរបៀបរៀបរយល្អ។ ការដាំដើមឈើ និងការធ្វើសួនច្បារក៏ជាផ្នែកមួយដែលធ្វើឱ្យបរិស្ថានសាលារៀនស្អាត និងមានពណ៌បៃតងផងដែរ។

**ស្តង់ដាទី៣៖** ***បំណិនត្រិះរិះពិចារណា និងនវានុវត្តន៍***

នាយកសាលាត្រូវមានគំនិត បំណិនត្រិះរិះពិចារណា និងវិភាគលើស្ថានការណ៍នៃការងារដែលកើតមានឡើងឱ្យបានគ្រប់ជ្រុងជ្រោយដោយប្រមូលទិន្នន័យដាក់លាក់ក្នុងការដោះស្រាយ។ ខាងក្រោមនេះ ជាសូចនាករសំខាន់ៗដែលនាយកសាលាត្រូវមាន៖

• **ចក្ខុវិស័យ បេសកកម្ម គោលនយោបាយ និងផែនការយុទ្ធសាស្ត្រ៖** នាយកសាលាផ្សព្វផ្សាយពីគោលនយោបាយអប់រំជាតិ ផែនការយុទ្ធសាស្ត្រ លិខិតបទដ្ឋានគតិយុត្តនានាដូចជាសារាចរណ៍ សេចក្តីប្រកាស សេចក្តីជូនដំណឹង ព័ត៌មានរបស់ក្រសួងអប់រំ យុវជន និងកីឡា។ លើសពីនេះ នាយកសាលា ត្រូវស្វែងយល់ពីទិសដៅរបស់ក្រសួង និងរៀបចំផែនការអភិវឌ្ឍន៍សាលារៀនក្នុងរយៈពេល៥ឆ្នាំ ៣០ឆ្នាំ និងផែនការប្រតិបត្តិប្រចាំឆ្នាំជាដើម។ បន្ទាប់ពីបង្កើតផែនការរួចមក នាយកសាលាត្រូវផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធក្នុងគោលបំណងអនុវត្តផែនការឱ្យមានប្រសិទ្ធភាព។

• **ការអនុវត្តចក្ខុវិស័យ និងផែនការយុទ្ធសាស្ត្រ៖** ក្រោយពីរៀបចំផែនការយុទ្ធសាស្ត្រមក នាយកសាលាត្រូវបែងចែកការងារ ភារកិច្ច និងការទទួលខុសត្រូវដល់ក្រុមបច្ចេកទេស ដើម្បីយកទៅអនុវត្តឱ្យទទួលបានសម្រេចជោគជ័យ ដោយបែងចែកធនធានក្នុងអង្គភាព ដូចជាធនធានមនុស្ស ថវិកា និងសម្ភារៈជាដើម។

• **ការត្រួតពិនិត្យ និងវាយតម្លៃការងារ៖** នាយកសាលារៀនត្រូវពិនិត្យមើលការងារដែលបានអនុវត្តជាប្រចាំថាតើត្រឹមត្រូវតាមគោលការណ៍ដែលបានដាក់ចុះមក របស់ក្រសួងអប់រំ យុវជន និងកីឡាហើយឬនៅ និងចេះសហការគ្នាធ្វើស្វ័យវាយតម្លៃ និងធ្វើការកែលម្អជាញឹកញាប់ នូវចំណុចខ្វះខាត ឱ្យទៅជាចំណុចល្អឡើងវិញ។ ក្រៅពីនេះ នាយកសាលាត្រូវពិនិត្យតាមដាន ប្រមូល វិភាគទិន្នន័យ និងព័ត៌មាននានាដែលទាក់ទងទៅនឹងការដឹកនាំ និងគ្រប់គ្រងសាលារៀនឱ្យមានប្រសិទ្ធភាពខ្ពស់។ ពេលមានបញ្ហាផ្សេងៗកើតឡើងនៅក្នុងសាលារៀន នាយកសាលាត្រូវដោះស្រាយឱ្យបានទាន់ពេលវេលា និងទាន់ភាពចាំបាច់របស់អ្នកពាក់ព័ន្ធ។

**ស្តង់ដាទី៤៖** ***ភាពជាអ្នកដឹកនាំគ្រប់គ្រងរដ្ឋបាលសាលារៀន***

ការគ្រប់គ្រងរដ្ឋបាលជាភារកិច្ចមួយយ៉ាងសំខាន់របស់ថ្នាក់ដឹកនាំសាលារៀនក្នុងការធ្វើឱ្យប្រសើរឡើងដល់ការរៀន និងបង្រៀន ប្រកបដោយគុណភាព និងប្រសិទ្ធភាព។ ការគ្រប់គ្រងរដ្ឋបាលរបស់

នាយកសាលាសំដៅឱ្យមានការអភិវឌ្ឍគ្រប់ផ្នែកដូចជា បរិស្ថាន ការគ្រប់គ្រងបុគ្គលិក ការគ្រប់គ្រងហិរញ្ញវត្ថុ និយតភាពការងារ និងត្រួតពិនិត្យវាយតម្លៃលើសេវា ការគ្រប់គ្រងទិន្នន័យស្ថិតិបុគ្គលិក ថ្នាក់រៀន សិស្ស ការរៀបចំផែនការសកម្មភាព និងថវិកា។ ខាងក្រោមនេះជាសូចនាករសំខាន់ៗ៖

• **ការគ្រប់គ្រងរដ្ឋបាល៖** ការងាររដ្ឋបាលសាលារៀន ជាការងារសំខាន់មួយដែលនាយកសាលាត្រូវផ្តោតការយកចិត្តទុក ដាក់។ នាយកសាលាត្រូវពិនិត្យមើលលើទំនាក់ទំនងរវាងគ្រូបង្រៀន និងថ្នាក់ដឹកនាំសាលារៀន ថាតើមានលក្ខណៈជិតស្និទ្ធកម្រិតណា ការបំពេញការងាររបស់គ្រូបង្រៀនបានល្អប៉ុណ្ណា ការងារដែលត្រូវរៀបចំទុកដាក់ដូចជាលិខិតស្នាមនានា និងឯកសារគណនេយ្យស្របតាមគោលការណ៍ណែនាំហើយឬនៅ។ នាយកសាលាត្រូវស្វែងយល់និងរៀបចំជាគណៈកម្មការ ក្រុមប្រឹក្សានានាក្នុងសាលារៀន ប្រព័ន្ធគ្រប់គ្រងទ្រព្យសម្បត្តិរបស់សាលារៀនជាដើម។ ចំណុចមួយទៀតគឺការដឹកនាំសិស្សជួយការងារសង្គម និងសហគមន៍ រួមមានការងារបរិស្ថាន អនាម័យ ចរាចរណ៍ ប្រយុទ្ធប្រឆាំងគ្រឿងញៀន កសិកម្ម បុណ្យជាតិ និងអន្តរជាតិ ការងារកាកបាទក្រហម ការងារយុវជន និងកាយរឹទ្ធិជាដើម។

• **ការគ្រប់គ្រងបុគ្គលិក៖** ក្រៅពីកិច្ចការរដ្ឋបាល នាយកសាលាត្រូវគិតគូរពីសុខទុក្ខរបស់គ្រូបង្រៀននិងបុគ្គលិកសាលាដោយស្វែងយល់ពីជីវភាពរស់នៅ និងព័ត៌មាននានាដែលទាក់ទងនឹងការបង្រៀនរបស់គ្រូម្នាក់ៗដូចជាប្រវត្តិ ទីកន្លែងស្នាក់នៅ ចំណង់ចំណូលចិត្ត និងមធ្យោបាយទំនាក់ទំនង។ ការយល់ដឹងពីបញ្ហាទាំងនេះអាចជួយដល់នាយកសាលាក្នុងការគ្រប់គ្រងបុគ្គលិក ការលើកទឹកចិត្តរបស់នាយកសាលាចំពោះគ្រូដែលមានស្នាដៃល្អដោយស្នើដំឡើងថ្នាក់ ឋានន្តរស័ក្តិ ផ្តល់ជាប័ណ្ណសរសើរជាចំណុចមួយដែលនាយកសាលាត្រូវយល់ដឹង ព្រមទាំងលើកទឹកចិត្ត និងបង្ករលក្ខណៈងាយស្រួលដល់គ្រូបង្រៀនទាំងអស់ក្នុងសាលាឱ្យទទួលបានការសិក្សាបន្ថែម ការងារមួយទៀតដែលនាយកត្រូវយកចិត្តទុកដាក់គឺការវាយតម្លៃលើការបំពេញភារកិច្ចរបស់គ្រូបង្រៀនប្រកបដោយតម្លាភាព និងយុត្តិធម៌។

• **ការគ្រប់គ្រងហិរញ្ញវត្ថុ៖** ការងារហិរញ្ញវត្ថុក៏ជាការងារមួយដែលមានលក្ខណៈសំខាន់សម្រាប់នាយកសាលា។ នាយកសាលាត្រូវប្រមូលទិន្នន័យទាក់ទងនឹងហិរញ្ញវត្ថុឲ្យមានលក្ខណៈច្បាស់លាស់មានតម្លាភាព គណនេយ្យភាព ដោយការរៀបចំប្រព័ន្ធគ្រប់គ្រងគណនេយ្យដែលអាចជឿជាក់បាន។

## ស្តង់ដាទី៥៖ *ភាពជាអ្នកដឹកនាំលើកម្មវិធីសិក្សា និងការបង្រៀននិងរៀន*

កម្មវិធីសិក្សាជាផ្នែកមួយដ៏សំខាន់សម្រាប់ការបង្រៀននិងរៀន។ នាយកសាលាចាំបាច់ត្រូវដឹកនាំអនុវត្ត និងកែលម្អកម្មវិធីសិក្សា បង្កើតបរិស្ថាន និងបរិយាកាសសិក្សា ធ្វើអធិការកិច្ច វាយតម្លៃការបំពេញការងាររបស់គ្រូបង្រៀន និងតាមដានលទ្ធផលសិក្សា។ ខាងក្រោមនេះជាសូចនាករសំខាន់ៗសម្រាប់នាយកសាលាអនុវត្ត៖

- **ការគ្រប់គ្រងការរៀននិងបង្រៀន៖** នាយកសាលាត្រូវស្វែងរកសម្ភារៈ និងធនធានសិក្សា សម្រាប់ដំណើរការរៀននិងបង្រៀនដោយលើកទឹកចិត្តគ្រូ ប្រើចិត្តគរុកោសល្យច្បាស់លាស់ ក្នុងការសម្របសម្រួលឱ្យសិស្សយល់ដឹង និងចេះពីរបៀបរៀន។ ចំណុចមួយទៀតនោះ គឺនាយកសាលាត្រូវជំរុញឱ្យគ្រូបង្រៀនធ្វើផែនការបង្រៀន និងខិតខំអនុវត្តផែនការនោះឱ្យបានត្រឹមត្រូវជាប្រចាំ ហើយតាមដាន ឬចុះអធិការកិច្ចតាមផែនការកំណត់ ព្រមទាំងផ្តល់ព័ត៌មានត្រឡប់ប្រកបដោយការលើកទឹកចិត្តនូវចំណុចវិជ្ជមាន និងចំណុចអវិជ្ជមាន។ លើសពីនេះទៅទៀត នាយកសាលាត្រូវពិនិត្យតាមដានការបង្រៀនរបស់គ្រូ ពិនិត្យមើលបំណែងចែកកម្មវិធីសិក្សាថាតើអាចទាន់ ឬចប់នៅចុងឆ្នាំសិក្សាដែរ ឬទេ។
- **ការស្រាវជ្រាវ៖** នាយកសាលាត្រូវកំណត់ពេលឱ្យបានច្បាស់លាស់សម្រាប់ក្រុមបច្ចេកទេសដើម្បីធ្វើការប្រជុំរកវិធីសាស្ត្រថ្មីសម្រាប់យកទៅបង្រៀន ហើយជំរុញឱ្យគ្រូស្រាវជ្រាវឯកសារដែលទាក់ទងនឹងមេរៀនដើម្បីឱ្យការបង្រៀន និងរៀនកាន់តែមានប្រសិទ្ធភាព។
- **ការសហការ និងទំនាក់ទំនង៖** នាយកសាលាត្រូវមានកម្មវិធីសម្រាប់ធ្វើការប្រជុំជាមួយបុគ្គលិក និងសហគមន៍ក្នុងការត្រួតពិនិត្យ កែលម្អ អភិវឌ្ឍ និងអនុវត្តកម្មវិធីសិក្សា ព្រមទាំងផ្សព្វផ្សាយលទ្ធផលនៃការវាយតម្លៃជាផ្លូវការដល់ភាគីដែលពាក់ព័ន្ធ។ លើសពីនេះទាំងនាយកសាលា គ្រូបង្រៀន និងអ្នកពាក់ព័ន្ធត្រូវចេះសហការ សាមគ្គី និងគោរពគ្នាទៅវិញទៅមក។
- **ការអភិវឌ្ឍសមត្ថភាព៖** នាយកសាលាគួររកឱកាសអភិវឌ្ឍសមត្ថភាពរបស់ខ្លួនឱ្យបានរីកចម្រើន ហើយនាយកសាលាក៏ត្រូវលើកទឹកចិត្តដល់គ្រូបង្រៀនបង្កើនចំណេះដឹងវិជ្ជាជីវៈយកទៅបំពេញការងារឱ្យបាន

ល្អូន។ នាយកសាលាត្រូវរៀបចំ ចាត់ចែង និងសម្របសម្រួលឱ្យមានសកម្មភាពចែករំលែកចំណេះដឹង និងបទពិសោធន៍ដល់គ្នាទៅវិញទៅមក។

• **ការធ្វើអធិការកិច្ចផ្ទៃក្នុង៖** នាយកសាលាពិនិត្យតាមដាន និងវាយតម្លៃសកម្មភាពគ្រូបង្រៀនដើម្បីកែលម្អលទ្ធផលសិក្សារបស់សិស្ស និងរិះរកវិធីសាស្ត្រថ្មីៗសម្រាប់ជាជំនួយដល់ការបង្រៀនរបស់គ្រូ។ ការអនុវត្តបែបនេះអាចធ្វើឱ្យការបំពេញការងាររបស់គ្រូទទួលបានលទ្ធផលវិជ្ជមានច្រើន។

**ស្តង់ដាទី៦៖** *ការផ្សារភ្ជាប់សាលារៀន នឹងសហគមន៍*

សហគមន៍មានតួនាទីសំខាន់ក្នុងដំណើរការសាលារៀន ហើយទំនាក់ទំនងល្អរវាងសាលារៀន និងសហគមន៍ជាកត្តាដែលមិនអាចខ្វះបាន។ កាលណាសហគមន៍មានសកម្មភាពចូលរួមច្រើនជាមួយសាលារៀន នឹងធ្វើឱ្យសាលារៀនមានសកម្មភាពផុលផុស និងរីកចម្រើនខ្លាំង។ ចំណុចខាងក្រោមជាសូចនាករសំខាន់ៗ៖

• **អជ្ញាធរដែនដី៖** នាយកសាលាត្រូវមានទំនាក់ទំនងជិតស្និតជាមួយអជ្ញាធរដែនដីដូចជាមេឃុំ ចៅសង្កាត់ មេភូមិ នគរបាល និងកងរាជអាវុធហត្ថជាដើម។ នៅពេលសាលាមានបញ្ហា ឬចង់ពឹងពាក់លើចំណុចណាមួយ អជ្ញាធរអាចជួយដោះស្រាយបាន។

• **មាតាបិតា៖** សាលារៀនត្រូវមានទំនាក់ទំនងល្អជាមួយមាតាបិតាសិស្សក្នុងការផ្តល់ និងទទួលព័ត៌មានពីគ្នាទៅវិញទៅមក ហើយលើកឡើងពីអត្ថប្រយោជន៍នៃការសិក្សាដល់អាណាព្យាបាល និងលើកទឹកចិត្តដល់ពួកគាត់ ឱ្យបញ្ជូនកូនៗមកសាលារៀន។

• **ភាគីពាក់ព័ន្ធ៖** សាលារៀនត្រូវបង្ករលក្ខណៈងាយស្រួលដល់អ្នកពាក់ព័ន្ធ ដោយផ្តល់ការគាំទ្រ ឱកាសឱ្យចូលរួមសកម្មភាពនានា ហើយទទួលយកនូវគំនិត ឬយោបល់រិះគន់ដើម្បីស្ថាបនាពីសហគមន៍ និងអ្នកពាក់ព័ន្ធ។

## ២.៤ ក្របខណ្ឌសមត្ថភាពនាយកសាលារៀននៅអាស៊ីអាគ្នេយ៍

នៅឆ្នាំ២០១៣ មជ្ឈមណ្ឌល SEAMEO INNOTECH បានអភិវឌ្ឍក្របខ័ណ្ឌសមត្ថភាពនាយកសាលារៀន នៅអាស៊ីអាគ្នេយ៍។ ក្របខ័ណ្ឌសមត្ថភាពនេះមានចក្ខុវិស័យ ដើម្បីផ្តល់មូលដ្ឋានគ្រឹះ សម្រាប់

កំណត់កម្រិតជំនាញ និងបុគ្គលិកលក្ខណៈដល់នាយកសាលារៀន អនុវត្តតួនាទីឱ្យមានប្រសិទ្ធភាពដឹកនាំសាលារៀនឱ្យបានជោគជ័យ និងមានឧត្តមភាព។ក្របខ័ណ្ឌនេះមានសមត្ថភាពគោលចំនួន៥ដូចខាងក្រោម៖

**២.៤.១ គំនិតយុទ្ធសាស្ត្រ និងនវានុវត្តន៍៖** ជាសមត្ថភាព នៃការរៀបចំទិសដៅយុទ្ធសាស្ត្រសម្រាប់សាលារៀន ក្នុងការសម្រេចចិត្ត នាំឱ្យមានការផ្លាស់ប្តូរនិងនវានុវត្តន៍។ សូចនាករសំខាន់ៗដើម្បីវាស់វែងផលសម្រេចបាននៃសមត្ថភាពគោលមួយនេះរួមមាន៖

**ក. ការធ្វើគោលទិសដៅយុទ្ធសាស្ត្រសាលារៀន**

- ធ្វើការងារជាមួយសាលារៀន សហគមន៍និងភាគីពាក់ព័ន្ធក្នុងការបង្កើតផែនការយុទ្ធសាស្ត្រសាលារៀន
- ដឹកនាំអនុវត្តផែនការយុទ្ធសាស្ត្រ
- បង្ហាញពីចក្ខុវិស័យ និងធ្វើជាគម្រូឱ្យឃើញពីគុណតម្លៃនៃការអនុវត្តការងារប្រចាំថ្ងៃ

**ខ. ការសម្រេចចិត្តដោយមានការចូលរួម**

- ប្រើភស្តុតាងផ្សេងគ្នា ដើម្បីគាំទ្រ ត្រួតពិនិត្យ តាមដាន និងវាយតម្លៃកែលម្អផែនការយុទ្ធសាស្ត្រសាលារៀន
- ប្រតិបត្តិការពិនិត្យឡើងវិញឱ្យបានទៀងទាត់នៃការអនុវត្តផែនការកម្មវិធីនិងប្រើប្រាស់លទ្ធផលដើម្បីដោះស្រាយបញ្ហានៅពេលអនុវត្ត

**គ. ការដឹកនាំដោយមានការផ្លាស់ប្តូរ និងនវានុវត្តន៍**

- ដឹកនាំដំណើរការផ្លាស់ប្តូរទិសដៅលើការអភិវឌ្ឍ និងអនុវត្តគោលវិធី ប្រព័ន្ធ និងរចនាសម្ព័ន្ធថ្មីៗ
- ធ្វើឱ្យនិរន្តរភាពច្នៃប្រឌិតនិងនវានុវត្តន៍នៅក្នុងកម្មវិធីសាលាដើម្បីសម្រេចបាននូវលទ្ធផលសិក្សាខ្ពស់

**២.៤.២ ភាពជាអ្នកដឹកនាំនិងគ្រប់គ្រង៖** ជាសមត្ថភាពនៃការគ្រប់គ្រងធនធាន និងប្រព័ន្ធសាលារៀន ការគ្រប់គ្រងការបំពេញការងាររបស់បុគ្គលិក ការគ្រប់គ្រងកម្មវិធីរបស់បុគ្គលិក ការគ្រប់គ្រង

កម្មវិធីនិងគម្រោងនានារបស់សាលារៀនប្រកបដោយនិរន្តភាព។ សូចនាករសំខាន់ៗ ដើម្បីវាស់វែងផលសម្រេចបាននៃសមត្ថភាពគោលមួយនេះរួមមាន៖

**ក.ការគ្រប់គ្រងប្រព័ន្ធ និងធនធានសាលារៀន**

- គ្រប់គ្រងធនធានហិរញ្ញវត្ថុ
- គ្រប់គ្រងបរិស្ថានសិក្សា
- គ្រប់គ្រងប្រព័ន្ធ និងនិតិវិធី

**ខ. ការគ្រប់គ្រងការបំពេញការងាររបស់បុគ្គលិក**

- គ្រប់គ្រងលក្ខខណ្ឌតម្រូវការបុគ្គលិករបស់សាលារៀន
- គាំទ្រការអភិវឌ្ឍសមត្ថភាពបុគ្គលិក
- ទទួលស្គាល់ការបំពេញការងាររបស់បុគ្គលិក

**គ. ការគ្រប់គ្រងគម្រោង និងកម្មវិធីសាលារៀនឱ្យមាននិរន្តរភាព**

- បង្ហាញបំណិនគ្រប់គ្រងគម្រោង និងកម្មវិធី
- លើកកម្ពស់គម្រោងនិងកម្មវិធីដោយផ្ដោតលើសាលារៀននិងគាំទ្រការអភិវឌ្ឍប្រកបដោយនិរន្តរភាព

**២.៤.៣ ភាពជាអ្នកដឹកនាំលើការបង្រៀន និងរៀន**៖ជាសមត្ថភាពដឹកនាំក្នុងការអនុវត្តនិងកែលម្អកម្មវិធីសិក្សា បង្កើតបរិស្ថានសិក្សាតាមបែបសិស្សមជ្ឈមណ្ឌល ការធ្វើអធិការកិច្ចនិងវាយតម្លៃលើការបំពេញភារកិច្ចរបស់គ្រូបង្រៀនក៏ដូចជាផ្ដល់លទ្ធផលអំពីផែនការសិក្សា។ សូចនាករសំខាន់ៗ ដើម្បីវាស់វែងផលសម្រេចបាននៃសមត្ថភាពគោលមួយនេះរួមមាន៖

**ក.ការដឹកនាំកែលម្អ និងការអភិវឌ្ឍកម្មវិធីសិក្សា**

- គ្រប់គ្រងការអនុវត្តកម្មវិធីសិក្សា
- លើកកម្ពស់ការយល់ដឹងសំដៅដល់ការបង្រៀនចម្រុះ និងផ្សេងៗគ្នា

**ខ. ការបង្កើតបរិស្ថានសិស្សមជ្ឈមណ្ឌល**

- លើកកម្ពស់សកម្មភាពសិស្សមជ្ឈមណ្ឌល
- លើកកម្ពស់បរិស្ថានសិក្សាប្រកបដោយផាសុខភាព សុវត្ថិភាព និងការអប់រំបញ្ចូលគ្នា
- លើកកម្ពស់វប្បធម៌សន្តិភាពជាតិសាសន៍ផ្សេងៗគ្នា

**គ. ការធ្វើអធិការកិច្ច និងវាយតម្លៃការបំពេញភាកិច្ចរបស់គ្រូ**

- អនុវត្តគម្រូសមស្របចំពោះការគ្រប់គ្រង និងវាយតម្លៃ
- ការអប់រំគណៈគ្រប់គ្រងសាលារៀន

**ឃ. ការបង្ហាញនូវលទ្ធផលសិក្សាតាមផែនការ**

- លើកកម្ពស់គោលវិធី ផ្អែកលើស្មារតីជាក្រុម សម្រាប់ការដឹកនាំការបង្រៀន និងរៀន
- គ្រប់គ្រងការវាយតម្លៃការរៀន និងបង្រៀនឲ្យប្រសើរឡើង

**២.៤.៤ ឧត្តមភាពបុគ្គល៖** ជាសមត្ថភាពគ្រប់គ្រងលើប្រសិទ្ធភាពបុគ្គលទៅលើសកម្មភាពឱ្យអស់ពីសមត្ថភាព និងលទ្ធភាពដែលអាចធ្វើទៅបាននិងបន្តការអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈជាដើម។ សូចនាករសំខាន់ៗ ដើម្បីវាស់វែងផលសម្រេចបាននៃសមត្ថភាពគោលមួយនេះរួមមាន៖

**ក. គ្រប់គ្រងប្រសិទ្ធភាពបុគ្គល**

- ដឹកនាំដោយធ្វើជាគម្រូ
- បង្ហាញនូវតម្លាភាព និងគណនេយ្យភាព
- អនុវត្តការរស់នៅប្រកបដោយសុខភាពនិងតុល្យភាពមានមោទនភាពវិជ្ជាជីវៈរបស់បុគ្គលម្នាក់ៗ
- ផ្សព្វផ្សាយលទ្ធផល

**ខ. ធ្វើសកម្មភាពលើបញ្ហាប្រឈម និងលទ្ធភាពដោះស្រាយនានា**

- គ្រប់គ្រងអាទិភាព
- បង្ហាញនូវការសម្រេចចិត្តក្នុងការកំណត់នូវបញ្ហាប្រឈម
- បង្ហាញនូវឥរិយាបថជាសហគ្រិនភាព

**គ. បន្តអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈ**

- ទំនួលខុសត្រូវក្នុងការសិក្សាពេញមួយជីវិត
- គាំទ្រទស្សនវិស័យ និងតម្លៃរបស់ ASEA

**២.៤.៥ ការចូលរួមពីភាគីពាក់ព័ន្ធ៖** ជាសមត្ថភាពក្នុងការលើកកម្ពស់ ការចែករំលែក ការទទួលខុសត្រូវ សម្រាប់ការអភិវឌ្ឍសាលារៀន គ្រប់គ្រងភាពជាដៃគូ និងបណ្តាញការអប់រំ និងការរក្សានិរន្តរភាពនៃទំនាក់ទំនងកិច្ចសហប្រតិបត្តិការជាមួយភាគីពាក់ព័ន្ធ។ សូចនាករសំខាន់ៗ ដើម្បីវាស់វែងផលសម្រេចបាននៃសមត្ថភាពគោលមួយនេះរួមមាន៖

**ក. លើកកម្ពស់ការទទួលខុសត្រូវ និងចែករំលែកសម្រាប់ការកែលម្អសាលារៀន**

- កសាងទំនុកចិត្ត និងដឹកនាំក្រុម
- ពង្រឹងអំណាចសហគមន៍ក្នុងការធ្វើការងារដើម្បីលើកកម្ពស់សាលារៀន

**ខ. គ្រប់គ្រងកិច្ចសហប្រតិបត្តិការ និងបណ្តាញអប់រំ**

- ទំនាក់ទំនងជាមួយភាគីពាក់ព័ន្ធផ្សេងៗឱ្យមានប្រសិទ្ធភាពខ្ពស់
- សម្របសម្រួលភាពជាដៃគូជាមួយសហគមន៍
- លើកកម្ពស់ឱ្យមានការចូលរួមមតិពីសហគមន៍
- គ្រប់គ្រងទំនាស់ និងអនុវត្តជំនាញចរចា

**គ. រក្សានិរន្តរភាព ទំនាក់ទំនងកិច្ចសហការជាមួយភាគីពាក់ព័ន្ធ**

- គាំទ្រកម្មវិធី និងគម្រោងដែលផ្តោតលើសហគមន៍
- ផ្សព្វផ្សាយការបំពេញការងារសាលារៀន និងសហគមន៍

### ២.៤.៦ ទម្រង់នៃគំរូទម្រង់សាលារៀន

បន្ទាប់ពីបានអនុវត្តសាកល្បងកម្មវិធីកំណែទម្រង់សាលារៀន និងបទពិសោធន៍ ពីការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីត-១៩ ក្រសួងបានបង្កើតគំរូកំណែទម្រង់សាលារៀនចំនួន ៣ប្រភេទ គឺ៖

**ប្រភេទទី១ សាលារៀនជំនាន់ថ្មី** ដោយផ្តោតលើការផ្តល់ស្វ័យភាពក្នុងការអនុវត្តកម្មវិធីសិក្សា ដើម្បីបណ្តុះធនធានមនុស្សមានបំណិនសតវត្សរ៍ទី២១ ក្នុងនោះគណៈគ្រប់គ្រងសាលារៀន និងគ្រូបង្រៀនត្រូវមាន៖

ក) សីលធម៌ និងស្តង់ដាវិជ្ជាជីវៈខ្ពស់ ខ) គណនេយ្យភាព និងនវានុវត្តន៍ គ) ចេះប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន ក្នុងការរៀន និងបង្រៀន ឃ). ចេះប្រើប្រាស់វិធីសាស្ត្របង្រៀនថ្មី។ សិស្សសាលារៀនជំនាន់ថ្មីត្រូវមានៈ ក).គំនិតផ្តួចផ្តើមនិងសហគ្រិនភាព ខ).ចេះទំនាក់ទំនង និងសរសេរយ៉ាងប៉ិនប្រសប់ គ).ចេះវិភាគនិងវាយតម្លៃព័ត៌មាន ឃ). ចង់ឃើញ ចង់ដឹង និងមានការស្រមើលស្រមៃខ្ពស់ ច). ចេះគិតបែបវិភាគស៊ីជម្រៅ និងដោះស្រាយបញ្ហា ឆ).ចេះសហការ និងជ).មានភាពរហ័សរហួន និងចេះយកចំណេះដឹងទៅអនុវត្ត។

**ប្រភេទទី២ សាលារៀនគំរូ** ដោយផ្តោតលើ ក).សាលារៀនមានគណនេយ្យភាពជាមួយសហគមន៍ និងសម្រេចបានស្តង់ដាសាលារៀនមានប្រសិទ្ធភាព ខ).សាលារៀនមានស្វ័យភាព ក្នុងការងារផែនការកែលម្អសាលារៀន ថ្នាក់រៀន និងផ្តល់ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំដល់គណៈគ្រប់គ្រង និងគ្រូបង្រៀន គ).សិស្សត្រូវបានធ្វើតេស្តស្តង់ដាប្រកបដោយតម្លាភាព និងយុត្តិធម៌ ដើម្បីបម្រើដល់ការកែលម្អការបង្រៀន និងរៀនការជួយសិស្សរៀនយឺត និងផ្តល់ព័ត៌មានដល់មាតាបិតា ឬអ្នកអាណាព្យាបាល និងសហគមន៍ ឃ).គ្រូបង្រៀនប្រើប្រាស់លទ្ធផលតេស្ត ដើម្បីកែលម្អការបង្រៀន និងទទួលបានការអភិវឌ្ឍគុណវុឌ្ឍិជាប្រចាំង).មាតាបិតា ឬអ្នកអាណាព្យាបាលនិងសហគមន៍ចូលរួមគាំទ្រ និងអភិវឌ្ឍន៍សាលារៀន។

**ប្រភេទទី៣ សាលារៀនធម្មតា** ដោយផ្តោតលើ ក). ការកែលម្អលទ្ធផលសិក្សារបស់សិស្សស្របតាមការរកឃើញលទ្ធផលតេស្តវង្វាយតម្លៃការសិក្សារបស់សិស្សថ្នាក់ជាតិ ថ្នាក់ទី៣ ទី៦ ទី៨ និងទី១១ ខ). ការពង្រឹងវត្តមានគ្រូ និងវត្តមានសិស្សគ). ការពង្រឹងការគ្រប់គ្រងតាមសាលារៀន។

## ២.៥ នាយកសាលាជាអ្នកដឹកនាំ

### ២.៥.១ ភាពជាអ្នកដឹកនាំ

ភាពជាអ្នកដឹកនាំគឺជាសមត្ថភាពដែលដឹកនាំ ឬជំរុញអ្នកឯទៀតក្នុងក្រុម នៅក្នុងអង្គភាពឱ្យពួតដៃធ្វើការ ដើម្បីសម្រេចគោលដៅ (ការងារគ្រប់គ្រងរដ្ឋបាល នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹការ ,២០០២)។ អ្នកដឹកនាំជាបុគ្គលត្រូវបានទទួលស្គាល់ពីសមាជិកក្រុមក្នុងអង្គភាព ឬក្រៅអង្គភាព ដើម្បីដឹកនាំអនុវត្តការងារឱ្យសម្រេចគោលបំណងដែលបានគ្រោងទុក។ កាលណាមនុស្សរួមគ្នាធ្វើការចាប់ពីពីរ

នាក់ឡើងទៅ ត្រូវតែមានអ្នកដឹកនាំ។ គ្រួសារមួយ ភូមិមួយ ឃុំមួយ អង្គភាពមួយ ប្រសិនបើគ្មានមេដឹកនាំ វានឹងធ្វើឱ្យកន្លែងនោះគ្មានសណ្តាប់ធ្នាប់ ខ្វះសន្តិសុខ និងមិនមានការរីកចម្រើន។ ដូចនេះ អ្នកដឹកនាំមានសារៈសំខាន់ណាស់ ព្រោះអ្នកដឹកនាំជាបង្គោលក្នុងការធ្វើសេចក្តីសម្រេចចិត្ត ដែលធ្វើឱ្យមានទំនាក់ទំនងគ្នាពីក្រុមមួយទៅក្រុមមួយទៀត និងជាអ្នកជំរុញទឹកចិត្ត ជាអ្នកផ្តល់សម្ភារៈក្នុងដំណើរការនោះផងដែរ។ ភាពជាអ្នកដឹកនាំគឺជាដំណើរការដែលបុគ្គលម្នាក់ៗមានឥទ្ធិពលលើបុគ្គលមួយក្រុម សម្រេចបាននូវគោលដៅរួមមួយ។ ភាពជាអ្នកដឹកនាំគឺជាសមត្ថភាពរបស់បុគ្គលម្នាក់ដែលជះឥទ្ធិពលដល់សមាជិកក្រុម ដើម្បីជំរុញ និងចូលរួមចំណែកធ្វើឱ្យអង្គភាពសម្រេចជោគជ័យ (House et al,1999)។ ភាពជាអ្នកដឹកនាំគឺជាសមត្ថភាពនៃការអភិវឌ្ឍ និងការទំនាក់ទំនងទៅនឹងចក្ខុវិស័យរបស់មនុស្សមួយក្រុមដែលធ្វើឱ្យទស្សនវិស័យនោះក្លាយជាការពិត។

**២.៥.២ ការបង្ហាញពីការដឹកនាំសាលារៀនរបស់លោក** Beatriz Pont, Deborah Nusche, Hunter Moorman

តាមរយៈអង្គការ OECD (Organization for Economic Co-operation and Development) បានបោះពុម្ពផ្សាយនៅក្នុងវ៉ុលទី១ ស្តីពីការអភិវឌ្ឍភាពជាអ្នកដឹកនាំនៅតាមសាលារៀន ក្នុងឆ្នាំ២០០៨ កំណត់យកគោលការណ៍ សំខាន់ៗចំនួនបួន ទាក់ទងទៅនឹងភាពជាអ្នកដឹកនាំនៅសាលារៀនគឺ៖ (ក) ការទទួលខុសត្រូវរបស់អ្នកដឹកនាំសាលារៀន (ខ) ការចែករំលែកភាពជាអ្នកដឹកនាំសាលារៀន (គ) ការអភិវឌ្ឍជំនាញនៃភាពជាអ្នកដឹកនាំសាលារៀនប្រកបដោយប្រសិទ្ធភាព និង (ឃ) ការអនុវត្តវិជ្ជាជីវៈនៃភាពជាអ្នកដឹកនាំនៅក្នុងសាលារៀន។

**ក. ការទទួលខុសត្រូវរបស់អ្នកដឹកនាំសាលារៀន**

ការស្រាវជ្រាវមួយបានបង្ហាញថា អ្នកដឹកនាំនៅតាមសាលារៀន ត្រូវមានការទទួលខុសត្រូវច្រើនក្នុងការបំពេញភារកិច្ចរបស់ខ្លួន ហើយបង្ករលក្ខណៈឱ្យសិស្សមានស្វ័យភាពក្នុងការសម្រេចចិត្ត។ ការទទួលខុសត្រូវរបស់អ្នកដឹកនាំតាមសាលារៀនអាចបង្ហាញតាមរយៈសមត្ថភាពយល់ដឹងរបស់ខ្លួន ការអនុវត្តការងារដែលធ្វើឱ្យប្រសើរឡើងចំពោះការបង្រៀនរបស់គ្រូ និងការរៀនរបស់សិស្ស។

❖ **ការទទួលខុសត្រូវក្នុងការកែលម្អការសិក្សារបស់សិស្ស**

បញ្ហាចម្បងរបស់អ្នកដឹកនាំនៅតាមសាលារៀនគឺត្រូវរៀបចំគោលនយោបាយច្បាស់លាស់ក្នុងការអនុវត្តលើតួនាទី និងការទទួលខុសត្រូវដែលទាក់ទងនឹងលទ្ធផលនៃការរៀនសូត្រឱ្យមានភាពល្អប្រសើរឡើង (K Leithwood - 2004)។ ការសិក្សានេះក៏បានកំណត់អត្តសញ្ញាណសំខាន់ៗចំនួនបួននៃការទទួលខុសត្រូវដែលជាគន្លឹះសម្រាប់ថ្នាក់ដឹកនាំសាលារៀន ដើម្បីលើកកម្ពស់លទ្ធផលនៃការសិក្សា៖

- ការគាំទ្រ ការវាយតម្លៃ និងការអភិវឌ្ឍគុណភាពគ្រូបង្រៀន
- ការកំណត់គោលដៅ ការវាយតម្លៃ និងគណនេយ្យភាព
- ការគ្រប់គ្រងយុទ្ធសាស្ត្រហិរញ្ញវត្ថុ
- ធនធានមនុស្សចេះសហការគ្នាក្នុងការបំពេញភារកិច្ច

❖ **ការអភិវឌ្ឍភាពជាអ្នកដឹកនាំរបស់សាលារៀនសម្រាប់គោលនយោបាយនិងការអនុវត្ត**

ភាពជាអ្នកដឹកនាំរបស់នាយកសាលាអាចជួយផ្តល់ការណែនាំទៅលើភារកិច្ច និងការទទួលខុសត្រូវឱ្យមានប្រសិទ្ធភាព និងបង្កើតជាគោលនយោបាយមួយច្បាស់លាស់ សម្រាប់សាលារៀនដែលមានឥទ្ធិពលដល់ការបំពេញតួនាទីភារកិច្ចរបស់គ្រូបង្រៀននិងការរៀនសូត្ររបស់សិស្ស ភាពជាអ្នកដឹកនាំរបស់នាយកសាលាជាមូលដ្ឋានគ្រឹះដើម្បីធ្វើឱ្យដំណើរការសាលារៀនប្រព្រឹត្តទៅបានល្អប្រសើរប្រកបដោយការទទួលខុសត្រូវ។

**ខ. ការចែករំលែកភាពជាអ្នកដឹកនាំសាលារៀន**

ការបង្កើតការទទួលខុសត្រូវ និងគណនេយ្យភាពនៃភាពជាអ្នកដឹកនាំសាលារៀន បានបង្កើតឡើងសម្រាប់ការចែករំលែកភាពជាអ្នកដឹកនាំដល់គណៈកម្មការសាលា ឬក្រុមប្រឹក្សាសាលាដែលប្រឈមមុខនឹងការងារថ្មីជាច្រើន។ ខាងក្រោមនេះជាចំណុចដែលត្រូវចែករំលែក៖

- ការលើកទឹកចិត្តក្នុងការចែករំលែកភាពជាអ្នកដឹកនាំ

ការបែងចែកភាពជាអ្នកដឹកនាំអាចពង្រឹងដល់ការគ្រប់គ្រង និងការធ្វើផែនការដោយជោគជ័យ។ ការចែកចាយភាពជាអ្នកដឹកនាំ តាមរយៈក្រុម និងអង្គភាពអាចធ្វើបាននឹងជួយដោះស្រាយបញ្ហាប្រឈម

នៅតាមសាលារៀនក្នុងពេលបច្ចុប្បន្ននេះ និងជួយកែលម្អសាលារៀនឲ្យបានល្អផងដែរ។ ការចែករំលែកនេះ អាចធ្វើតាមរយៈក្រុម ផ្នែកផ្សេងៗ ឬ តាម   រយៈការបង្កើតក្រុមពិសេសមួយដែលផ្អែកលើជំនាញ និងតម្រូវការបច្ចុប្បន្ន។

- ការគាំទ្រការចែករំលែកភាពជាអ្នកដឹកនាំ

ការគាំទ្រដល់ការចែករំលែកភាពជាអ្នកដឹកនាំគឺជាការពង្រឹងគំនិតនៃភាពជាអ្នកដឹកនាំ ដើម្បីបង្កើតយន្តការលើកទឹកចិត្ត និងផ្តល់រង្វាន់ដល់ការចូលរួម ការអនុវត្តកិច្ចការ និងការពង្រីកការដឹកនាំ ការបណ្តុះបណ្តាលភាពជាអ្នកដឹកនាំទៅកាន់ថ្នាក់ដឹកនាំនៅក្នុងសាលារៀន។ អ្នកដឹកនាំនៅតាមសាលារៀនត្រូវបង្កើតយន្តការមួយ ក្នុងការចែករំលែកភាពជាអ្នកដឹកនាំ។ ការគាំទ្រដល់ក្រុមប្រឹក្សាសាលារៀន ការស្រាវជ្រាវមួយបានបង្ហាញថា ក្រុមប្រឹក្សាសាលារៀនបានចូលរួមចំណែកដល់ការអភិវឌ្ឍភាពជាអ្នកដឹកនាំនៅក្នុងសាលាបានច្រើន។ ក្រុមប្រឹក្សាសាលារៀនមានតួនាទី និងការទទួលខុសត្រូវក្នុងដំណើរការសាលា និងពិនិត្យនូវភាពស៊ីសង្វាក់គ្នារវាងថ្នាក់ដឹកនាំ គ្រូបង្រៀន និងសិស្សានុសិស្ស ។ ក្រុមប្រឹក្សាសាលាអាចជួយផ្តល់នូវគោលការណ៍ គំនិត និងយុទ្ធសាស្ត្រដើម្បីកសាងសាលារៀនឱ្យមានភាពរីកចម្រើន។

### គ. ការអភិវឌ្ឍជំនាញនៃភាពជាអ្នកដឹកនាំសាលាប្រកបដោយប្រសិទ្ធភាព

#### ❖ ការបន្តអភិវឌ្ឍភាពជាអ្នកដឹកនាំ

ការអភិវឌ្ឍភាពជាអ្នកដឹកនាំគឺជាសកម្មភាពមួយដែលធ្វើឡើងក្នុងគោលបំណងពង្រឹងដល់ការគ្រប់គ្រង និងដឹកនាំនៅតាមស្ថាប័ន ឬអង្គភាព។ ដំណើរការនៃការអភិវឌ្ឍភាពជាអ្នកដឹកនាំនេះត្រូវមានលក្ខណៈស្របតាមតម្រូវការ និងបរិបទនៅតាមសាលារៀន។ ដំណាក់កាលសំខាន់ៗចំនួនបីដែលត្រូវយកមកអភិវឌ្ឍរួមមាន៖

- ការលើកទឹកចិត្តក្នុងការបណ្តុះបណ្តាលភាពជាអ្នកដឹកនាំ
- ការរៀបចំកម្មវិធីបណ្តុះបណ្តាលភាពជាអ្នកដឹកនាំ
- ការធានាដល់ការបណ្តុះបណ្តាលដើម្បីបំពេញតម្រូវការ

អ្នកដឹកនាំនៅតាមសាលារៀនត្រូវផ្តល់ឱកាសឱ្យទទួលការបណ្តុះបណ្តាលច្រើនក្នុងគោលបំណងពង្រឹងសមត្ថភាពដឹកនាំ និងគ្រប់គ្រង។ នៅក្នុងការបណ្តុះបណ្តាលនេះគួរលើកទឹកចិត្តដល់អ្នកដឹនាំនៅតាមសាលារៀនឱ្យអភិវឌ្ឍជំនាញឱ្យមានភាពច្បាស់លាស់។ ការបណ្តុះបណ្តាលនេះត្រូវធ្វើការឱ្យត្រូវនឹងបញ្ហាជាក់ស្តែងនៅកន្លែងការងារ។

- ជានាឱ្យមានស្ថិរភាពនៃការបណ្តុះបណ្តាល

ការបណ្តុះបណ្តាលភាពជាអ្នកដឹកនាំពិតជាមានភាពចាំបាច់ក្នុងដំណើរការនៃការងារ។ ការងារនេះត្រូវតែធ្វើឡើងជាបន្តបន្ទាប់ដើម្បីឱ្យមានភាពល្អប្រសើរ។ ការងារបណ្តុះបណ្តាលនេះ មានស្តង់ដាច្បាស់លាស់ និងជានាឱ្យមានគុណ ភាព។ ក្រុមដឹកនាំ បណ្តុះបណ្តាល ត្រូវវាយតម្លៃ បង្កើតយន្តការតាមដានសមត្ថភាពអ្នកទទួលការបណ្តុះបណ្តាល។

- ជានានូវភាពសមស្របសម្រាប់ការបណ្តុះបណ្តាលប្រកបដោយប្រសិទ្ធភាព

ដើម្បីធ្វើការបណ្តុះបណ្តាលឱ្យមានប្រសិទ្ធភាពនិងគុណភាព គេត្រូវគិតដល់ភាពចាំបាច់នៃការងារ។ វាបានបង្ហាញនូវគន្លឹះសំខាន់ៗដូចជា៖ កម្មវិធីសិក្សា បទពិសោធន៍ជាក់ស្តែង ក្នុងការងារ ការប្រមូលផ្តុំក្រុម ការណែនាំ ការបង្វឹកបង្ហាត់ និងការសិក្សាពីការសហការគ្នារវាងកម្មវិធីសិក្សានិងសាលារៀន។

**ឃ.ការធ្វើឱ្យអ្នកដឹកនាំនៅក្នុងសាលារៀនបំពេញការងារប្រកបដោយប្រសិទ្ធភាព**

អ្នកដឹកនាំជាមនុស្សម្នាក់ដែលត្រូវមានសមត្ថភាពក្នុងការបំពេញការងារ។ ការជ្រើសរើសបេក្ខជនដឹកនាំត្រូវធ្វើឡើងដោយយកចិត្តទុកដាក់ប្រកបដោយតម្លាភាព និងគុណភាព។ កាលណាជ្រើសរើសបេក្ខជនបានត្រឹមត្រូវនឹងជួយដល់ដំណើរការរបស់អង្គភាពនៅថ្ងៃអនាគតបានល្អផងដែរ។ អ្នកដឹកនាំល្អនឹងអនុវត្តការងារមានប្រសិទ្ធភាព និងទទួលបានទាំងបរិមាណ និងគុណភាព។ ដូចនេះ ដំណើរការនៃការជ្រើសរើសបេក្ខជនដែលបានបំពេញលក្ខខណ្ឌស្តង់ដាគឺត្រូវធ្វើការសម្ភាសលើសមត្ថភាពដែលទាក់ទងនឹងជំនាញ។ បន្ទាប់ពីជ្រើសរើសបានត្រូវយកមកបណ្តុះបណ្តាលជំនាញបន្ថែមទៀត។

- **ការផ្តោតលើប្រាក់ខែរបស់អ្នកដឹកនាំសាលា**

ផលប្រយោជន៍ការងារ ជាផ្នែកមួយដែលធ្វើឱ្យការបំពេញភារកិច្ចបានល្អប្រសើរ គឺប្រាក់ខែខ្ពស់ជាការទាក់ទាញដល់បេក្ខជនដែលមានសមត្ថភាពមកដាក់ពាក្យសុំធ្វើការងារ។ វាមានឥទ្ធិពលដល់ការអនុវត្តការងាររបស់អ្នកដឹកនាំ។ ការកំណត់ប្រាក់ខែត្រូវមានលក្ខណៈសមស្របតាមតួនាទី ឋានៈ មុខងារ និងបន្ទុកនៃការងារ។

- **ទទួលស្គាល់តួនាទីរបស់អ្នកដឹកនាំសាលារៀន**

មានចំណេះដឹងហើយត្រូវចែករំលែកចំណេះដឹងទាំងនេះទៅដល់បុគ្គលិកក្រោមឱវាទ ការធ្វើបែបនេះ ក្នុងគោលបំណងឱ្យការបំពេញភារកិច្ចរបស់ពួកគាត់មានគុណភាពនិងងប្រសិទ្ធភាព។ អ្នកដឹកនាំសាលារៀនត្រូវស្គាល់ឱ្យបានច្បាស់នូវតួនាទី និងភារកិច្ចរបស់ខ្លួន ព្រោះវាជួយដល់ការអនុវត្តការងារបានល្អ។

- **ផ្តល់នូវជម្រើសនិងការគាំទ្រសម្រាប់ការអភិវឌ្ឍអាជីព**

ការអភិវឌ្ឍអាជីពជាកិច្ចការមួយដ៏សំខាន់សម្រាប់អ្នកដឹកនាំសាលារៀននិងបង្កើតនូវភាពប៉ិនប្រសប់ សម្រាប់ការដឹកនាំ និងគ្រប់គ្រង។ មានវិធីសាស្រ្តជាច្រើនក្នុងការបណ្តុះបណ្តាលអាជីពដល់អ្នកដឹកនាំឱ្យចេះធ្វើនិងធ្វើដោយឆន្ទៈ បត់បែនទៅតាមស្ថានភាពជាក់ស្តែង។ អ្នកដឹកនាំសាលា ត្រូវស្វែងរកឱកាសដោយខ្លួនឯង ដើម្បីអភិវឌ្ឍជំនាញដឹកនាំរបស់ខ្លួនឱ្យប្រសើរឡើង។

## ២.៥.៣ លក្ខណៈសម្បត្តិរបស់អ្នកដឹកនាំ

អ្នកដឹកនាំជាប្រភេទមនុស្សដែលមានលក្ខណៈដឹកនាំ មានចំណេះដឹង និងបំណិនសមស្រប ក្នុងការដឹកនាំក្រុមដើម្បីសម្រេចលទ្ធផលដែលចង់បាន។ អ្នកដឹកនាំមិនអាចខ្វះបុគ្គលិកលក្ខណៈ និងអាកប្បកិរិយាបានទេ (ការគ្រប់គ្រង និងភាពជាអ្នកដឹកនាំ, 2016)។

### ក. លក្ខណៈសម្បត្តិអ្នកដឹកនាំល្អ

អ្នកដឹកនាំល្អត្រូវមានលក្ខណៈសម្បត្តិដូចតទៅៈ

១-មានសេចក្តីក្លាហាន ២-ចិត្តល្អចេះជួយគ្នា ៣-អារម្មណ៍នឹងន ៤-មានចក្ខុវិស័យ ៥-មានសមត្ថភាព ៦-មានតម្លាភាព ៧-មានទំនងទំនងគ្នាល្អ ៨-មានយុត្តិធម៌ និង ៩-មានសុខភាពមាំមួន។

**ខ. លក្ខណៈសម្បត្តិអ្នកដឹកនាំមិនល្អ**

លក្ខណៈសម្បត្តិអ្នកដឹកនាំមិនល្អមាន៖១-ច្រណែនឈ្នានីស ២-លោភលន់គិតប្រយោជន៍ផ្ទាល់ខ្លួន ៣-ខ្វះចំណេះដឹង ខ្វះសមត្ថភាព ៤-ប្រើឥទ្ធិពលមិនធ្វើគុណចំពោះអ្នកដទៃ ៥-គ្មានការទទួលខុសត្រូវ ៦-មិននឹងន មិនចេះអត់ធ្មត់ ៧-ខ្ជិលច្រអូស ៨-ទស្សនៈចង្អៀតចង្អល់ ៩-ប្រមឹកបាត់បង់សតិសម្បជញ្ញៈ។

**គ. វាយតម្លៃអ្នកដឹកនាំ**

អ្នកដឹកនាំល្អត្រូវគេវាយតម្លៃលើចំណុចមួយចំនួនដូចតទៅ៖

១-លទ្ធផលលើផ្នែកបរិមាណ និងគុណភាព ២-គោរព និងស្មោះត្រង់ពីអ្នកក្រោមបង្គាប់ ៣-មនសិការ និងសាមគ្គីភាព។

**ឃ. កត្តាមួយចំនួនដែលធ្វើឱ្យអ្នកដឹកនាំជោគជ័យ**

អ្នកដឹកនាំត្រូវស្វែងយល់នូវចំណុចដែលខ្លួនអាចនឹងទទួលបានជោគជ័យដូចជា៖១.បុគ្គលិកក្នុងអង្គភាពរបស់ខ្លួនគោរពនិងស្រឡាញ់ ២-ប្រព័ន្ធការងាររបៀបរបបការងារ ច្បាប់ទម្លាប់ វិន័យខាងក្នុង និងខាងក្រៅ ៣- សភាពបរិស្ថាន និង ៤-ជំហរអ្នកដឹកនាំ

### ២.៥.៤ បំណិនរបស់អ្នកដឹកនាំ

តាមរយៈការកំណត់មុខងារ ឬគោលការណ៍សំខាន់ៗរបស់អ្នកដឹកនាំមានគោលបំណងមួយចំនួនដែលអាចជួយឱ្យសម្រេចនូវមុខងារទាំងនោះក្នុងស្ថានភាពខុសៗគ្នា។ អ្នកដឹកនាំត្រូវតែបង្កើនសមត្ថភាពរបស់ខ្លួន ដើម្បីកសាងបំណិនឆ្ពោះទៅសម្រេចឧត្តមភាពមួយរួមមាន៖

**ក.ការកំណត់កិច្ចការ៖កិច្ចការជាអ្វីដែលយើងត្រូវធ្វើ** មនុស្សនៅក្នុងអង្គភាព ឬក្រុមមួយត្រូវការកិច្ចការមួយមាន លក្ខណៈច្បាស់លាស់ (clear) រូបី (Concrete) មានពេលវេលាកំណត់ច្បាស់លាស់ (Deadline) ប្រាកដនិយម(Realistic) មានការជំរុញឱ្យខិតខំអស់ពីសមត្ថភាព (Challenging) អាចវាយតម្លៃបាន (Able to evaluate)។

**ខ. ការធ្វើផែនការ៖ការធ្វើផែនការគឺជាសកម្មភាពគន្លឹះមួយរបស់ក្រុម ឬអង្គភាព។** ការធ្វើផែនការទាមទារឲ្យមានការស្វែងរកជម្រើសនានា។ ការធ្វើផែនការទទួលលទ្ធផលល្អបំផុតកាលណាគេធ្វើជាមួយ

មនុស្សដទៃដោយបើកចំហគំនិតមានការជំរុញនិងតាមវិធីច្នៃប្រឌិត។ ការប្រមើលមើលព្រឹត្តិការណ៍ជាយថាហេតុតែងមាននៅក្នុងផែនការ។

**គ. ការសង្ខេប៖** ការសង្ខេបដើម្បីផ្តល់ការណែនាំដល់ក្រុមគឺជាមុខងារមូលដ្ឋានមួយរបស់អ្នក។ ការសង្ខេបគឺជាឱកាសមួយ ដើម្បីបង្កើតបរិយាកាសល្អប្រសើរមួយ លើកកម្ពស់ការងាក្រុម ជំរុញនិងលើកទឹកចិត្តបុគ្គលម្នាក់ៗ។ លក្ខណៈនៃការសង្ខេបដែលមានប្រសិទ្ធភាពក្នុងការផ្តល់ការណែនាំប្រកបដោយជោគជ័យគឺ៖ដឹកនាំដែលតែងតែអនុវត្តវិធីនិយាយតទល់មុខគ្នាមួយទល់នឹងមួយ។

- ការរៀបចំ
- ភាពច្បាស់លាស់
- មានលក្ខណៈរស់រវើក
- មានលក្ខណៈធម្មជាតិ(ពីកំណើត)
- អំណះអំណាងបញ្ជាក់

**ឃ. ការត្រួតពិនិត្យ**

អ្នកដឹកនាំដែលឆ្នើមរមែងទទួលលទ្ធផលជាអតិបរមាដោយប្រើធនធានអប្បបរមា។ ដើម្បីត្រួតពិនិត្យអ្នកដទៃ អ្នកដឹកនាំត្រូវតែបង្ហាញនូវស្វ័យភាពត្រួតពិនិត្យមានប្រព័ន្ធត្រួតពិនិត្យល្អមួយដែលងាយនិងមានប្រសិទ្ធភាពក្នុងការពិនិត្យដូចជាត្រួតពិនិត្យហិរញ្ញកិច្ច ត្រួតពិនិត្យការអនុវត្តការងារ និងត្រួតពិនិត្យទៅលើអ្វីដែលអ្នកដទៃគួរធ្វើឬមិនគួរធ្វើដើម្បីសម្រេចឱ្យបានវត្ថុបំណងដែលបានគ្រោងទុក ជោគជ័យនៃការចាត់ការ ការដាក់បទបញ្ជា ការទប់ទល់ឬជំរុញការខិតខំប្រឹងប្រែងបំពេញកិច្ចការរបស់បុគ្គល ឬក្រុម គឺជាលក្ខណៈវិនិច្ឆ័យ សម្រាប់ការសាកល្បង ការត្រួតពិនិត្យរបស់អ្នកដឹកនាំដែលមានប្រសិទ្ធភាពម្នាក់។

**ង. ការវាយតម្លៃ៖ អ្នកដឹកនាំត្រូវ៖**

- វាយតម្លៃផលវិបាកនានា
- វាយតម្លៃការប្រតិបត្តិរបស់ក្រុម
- វាយតម្លៃ និងបណ្តុះបណ្តាលបុគ្គល

- វិនិច្ឆ័យមនុស្ស

**ច. ការរៀបចំចាត់ចែង៖ អ្នកដឹកនាំល្អគឺជាអ្នកដឹកនាំដែលពូកែ៖**

- រៀបចំចាត់ចែងខ្លួនឯងកិច្ចការផ្ទាល់ខ្លួន ជាពិសេសរបៀបគ្រប់គ្រងខ្លួនឯង ដូចជាពេលវេលា និងរបៀបធ្វើប្រតិភូកម្មការងារ។

របៀបចាត់ចែងការងារក្រុម៖ កសាងនិងរក្សាក្រុមដើម្បីធានាថាក្រុមល្អនិងមានប្រសិទ្ធភាព

- រៀបចំចាត់ចែងអង្គភាព៖រចនាសម្ព័ន្ធនិងប្រព័ន្ធប្រតិបត្តិការរបស់មនុស្ស។ អ្នកដឹកនាំគួរគិតពិចារណាលើបំណិនចាត់ចែងរបស់ខ្លួន តាមរយៈការពិនិត្យមើលលើកិច្ចការក្រុម និងបុគ្គល។

**ឆ. ការធ្វើជាគម្រូ៖ អ្នកដឹកនាំល្អត្រូវធ្វើជាគម្រូដើម្បីជោគជ័យ៖** អ្នកដឹកនាំត្រូវចំណាយពេលវេលាខ្លះក្នុងការចុះមើលនិងជជែកជាមួយបុគ្គលិកនិងបង្កើតនូវភាពស្គាល់គ្នាទៅវិញទៅមកច្បាស់លាស់។ គម្រូដែលអ្នកដឹកនាំផ្តល់ឱ្យជាឧទាហរណ៍ល្អ ឬអាក្រក់គឺអាស្រ័យទៅលើអ្នកដឹកនាំ។

## ២.៥.៥ គន្លឹះមួយចំនួនដែលធ្វើឱ្យអ្នកដឹកនាំសម្រេចបានជោគជ័យ

### ក. ការធ្វើសេចក្តីសម្រេចចិត្ត

ការស្រាវជ្រាវមួយដែលបានធ្វើឡើងជាមួយនាយកសាលាជាង២០០នាក់នៅសហរដ្ឋអាមេរិកបានបង្ហាញថាសមត្ថភាពក្នុងការធ្វើសេចក្តីសម្រេចចិត្តជាលក្ខណៈសម្បត្តិសំខាន់បំផុតរបស់នាយកសាលារៀន។ ការស្រាវជ្រាវនេះបានបង្ហាញថាមានជំហាន៦ដែលនាយកសាលាបានប្រើក្នុងការធ្វើសេចក្តីសម្រេចចិត្ត៖(១).ការកំណត់វត្ថុបំណង (២).ការប្រមូលព័ត៌មាន (៣) ការបង្កើតជម្រើស(៤).ការវាយតម្លៃជម្រើស (៥).ការអនុវត្តជម្រើស និង(៦).តាមដានផលវិបាកដែលមានបំណិនសំខាន់ៗនៃការគិតប្រកបដោយប្រសិទ្ធភាព និងការធ្វើសេចក្តីសម្រេចចិត្តរួមមាន៖

- ✓ **ការវិភាគ៖**

ការវិភាគគឺជាសមត្ថភាពមួយដ៏សំខាន់ក្នុងការបែងចែករឿងរ៉ាវ ឬប្រព្រឹត្តការណ៍ជាចំណែកៗ ជាពិសេសចំណុច ឬបញ្ហាស្មុគស្មាញឱ្យទៅជាងាយៗ និងសាមញ្ញ។ លក្ខណៈសម្គាល់នៃការគិតមានដូចខាងក្រោម៖

- បង្កើតទំនាក់ទំនងរវាងផ្នែក និងរឿងរ៉ាវទាំងមូល
- កំណត់ឫសគល់នៃបញ្ហា
- កំណត់ស្ថានភាពនៃបញ្ហា

✓ **ការសំយោគៈ**

ការធ្វើសេចក្ដីសម្រេចចិត្តទាមទារឱ្យបុគ្គលម្នាក់ៗ ចូលរួមបញ្ចេញគំនិតទស្សនៈដែលផ្អែកលើសមត្ថភាព ដើម្បីរួមចំណែកបង្កើតបានជាសកម្មភាពពេញលេញមួយហៅថាសំយោគ។ ទស្សនៈរួមគ្នាត្រូវយកមកប្រើប្រាស់ក្នុងបរិបទនៃការធ្វើសេចក្ដីសម្រេចចិត្ត។

✓ **ការវាយតម្លៃៈ**

រាល់ការធ្វើសេចក្ដីសម្រេចចិត្ត ទាមទារឱ្យមានការបកស្រាយ និងវាយតម្លៃព័ត៌មាន។ ជាធម្មតារង្វាយតម្លៃផ្ដោតលើបញ្ហាចំនួនពីរគឺៈ(១) ទិន្នន័យដែលប្រមូលមកពីប្រភពជាច្រើន (២) ដឹងទិន្នន័យណាដែលទាក់ទងដល់ការធ្វើសេចក្ដីសម្រេចចិត្ត និងមួយណាដែលមិនទាក់ទង។ មុនពេលអនុវត្តយុទ្ធសាស្ត្រវាយតម្លៃចុងក្រោយ គេត្រូវពិនិត្យនិងពិចារណាឡើងវិញរាល់ជម្រើសដែលបានរៀបចំដោះស្រាយ។ បើគ្មានដំណើរការវាយតម្លៃដ៏រឹងមាំមួយទេ គេមិនអាចស្មានដឹងពីកម្រិតនៃភាពជោគជ័យប៉ុណ្ណានោះទេ។

**ខ. ការជឿជាក់**

ទ្រឹស្ដីជឿជាក់គឺជាសភាពដែលបុគ្គលម្នាក់ៗលម្អៀងទៅរកការអនុវត្តបែបណាមួយដោយរំពឹងថាការអនុវត្តនោះនឹងផ្ដល់នូវលទ្ធផលមួយដែលធ្វើឱ្យទាក់ទាញដល់បុគ្គលផ្សេងទៀត។ ចំណុចគន្លឹះនៃទ្រឹស្ដីនេះគឺជាការយល់ដឹងពីការគ្រប់គ្រងគោលដៅរបស់បុគ្គលិក ហើយមានទំនាក់ទំនងរវាងការខិតខំប្រឹងប្រែងការប្រតិបត្តិនិងការផ្ដល់រង្វាន់។ ទ្រឹស្ដីនេះបង្ហាញពីលក្ខណៈនៃការជឿជាក់ដូចខាងក្រោមៈ

- ការជឿជាក់កំណត់បាននូវសកម្មភាពជាក់លាក់
- ការជឿជាក់អាចមានលក្ខណៈវិជ្ជមាន និងអវិជ្ជមាន
- ការជឿជាក់វិជ្ជមាននឹងនាំឱ្យមានសកម្មភាពវិជ្ជមាន
- ការជឿជាក់អវិជ្ជមាននឹងនាំឱ្យមានសកម្មភាពអវិជ្ជមាន

- ទំនាក់ទំនងនៃការជឿជាក់
  - ការជឿជាក់ទាក់ទងនឹងការខិតខំប្រឹងប្រែង៖ការខិតខំរបស់បុគ្គលនាំឱ្យទទួលបានលទ្ធផលតាមកម្រិត។
  - សម្ភារៈ៖ ដឹងថាការប្រព្រឹត្តត្រឹមកម្រិតណាដែលនាំឱ្យបានលទ្ធផល។
  - រង្វាន់៖ភាពទាក់ទាញ និងសារៈសំខាន់នៃការប្រតិបត្តិផ្តល់រង្វាន់ដល់បុគ្គល។
- ការជឿជាក់មួយចំនួនដែលនាយកសាលាគួរមាន៖
  - ចក្ខុវិស័យមួយច្បាស់លាស់សម្រាប់សាលារៀន
  - ការចែករំលែកការទទួលខុសត្រូវជាមួយក្រុម
  - សេចក្តីស្មោះត្រង់
  - ការលើកទឹកចិត្តដោយការនិយាយពីការងារល្អរបស់បុគ្គល
  - កុមារទាំងអស់ទទួលបានឱកាសចូលរៀនដោយសមធម៌
  - ការបង្ហាញពីវិធីសាស្ត្រ និងបច្ចេកទេសថ្មីៗដល់ក្រុម
  - ទំនាក់ទំនងល្អជាមួយក្រុម និងសហគមន៍

❖ **ការចូលរួមរបស់បុគ្គលិកក្នុងអង្គភាព**

ដើម្បីធានាឱ្យមានការចូលរួមពីបុគ្គលិកក្រោមឱវាទ អ្នកដឹកនាំត្រូវមានការគ្រប់គ្រងប្រកបដោយគណនេយ្យភាព៖មានការគ្រប់គ្រងប្រកបដោយគណនេយ្យភាពគឺជាទស្សទានមួយដែលបង្ហាញពីការកែទម្រង់ក្នុងរដ្ឋបាលសាធារណៈដែលនៅក្នុងនោះតម្រូវឱ្យអ្នកគ្រប់គ្រងដឹកនាំ ឬស្ថាប័ននីមួយៗត្រូវមាន៖

១.ស្តង់ដាសមត្ថភាពនៅក្នុងការងារ

២. ខ្នាតរង្វាស់នៃការបំពេញការងារ

៣.ការចាត់ចែងនិងត្រួតពិនិត្យការងារ

៤.ប្រព័ន្ធតាមដាន និងវាយតម្លៃ

៥.ប្រព័ន្ធនៃការលើកទឹកចិត្ត និងការដាក់ពិន័យ

- **ទំនាក់ទំនងល្អ៖** អ្នកដឹកនាំត្រូវមានការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាព គឺត្រូវពូកែក្នុងការបញ្ជូនសារ និងទាញការសន្និដ្ឋានឱ្យបានល្អពីក្រុម ឬមនុស្សឯងទៀត។ គ្រប់ទិដ្ឋភាពនៃការប្រាស្រ័យទាក់ទងត្រូវរៀបចំឱ្យបានល្អ និងបង្កើនប្រសិទ្ធភាពដើម្បីធានាថា យើងយល់ច្បាស់ពីអ្នកដទៃហើយ អ្នកដទៃក៏យល់ច្បាស់ពីយើងដែរ។
- ***វត្តមានរបស់នាយកសាលានៅកន្លែងធ្វើការ៖*** ការស្រាវជ្រាវជាច្រើនរបស់ប្រទេសនានាលើសកលលោក បានបង្ហាញពីលក្ខណៈសម្បត្តិមួយ ក្នុងចំណោមលក្ខណៈសម្បត្តិរបស់នាយកសាលារៀនដែលមានប្រសិទ្ធភាពខ្ពស់ នោះ គឺនាយកសាលារៀនត្រូវមានវត្តមាននៅក្នុងសាលារៀននៅម៉ោងបំពេញការងារ។ សាលារៀននីមួយៗដែលសិស្សទទួលលទ្ធផលខ្ពស់ក្នុងការសិក្សាគឺជាសាលាដែលនាយកសាលាបង្ហាញមុខជាប់ជានិច្ច។ គ្រូបង្រៀនចាប់អារម្មណ៍លើវត្តមានបង្ហាញមុខរបស់នាយកសាលាតាមរយៈការសង្កេតតាមដានការបង្រៀនរបស់ពួកគាត់ ដែលធ្វើឡើងជាផ្លូវការ និងមិនផ្លូវការ។
- **មានប្រព័ន្ធការងារ របៀបរបបធ្វើការច្បាស់លាស់**

អង្គភាពមួយមានដំណើរការទៅបានដោយរលូននិងមានលក្ខណៈជាប្រព័ន្ធនោះ អ្នកដឹកនាំចាំបាច់ត្រូវតែមានប្រព័ន្ធការងារច្បាស់លាស់ ពោលគឺរៀបចំបែងចែកភារកិច្ចដល់បុគ្គលិកក្រោមឱវាទទៅតាមតួនាទី ភារកិច្ច ជំនាញ និងទំនួលខុសត្រូវខ្ពស់របស់ពួកគេ ដោយភ្ជាប់នូវការគោរពក្រមសីលធម៌វិជ្ជាជីវៈ និងវិន័យការងារហ្មត់ចត់។ ជាមួយនឹងការប្រគល់ភារកិច្ចឱ្យទទួលខុសត្រូវតាមជំនាញរៀងៗខ្លួន ការវាយតម្លៃការបំពេញការងារគឺជាចំណុចដ៏សំខាន់ដែលនាំឱ្យមានការកែលម្អនិងការរីកចម្រើនសម្រាប់បុគ្គលិកព្រមទាំងអង្គភាព។ តាមរយៈការវាយតម្លៃការបំពេញការងារនេះ អាចឱ្យអ្នកដឹកនាំដឹងថាបុគ្គលិកម្នាក់ៗ ឬអង្គភាពសម្រេចបានលទ្ធផលកម្រិតណា។

- ***សភាពបរិស្ថាន៖*** សំដៅដល់បរិបទមជ្ឈដ្ឋានជុំវិញអង្គភាព ការចូលរួមរបស់សហគមន៍ (អជ្ញាធរ ព្រះសង្ឃ អាជីវករ និងមាតាបិតាសិស្ស)។
- **ជំហរអ្នកដឹកនាំ៖** អ្នកដឹកនាំត្រូវមានគោលជំហររឹងមាំត្រឹមត្រូវ ហើយមានភាពបត់បែន។

### ២.៦.១ នាយកសាលាជាអ្នកគ្រប់គ្រង

គុណសម្បត្តិ ឥរិយាបថ និងសីលធម៌របស់នាយកសាលា ជាតម្លៃរបស់មនុស្សទូទៅ។ មនុស្សខ្វះសីលធម៌មិនត្រឹមតែគ្មានប្រយោជន៍ដល់សង្គមប៉ុណ្ណោះទេ គឺថែមទាំងផ្តល់គ្រោះថ្នាក់ដល់សង្គមជាតិយ៉ាងធ្ងន់ធ្ងរផងដែរ។ មនុស្សខ្វះសីលធម៌មានលក្ខណៈសាហាវជាងសត្វទៅទៀត។ ចំណែកអ្នកគ្រប់គ្រង បើខ្វះសីលធម៌វិជ្ជាជីវៈ ប្រាដកជាមិនអាចទទួលបានជោគជ័យក្នុងមុខងាររបស់ខ្លួនឡើយ ដូចនេះ នាយកសាលាអាចទទួលគុណសម្បត្តិនេះបានយ៉ាងងាយ កាលណាគេមានភាពម្ចាស់ការ មានភក្តីភាព និងមានមនសិការវិជ្ជាជីវៈខ្ពស់ សុភវិនិច្ឆ័យត្រឹមត្រូវ ក្នុងកិច្ចការទទួលខុសត្រូវលើការងារដឹកនាំនិងគ្រប់គ្រងអង្គភាព។ គុណសម្បត្តិសំខាន់ៗរបស់នាយកសាលាមានៈ**ក.ឆន្ទៈម្ចាស់ការ** ជាអ្នកគ្រប់គ្រង ជាអ្នកជំរុញតម្រង់ទិស និងថែរក្សានូវឥរិយាបថមនុស្ស ក្នុងការសម្រេចគោលបំណងមួយ។ កត្តាមួយដែលនាំឱ្យបុគ្គល ឬក្រុម ឬអង្គភាពទទួលបានជោគជ័យគឺកត្តាឆន្ទៈបម្រើការងាររបស់បុគ្គល ឬសមាជិកក្រុមនៅក្នុងអង្គភាព។ ឆន្ទៈបម្រើការងារនេះផ្តើមចេញពីមនសិការរបស់បុគ្គល ឬក្រុម។ វាមិនមែនជាកត្តាកំណត់ ឬការចាប់បង្ខំនោះទេ ប៉ុន្តែជាទូទៅជាតម្លៃរបស់មនុស្ស គឺផ្សារភ្ជាប់ទៅនឹងការងារ និងរបៀបរបបនៃការប្រតិបត្តិ **ខ.ភក្តីភាព** ភក្តីភាពជាសេចក្តីត្រូវការដែលមនុស្សក្នុងសង្គមត្រូវប្រកាន់ភ្ជាប់ ដើម្បីលើកតម្កើងកិត្តិយស និងសេចក្តីថ្លៃថ្នូរទាំងក្នុងនាមបុគ្គល និងក្នុងនាមស្ថាប័ន ដែលខ្លួនកំពុងបម្រើការងារ។ ភក្តីភាពគឺជាសុជីវធម៌ និងសីលធម៌ដែលជាគុណតម្លៃខាងចរិយាធម៌របស់មនុស្ស។ នាយកសាលាប្រកបដោយមនសិការត្រូវប្រកាន់យកនូវភក្តីភាព៤យ៉ាងដូចខាងក្រោមៈ

- ការយល់ដឹងអំពីសភាពការណ៍
- ភក្តីភាពចំពោះស្ថាប័ន
- ភក្តីភាពចំពោះវិជ្ជាជីវៈ
- ភក្តីភាពចំពោះការប្រើប្រាស់សេវា

## ២.៦.២ ទីតាំងរបស់នាយកសាលា

នាយកសាលាជាប្រតិភូរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ទទួលបន្ទុកសាលារៀនមួយ។ ក្នុងនាមជាអ្នកតំណាងក្រសួង នាយកសាលាជាប្រមុខអង្គភាព តំណាងអំណាចរដ្ឋបាល ដែលទទួលការខុសត្រូវខ្ពស់បំផុត ក្នុងការចាត់ចែងការងារដឹកនាំនិងគ្រប់គ្រងសកម្មភាពរបស់សាលារៀនទាំងផ្នែករដ្ឋបាល បច្ចេកទេស និងផ្នែកទំនាក់ទំនង។ នាយកសាលាត្រូវបានជ្រើសរើសចេញពីនាយករង ឬបុគ្គលិក ដែលមានសមត្ថភាពរដ្ឋបាល បច្ចេកទេស និងមានគុណធម៌មានមនសិការវិជ្ជាជីវៈខ្ពស់ ព្រមទាំងមានបទពិសោធន៍គ្រប់គ្រងអង្គភាព។ សម្រាប់គ្រឹះស្ថានឯកជន នាយកត្រូវតែងតាំងដោយក្រុមប្រឹក្សាភិបាល យោងតាមប្រកាសលេខ១៤៣៥ អយក.ប្រក (ក្រសួងអប់រំ យុវជន និងកីឡា ២០០៧)។ ចំណែកនាយករងត្រូវបានជ្រើសរើសចេញពីបុគ្គលិកអប់រំដែលមានសមត្ថភាពរដ្ឋបាល បច្ចេកទេស និងមានគុណធម៌ មានមនសិការវិជ្ជាជីវៈខ្ពស់ មានបទពិសោធន៍ និងទេពកោសល្យ ក្នុងការងារបង្រៀនសិស្សានុសិស្ស។ ការជ្រើសរើសនិងតែងតាំងមន្ត្រីគ្រប់គ្រងបានល្អ និងមានប្រសិទ្ធភាព ត្រូវជ្រើសរើសមន្ត្រីឱ្យទៅកាន់មុខតំណែងសមស្របតាមឧបនិស្ស័យ កម្រិតសញ្ញាបត្រ ជំនាញ សមត្ថភាពបំពេញការងារ បទពិសោធន៍ការងារ សមត្ថភាពការងារ និងបុគ្គលិកលក្ខណៈជាមន្ត្រីគ្រប់គ្រង ប្រកបដោយមនសិការវិជ្ជាជីវៈខ្ពស់។ ការតែងតាំងត្រូវជៀសវាងនូវការឆ្លៀតឱកាស ឬប្រកាន់បក្សពួក។

## ២.៦.៣ តួនាទីរបស់នាយកសាលា

តួនាទីរបស់នាយកសាលាគឺសំដៅលើការទទួលខុសត្រូវ ក្នុងការធ្វើការងារអ្វីៗទាំងអស់ ដែលខ្លួនមានលទ្ធភាពអាចធ្វើទៅបាន ដើម្បីសម្រួល និងជំរុញឱ្យបុគ្គលិកទាំងអស់ បំពេញការងារដោយជោគជ័យ។ សាលារៀនដែលល្អ គឺត្រូវមាននាយកសាលាល្អ ដែលជាភាពចាំបាច់ សម្រាប់ដល់ការបង្រៀនរបស់គ្រូ និងការសិក្សារបស់សិស្សានុសិស្ស។ ដូចនេះនាយកសាលាត្រូវតែយល់ដឹងពីតួនាទី និងភារកិច្ចរបស់ខ្លួនឱ្យបានច្បាស់លាស់។ នាយកសាលា ជាអ្នកជួយប្រព័ន្ធអប់រំឱ្យមានដំណើរការ ដោយរៀបចំចាត់ចែងនិងអនុវត្តរាល់ការងារទាំងអស់ នៅក្នុងអង្គភាព ព្រមទាំងជាអ្នកបណ្តុះបណ្តាល និងជំរុញបុគ្គលិកក្រោម

ឱវាទ ឱ្យមានជំនាញវិជ្ជាជីវៈខ្ពស់ ដែលធ្វើឱ្យសិស្សទទួលបានលទ្ធផលល្អក្នុងការសិក្សា។ តួនាទីសំខាន់ៗ របស់នាយកសាលាមានដូចខាងក្រោម៖

- អជ្ញាធរអប់រំ
- មន្ត្រីរដ្ឋបាល
- ស្របនឹងពាក្យស្លោកមួយឃ្លាពោលថា«នាយកសាលាជាបេះដូងរបស់សាលារៀន
- ទីប្រឹក្សាគរុកោសល្យ
- នាយកសាលាជាអធិការអេចិន្ត្រៃយ៍
- អ្នកចរចារ
- អ្នកអប់រំ

## ២.៦.៤ ភារកិច្ចរបស់នាយកសាលា

នាយកសាលាជាអ្នកផ្តល់សេវាកម្ម អ្នកពិគ្រោះយោបល់ និងជាភ្នាក់ងារអភិវឌ្ឍសហគមន៍។ ភារកិច្ចរបស់នាយកសាលាគឺសំដៅដល់កិច្ចការទាំងឡាយណាដែលនាយកប្រតិបត្តិប្រចាំថ្ងៃ ដើម្បីធ្វើឱ្យសាលារៀនមានការងាររដ្ឋបាល ការងារបច្ចេកទេសគរុកោសល្យ និងការងារទំនាក់ទំនងល្អ។

**ក.ការងាររដ្ឋបាល៖** នាយកសាលារៀនត្រូវពិនិត្យមើលរាល់លិខិតស្នាម ឯកសាររដ្ឋបាលចេញចូលឱ្យបានច្បាស់  លាស់។ លិខិតចូលដូចជាសេចក្តីប្រកាស សរាចរណ៍ សេចក្តីណែនាំព័ត៌មានរបស់ក្រសួងអប់រំ យុវជន និងកីឡា ដែលបានដាក់មក ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាព។ នាយកសាលារៀន ត្រូវខិតខំបំពេញភារកិច្ចឱ្យបានប្រសើរឡើង។ ចំណែកលិខិតចេញវិញត្រូវរក្សាទុកឱ្យមានរបៀបរៀបរយ និងតាមកាលបរិច្ឆេទ។ ទម្រង់នៃលិខិតទាំងអស់ត្រូវមានលក្ខណៈត្រឹមត្រូវនឹងតាមស្តង់ដា របស់លិខិតស្នាម។ ការអនុវត្តបែបនេះអាចជួយដល់ដំណើរការគ្រប់គ្រង និងដឹកនាំមានលក្ខណៈរលូន និងប្រសើរឡើង។

**ខ.ការងារបច្ចេកទេសគរុកោសល្យ៖** ការអភិវឌ្ឍសាលារៀន កើតចេញពីការសហការគ្នា រវាងនាយកសាលា គ្រូបង្រៀន និងសិស្សានុសិស្ស។ ក្នុងនាមជានាយកសាលា ការងារពិនិត្យតាមដាន និងវាយតម្លៃលើការបង្រៀនរបស់គ្រូជាបញ្ហាដ៏សំខាន់មួយ។ ការធ្វើអធិការកិច្ចរបស់នាយកសាលាចំពោះគ្រូ តាម

មុខវិជ្ជា អាចជួយជំរុញ និងលើទឹកចិត្តដល់កិច្ចការបានល្អ។ នាយកសាលាត្រូវផ្តល់ជាអនុសាសន៍ និងវិធីសាស្រ្តខ្លះៗ ដើម្បីកែលម្អនូវចំណុចខ្វះខាតមួយចំនួន។ ការណែនាំគរុកោសល្យអាចធ្វើនៅពេលមានប្រជុំរួម ប្រជុំក្រុមបច្ចេកទេស ឬប្រជុំបុគ្គលដែលជួយដល់គ្រូបង្រៀន និងបុគ្គលិកអប់រំស្វែងយល់បន្ថែម និងយកទៅអនុវត្ត ដើម្បីផ្តល់ចំណេះដឹងដល់សិស្សានុសិស្ស។ នាយកសាលាក៏ត្រូវផ្សព្វផ្សាយនូវវិធីសាស្រ្តថ្មីៗដែលខ្លួនផ្សព្វផ្សាយជាលិខិតបទដ្ឋានគតិយុត្តទាំងអស់នោះដល់បុគ្គលិកក្រោមឱវាទឱ្យយល់ដឹង បានដឹង ឬដែលបានមកពីការចូលរួមសិក្ខាសាលានានាមកតម្រង់ទិសវិជ្ជាជីវៈរបស់គ្រូបង្រៀន។ នាយកសាលាត្រូវបើកវគ្គបំប៉នបន្ថែមដល់គ្រូបង្រៀន និងបុគ្គលិកក្រោមឱវាទទាំងអស់ផងដែរ។

**គ.ការងារទំនាក់ទំនង៖**

❖ ការងារទំនាក់ទំនងក្នុងសាលា

- ជាមួយនាយករង
- ជាមួយគ្រូបង្រៀន និងបុគ្គលិកនានា
- ជាមួយសិស្សានុសិស្ស

❖ ការងារទំនាក់ទំនងក្រៅសាលា

- ជាមួយមាតាបិតាឬអ្នកអាណាព្យាបាល
- ជាមួយសហគមន៍
- ជាមួយអាជ្ញាធរ

## ២.៧ ស្តង់ដាសាលារៀនគំរូសម្រាប់វិទ្យាល័យធនធាន

វិទ្យាល័យធនធានមួយចាត់ទុកថា បានបំពេញនូវស្តង់ដាអប្បបរមាកម្មវិធីសាលារៀនគំរូ លុះត្រាតែវិទ្យាល័យធនធាននោះមានពិន្ទុសរុបយ៉ាងតិច២១៣ និងស្តង់ដានីមួយៗបានបំពេញនូវពិន្ទុអប្បបរមាផងដែរ (ដូចមានក្នុងតារាងខាងក្រោម)។ ក្នុងករណី វិទ្យាល័យធនធានមានពិន្ទុសរុប២១៣ ឬលើសនេះ ហើយស្តង់ដាណាមួយមិនមានពិន្ទុអប្បបរមា នោះមិនចាត់ទុកថាជាវិទ្យាល័យធនធានជាប់ស្តង់ដាអប្បបរមាសាលារៀនគំរូនោះឡើយ។

| ពិន្ទុ/ស្តង់ដា | ស្តង់ដាទី១ | ស្តង់ដាទី២ | ស្តង់ដាទី៣ | ស្តង់ដាទី៤ | ស្តង់ដាទី៥ | សរុបពិន្ទុ |
|---|---|---|---|---|---|---|
| ពិន្ទុអប្បបរមា | ៣៩ | ៥៧ | ៤២ | ៥១ | ២៤ | ២១៣ |

**ស្តង់ដាទាំង៥រួមមាន៖**

ស្តង់ដាទី១៖ សាលារៀនដំណើរការផលសម្រេចនៃការអប់រំ និងការសិក្សារបស់សិស្ស មាន១២សូចនាករ

ស្តង់ដាទី២៖ ថ្នាក់រៀនដំណើរការសម្រាប់ការបង្រៀន និងការសិក្សារៀនសូត្ររបស់សិស្សម្នាក់ៗ មាន១៨សូចនាករ

ស្តង់ដាទី៣៖ ភាពជាម្ចាស់នៃសហគមន៍សាលារៀន មាន១៣សូចនាករ

ស្តង់ដាទី៤៖ ដំណើរប្រតិបត្តិការ និងរដ្ឋបាលសាលារៀន មាន១៧សូចនាករ

ស្តង់ដាទី៥៖ គណនេយ្យភាពថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិមាន៧សូចនាករ

សរុបសេចក្តីមក ការលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស ដែលជាផលសម្រេចចុងក្រោយនៃការអប់រំគឺមិនអាចកាត់ផ្តាច់ ឬមើលរំលងពីគុណវុឌ្ឍិ ការដឹកនាំនិងគ្រប់គ្រង និងការទទួលខុសត្រូវរបស់នាយកសាលានោះទេ។ ការសិក្សានេះ នឹងពិនិត្យមើលពីឧត្តមានុវត្តនៃការដឹកនាំនិងគ្រប់គ្រងរបស់នាយកសាលាវេស្ទើនអន្តរជាតិ " ករណីសិក្សា៖ សាលាវេស្ទើនអន្តរជាតិសាខា ស្ទែងមានជ័យ"។

# ជំពូក៣
# វិធីសាស្ត្រស្រាវជ្រាវ

# ជំពូក៣

# វិធីសាស្ត្រស្រាវជ្រាវ

ជំពូកនេះ មានគោលបំណងធ្វើការបកស្រាយ ពន្យល់ ការជ្រើសរើសវិធីសាស្ត្រស្រាវជ្រាវ វិធីសាស្ត្រជ្រើសរើសសំណាក ប្រភពទិន្នន័យ វិធីសាស្ត្រប្រមូលទិន្នន័យ វិធីសាស្ត្រវិភាគទិន្នន័យ និងក្រមសីលធម៌នៃការស្រាវជ្រាវ។

## ៣ ១.ការជ្រើសរើសវិធីសាស្ត្រស្រាវជ្រាវ

ការស្រាវជ្រាវនេះ បានប្រើប្រាស់វិធីសាស្ត្រស្រាវជ្រាវតាមបែបចម្រុះ (វិធីសាស្ត្រស្រាវជ្រាវបែបបរិមាណវិស័យ និងគុណវិស័យ) ដោយប្រើប្រាស់កម្រងសំណួរបំពេញ និងកម្រងសំណួរសម្ភាសន៍ផ្ទាល់ ដើម្បីធ្វើការប្រមូល និងវិភាគទិន្នន័យ ប្រមូលថ្មី(Primary Data) សម្រាប់ការបកស្រាយលទ្ធផលស្រាវជ្រាវ។ ក្នុងការវិភាគទិន្នន័យបែបគុណវិស័យ ការសិក្សាស្រាវជ្រាវនេះ បានប្រើប្រាស់វិធីសាស្ត្រវិភាគបែបខ្លឹមសារ និងពន្យល់បកស្រាយ។ រីឯការវិភាគតាមបែបបរិមាណវិស័យវិញគឺបកស្រាយ និងពិពណ៌នាតាមស្ថិតិ។

## ៣.២ វិធីសាស្ត្រជ្រើសរើសសំណាក

សំណាកដែលត្រូវបានជ្រើសរើសសម្រាប់ការសិក្សានេះ មានបីកម្រិត គឺកម្រិតគណៈគ្រប់គ្រងសាលាវេស្ទើនអន្តរជាតិសាខាស្ពែនខៀមចំនួន៣នាក់ ក្នុងនោះមាននាយក១នាក់ និងនាយិការង២នាក់។ កម្រិតមន្ត្រីជំនាញមានចំនួន១៤នាក់ ក្នុងនោះអ្នកសប្របសម្រួលភាសាខ្មែរចំនួន២នាក់ មន្ត្រីផ្នែកធនធានមនុស្សចំនួន៤នាក់ មន្ត្រីផ្នែករដ្ឋបាលចំនួន៤នាក់មន្ត្រីផ្នែកការិយាល័យសិក្សា (Registrar) ចំនួន៤នាក់ និងសិស្សដែលកំពុងសិក្សានៅក្នុងឆ្នាំសិក្សា២០២២-២០២៣សរុបចំនួន២២១៣នាក់។ ការជ្រើសរើសសំណាកជាបីកម្រិតដូចនេះ គឺដើម្បីផ្ទៀងផ្ទាត់ចម្លើយរវាងកម្រិតនីមួយៗសម្រាប់បញ្ជាក់ពីសុក្រឹតភាពនៃចម្លើយដែលអាចធ្វើឱ្យលទ្ធផលមានភាពជឿជាក់បាន។

## ៣.៣ ប្រភពទិន្នន័យ

### ៣.២.១ ទិន្នន័យបឋម

ក្នុងការសិក្សានេះ អ្នកស្រាវជ្រាវបានប្រមូលទិន្នន័យបឋមពីកម្រងសំណួរបំពេញ និងកម្រងសំណួរសម្ភាសន៍។ កម្រងសំណួរបំពេញមានគណៈគ្រប់គ្រង៣នាក់ មន្ត្រីជំនាញ១៤នាក់ និងសិស្សចំនួន២២១៣នាក់។

### ៣.២.២ ទិន្នបន្ទាប់បន្សំ

អ្នកសិក្សាបានស្វែងរកឯកសារដែលមានស្រាប់ពាក់ព័ន្ធនឹងវិស័យអប់រំដូចជា ស្តង់ដានាយកសាលាគុរុកោសល្យស្តង់ដានាយកសាលាកម្ពុជា ស្តង់ដានាយកសាលាអាស៊ាន ស្តង់ដាសាលាគំរូភាពជាអ្នកដឹកនាំ និងឯកសារស្នាដៃសិស្សជំនាន់មុនៗជាដើម។

## ៣.៤ វិធីសាស្ត្រប្រមូលទិន្នន័យ

មុនដំណើរការនៃការប្រមូលទិន្នន័យ អ្នកស្រាវជ្រាវបានធ្វើបទបង្ហាញអំពីគោលបំណង និងខ្លឹមសារនៃការស្រាវជ្រាវទៅកាន់អ្នកដែលត្រូវសម្ភាសន៍។ បន្ទាប់ពីការធ្វើបទបង្ហាញរួចហើយ អ្នកស្រាវជ្រាវចាប់ផ្តើមសម្ភាសទៅកាន់គណៈគ្រប់គ្រងសាលាវេស្ទើនអន្តរជាតិសាខាស្តេខៀម។ ចម្លើយដែលប្រមូលបាននឹងត្រូវបានរក្សាទុក ដើម្បីធ្វើការវិភាគ (១) សិក្សាស្វែងយល់ពីឧត្តមានុវត្តនៃការដឹកនាំនិងគ្រប់គ្រងបុគ្គលិករបស់នាយកសាលាវេស្ទើនអន្តរជាតិសាខាស្តេខៀម និង (២) រកឱ្យឃើញពីរបៀបប្រើប្រាស់វិធីសាស្ត្រក្នុងការគ្រប់គ្រងគ្រូបង្រៀន និងទាក់ទាញអ្នកអាណាព្យាបាលឱ្យបញ្ជូនកូនមកសិក្សានៅសាលាវេស្ទើនអន្តរជាតិ សាខាស្តេខៀម។

## ៣.៥ វិធីសាស្ត្រវិភាគទិន្នន័យ

ទិន្នន័យកម្រងសំណួរនៃការសិក្សាស្រាវជ្រាវនេះ ត្រូវបានសម្អាត រៀបចំ និងបែងចែកតាមប្រភេទ និងតាមចំណុចនៃការវិភាគបកស្រាយ។ ទិន្នន័យនៃការវិភាគលើកម្រងសំណួរ គឺត្រូវបានបកស្រាយដាក់ចូលក្នុងតារាងទិន្នន័យ ដើម្បីសិក្សាពី (១) ឧត្តមានុវត្តនៃការដឹកនាំនិងគ្រប់គ្រងបុគ្គលិករបស់នាយកសាលាវេស្ទើនអន្តរជាតិនៅសាខាស្តេខៀម និង (២) របៀបប្រើប្រាស់វិធីសាស្ត្រក្នុងការគ្រប់គ្រងគ្រូបង្រៀន និងទាក់ទាញអ្នកអាណាព្យាបាលឱ្យបញ្ជូនកូនមកសិក្សានៅសាលាវេស្ទើនអន្តរជាតិ សាខាស្តេខៀម។

## ៣.៦ ក្រមសីលធម៌នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ បានរក្សាសុវត្ថិភាពបុគ្គល និងអត្តសញ្ញាណរបស់អ្នកចូលរួម។ ដើម្បីជាការផ្តល់នូវក្រមសីលធម៌នៃការស្រាវជ្រាវដល់អ្នកចូលរួម អ្នកស្រាវជ្រាវបានស្នើសុំការអនុញ្ញាតពីអ្នកចូលរួម។ បុគ្គលភាព និងអត្តសញ្ញាណរបស់អ្នកចូលរួម មិនត្រូវបានលាតត្រដាងជាសាធារណៈ។ ទស្សនៈ និងចម្លើយរបស់អ្នកចូលរួម ត្រូវបានធ្វើការវិភាគ និងបកស្រាយដោយគោរពតាមក្រមសីលធម៌នៃការស្រាវជ្រាវក្នុងការសិក្សា។

# ជំពូក៤
# លទ្ធផល និងការពិភាក្សា

# ជំពូក៤

# លទ្ធផល និងការពិភាក្សា

## ៤.១. ឧត្តមមានុវត្តនៃការដឹកនាំនិងគ្រប់គ្រងរបស់នាយកសាលាវេស្ទើនអន្តរជាតិ សាខាស្តេខៀម

លទ្ធផលស្រាវជ្រាវក្នុងតារាងទី៤.១ បានបង្ហាញថា ចំនួន និងភាគរយសិស្សចូលរៀននៅសាលាវេស្ទើនអន្តរជាតិសាខាស្តេខៀមមានចំនួនជាង៩៧%។ ចំនួនសិស្ស និងភាគរយដែលបោះបង់ការសិក្សាមានតិចជាង១%។ រីឯ ចំនួន និងភាគរយសិស្សឡើងថ្នាក់មានជាង៩៨%។ សិស្សដែលបាននិទ្ទេស A និង B លើមុខវិជ្ជាភាសាខ្មែរមានចំនួនចន្លោះពី២០%-២៩% ខណៈពេលដែលសិស្សបាននិទ្ទេស A និង B លើមុខវិជ្ជាគណិតវិទ្យាមានចំនួនចន្លោះពី ៣០%-៣៩%។ កាន់តែពិសេសជាងនេះទៅទៀតនោះ ចំនួន និងភាគរយសិស្សមាននិទ្ទេសមធ្យមឡើងលើមុខវិជ្ជារូបវិទ្យា និងគីមីវិទ្យា (A, B, C)មានចំនួនចន្លោះពី ៤០%-៥៩%។ ចំនួន និងភាគរយសិស្សមាននិទ្ទេសមធ្យមឡើងទៅលើមុខវិជ្ជាជីវវិទ្យា និងប្រវត្តិវិទ្យា (A, B, C) មានចន្លោះពី៦០%-៨០%។ លទ្ធផលសិស្សថ្នាក់ទី៧/១០ មានសមត្ថភាពអានតាមស្តង់ដា (១០០ ទៅ១២០ពាក្យ/២៥០ ទៅ២៧០ ពាក្យ ក្នុងមួយនាទី) គឺច្រើនជាង៨០%។ ចំនួននេះគឺដូចគ្នាទៅនឹងភាគរយសិស្សថ្នាក់ជាតិទី៩/១២ដែលមានសមត្ថភាពអានតាមស្តង់ដា( ៣០០ ទៅ៣៥០ពាក្យ ក្នុង



| *តារាង ៤.១* ស្តង់ដាទី១ សាលារៀនមានដំណើរការសម្រេចផលសម្រេចនៃការអប់រំ និងការសិក្សារបស់សិស្ស | | |
|---|---|---|
| **ខ្លឹមសារ** | | **ចម្លើយ** |
| ១ | ចំនួនសិស្ស និងភាគរយចូលរៀន | >៩៧% |
| ២ | ចំនួនសិស្ស និងភាគរយបោះបង់ការសិក្សា | <១% |
| ៣ | ចំនួន និងភាគរយសិស្សឡើងថ្នាក់ | >៩៨% |
| ៤ | ចំនួននិងភាគរយសិស្សមាននិទ្ទេស A និង B លើមុខវិជ្ជាភាសាខ្មែរ | ២០%-២៩% |
| ៥ | ចំនួននិងភាគរយសិស្សមាននិទ្ទេស A និង B លើមុខវិជ្ជាគណិតវិទ្យា | ៣០%-៣៩% |
| ៦ | ចំនួននិងភាគរយសិស្សមាននិទ្ទេសមធ្យមឡើងលើមុខវិជ្ជារូបវិទ្យា (A, B, C) | ៤០%-៥៩% |
| ៧ | ចំនួននិងភាគរយសិស្សមាននិទ្ទេសមធ្យមឡើងលើមុខវិជ្ជាគីមីវិទ្យា (A, B, C) | ៤០%-៥៩% |
| ៨ | ចំនួនភាគរយសិស្សមាននិទ្ទេសមធ្យមឡើងលើមុខវិជ្ជាជីវវិទ្យា (A, B, C) | ៦០%-៨០% |
| ៩ | ចំនួននិងភាគរយសិស្សមាននិទ្ទេសមធ្យមឡើងលើមុខវិជ្ជាប្រវត្តិវិទ្យា (A, B, C) | ៦០%-៨០% |
| ១០ | ចំនួននិងភាគរយសិស្សថ្នាក់ទី៧/១០ មាន សមត្ថភាពអានតាមស្តង់ដា(១០០ ទៅ១២០ពាក្យ/២៥០ទៅ២៧០ពាក្យក្នុងមួយនាទី) | ≥៨០% |
| ១១ | ចំនួននិងភាគរយសិស្សថ្នាក់ជាតិទី៩/១២មានសមត្ថភាពអានតាមស្តង់ដា (៣០០ទៅ៣៥០ពាក្យក្នុងមួយនាទី) | ≥៨០% |
| ១២ | ចំនួននិងភាគរយសិស្សប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ (ថ្នាក់ជាតិ) | ≥៩០% |

**តារាង ៤.២** បង្ហាញលទ្ធផលសម្រេចបានរបស់សាលាវេស្ទើនអន្តរជាតិសាខាស្តេខៀម ក្នុងការអនុវត្តស្តង់ដាទី២។ ថ្នាក់រៀនមានផែនការបង្រៀន៣ឆ្នាំ និងផែនការប្រចាំឆ្នាំតាមមុខវិជ្ជា១០០%។ ថ្នាក់រៀនមានផែនការបង្រៀនប្រចាំឆ្នាំតាមមុខវិជ្ជា១០០%។ មុខវិជ្ជាដែលមានបំណែងចែកកម្មវិធីសិក្សាបង្រៀនប្រចាំសប្តាហ៍ និងកាលវិភាគបង្រៀនលម្អិតតាមមេរៀនមានចន្លោះពី១១ ទៅ១២មុខវិជ្ជា។ មុខវិជ្ជាថ្នាក់ទី៧/

១០ដល់១២មានប្លង់មេរៀនគ្រប់មេរៀន។ អ្វីដែលកាន់តែចាប់អារម្មណ៍នោះ ចំនួនថ្នាក់រៀនមានផែនការបង្រៀន៣ខែ ចំនួនម៉ោងសិក្សាសរុបប្រចាំឆ្នាំបានអនុវត្តធៀបនឹងចំនួនម៉ោងកំណត់ និងភាគរយថ្នាក់រៀនបានប្រជុំពិនិត្យតាមដានការរៀនសូត្រទៀងទាត់គឺមានចំនួន១០០%ដូចគ្នា។ ទោះបីជាយ៉ាងណាក៏ដោយភាគរយសិស្សបានរៀបចំ និងអនុវត្តតាមផែនការសិក្សាប្រចាំឆ្នាំសិក្សា និងភាគរយសិស្សបានធ្វើកិច្ចការគម្រោងទាំងអស់និងក្លឹបសិក្សា(សរុប៨ក្លឹបសិក្សា)មានតែជាង៩៥%ប៉ុណ្ណោះ។ ខណៈពេលដែលភាគរយសិស្សបានចូលរួមសកម្មភាពមគ្គុទេសក៍អាជីព និងការផ្តល់ប្រឹក្សាមានត្រឹមតែជាង៥០%។ ដោយឡែក ភាគរយនៃការបើកដំណើរការបន្ទប់កុំព្យូទ័រតាមផែនការ និងភាគរយនៃការបើកដំណើរការបន្ទប់ពិសោធន៍វិទ្យាសាស្ត្រទាំង៤តាមផែនការគឺមានរហូតដល់១០០%។ ចំពោះដំណើរការនិងការអភិវឌ្ឍបណ្ណាល័យតាមផែនការ និងដំណើរការគាំទ្រនិងអភិវឌ្ឍបន្ទប់ពហុបំណងគឺមិនសូវបានល្អនោះទេ។ ចំនួនដងនៃសិស្សប្រកួតប្រជែងអានអក្សរ និងចំនួនដងប្រកួតប្រជែងការធ្វើលំហាត់គណិតវិទ្យាគឺមានតិចជាង៦ដង។ យ៉ាងណាមិញ ភាគរយសិស្សអវត្តមានលើស៤ដងគឺមានកម្រិតទាបត្រឹមតែ០.៥% ហើយគ្រូអវត្តមាន ដោយមិនមានគ្រូជំនួសមានតិចជាង៥ដង។ ដោយឡែកចំនួនថ្ងៃដែលសាលារៀនបិទទ្វារខុសពីប្រតិទិនឈប់សម្រាកប្រចាំឆ្នាំរបស់រាជរដ្ឋាភិបាលមានត្រឹមតែ១ថ្ងៃប៉ុណ្ណោះ។

*តារាង ៤.២* ស្តង់ដាទី២ ថ្នាក់រៀនដំណើរការសម្រាប់ការបង្រៀន និងការសិក្សារៀនសូត្ររបស់សិស្សម្នាក់ៗ

| | ខ្លឹមសារ | ចម្លើយ |
|---|---|---|
| ១៣ | ចំនួននិងភាគរយថ្នាក់រៀនមានផែនការបង្រៀន៣ឆ្នាំ និងប្រចាំឆ្នាំតាមមុខវិជ្ជា | ១០០% |
| ១៤ | ចំនួនថ្នាក់រៀនមានផែនការបង្រៀនប្រចាំឆ្នាំតាមមុខវិជ្ជា | ១០០% |
| ១៥ | ចំនួនមុខវិជ្ជាមានបំណែងចែកកម្មវិធីសិក្សាបង្រៀនប្រចាំសប្តាហ៍ និងកាលវិភាគបង្រៀនលម្អិតតាមមេរៀន | ១១-១២ |
| ១៦ | ចំនួនមុខវិជ្ជាថ្នាក់ទី៧/១០ដល់១២មានប្លង់មេរៀនតាមគ្រប់មេរៀន | ១១-១២ |
| ១៧ | ចំនួនថ្នាក់រៀនមានផែនការបង្រៀន៣ខែ | ១០០% |

| | | |
|---|---|---|
| ១៨ | ចំនួនម៉ោងសិក្សាសរុបប្រចាំឆ្នាំបានអនុវត្តធៀបនឹងចំនួនម៉ោងកំណត់ | ១០០% |
| ១៩ | ចំនួននិងភាគរយថ្នាក់រៀនបានប្រជុំពិនិត្យតាមដានការរៀនសូត្រទៀងទាត់ | ១០០% |
| ២០ | ភាគរយសិស្សបានរៀបចំ និងអនុវត្តតាមផែនការសិក្សាប្រចាំឆ្នាំសិក្សា | ≥៩៥% |
| ២១ | ភាគរយសិស្សបានចូលរួមសកម្មភាពមគ្គុទេសក៍អាជីព និងការផ្តល់ប្រឹក្សា | ≥៥០% |
| ២២ | ភាគរយសិស្សបានធ្វើកិច្ចការគម្រោងទាំងអស់និងក្លឹបសិក្សា (សរុប៨ក្លឹបសិក្សា) | ≥៩៥% |
| ២៣ | ភាគរយនៃការបើកដំណើរការបន្ទប់កុំព្យូទ័រ តាមផែនការ | ១០០% |
| ២៤ | ភាគរយនៃការបើកដំណើរការបន្ទប់ពិសោធន៍វិទ្យាសាស្ត្រទាំង៤តាមផែនការ | ១០០% |
| ២៥ | ដំណើរការ និងអភិវឌ្ឍបណ្ណាល័យ តាមផែនការ | សប្តាហ៍ទៀងទាត់ |
| ២៦ | ដំណើរការ គាំទ្រ និងអភិវឌ្ឍបន្ទប់ពហុបំណង | សប្តាហ៍ទៀងទាត់ |
| ២៧ | ចំនួនដងសិស្សប្រកួតប្រជែងអានអក្សរ | ≤៦ |
| ២៨ | ចំនួនដងប្រកួតប្រជែងការធ្វើលំហាត់គណិតវិទ្យា | ≤៦ |
| ២៩ | ភាគរយសិស្សអវត្តមានលើស ៤ដង | ០.៥% |
| ៣០ | ចំនួនដងគ្រូអវត្តមាន ដោយមិនមានគ្រូជំនួស | ≤៥ |
| ៣១ | ចំនួនថ្ងៃសាលារៀនបិទទ្វារខុសពីប្រតិទិនឈប់សម្រាកប្រចាំឆ្នាំរបស់រាជរដ្ឋាភិបាល | ១ |

**តារាង ៤.៣** បង្ហាញពីលទ្ធផលនៃការអនុវត្តស្តង់ដាទី៣។ លទ្ធផលនេះបង្ហាញឱ្យឃើញថា គ្រួសារសិស្សគឺមិនមានអំពើហិង្សានោះទេ។ សមាសភាពគណៈកម្មការគ្រប់គ្រងសាលារៀន (គ.គ.ស) ឬ ក្រុមប្រឹក្សាសាលា (ក.ប.ស) គឺមានច្រើនជាង១០នាក់ ហើយការប្រជុំប្រចាំត្រីមាស ឆមាស និងឆ្នាំដែលដឹកនាំដោយ គ.គ.ស ឬក.ប.ស គឺធ្វើឡើងជាទៀងទាត់។ ភាគរយគ្រូបង្រៀនបានទទួលការសម្រេចចិត្តពីគណៈកម្មការគ្រប់គ្រងសាលារៀន ឬក្រុមប្រឹក្សាសាលា លើការវាយតម្លៃការអនុវត្តការងារប្រចាំឆ្នាំមានច្រើនជាង ៩៥%។ ចំណែកឯនាយក និងនាយករងទាំងអស់សុទ្ធតែបានទទួលការសម្រេចចិត្តពីគណៈកម្មការ

គ្រប់គ្រងសាលារៀន ឬក្រុមប្រឹក្សាសាលា លើការវាយតម្លៃការអនុវត្តការងារប្រចាំឆ្នាំ។ សិស្សអវត្តមាន សិស្សធ្លាក់មធ្យមភាគ សិស្សត្រៀមបោះបង់ ឬបោះបង់ការសិក្សាគឺបានមករៀនវិញទៀងទាត់រហូតដល់ជាង ៩៥%។ លទ្ធផលវង្វាយតម្លៃស្តង់ដាលើសមត្ថភាពសិស្ស បានអនុម័ត និងបិទផ្សាយជាប្រចាំ។ ផែនការសកម្មភាពអនុវត្តសូចនាករគន្លឹះ ផែនការកែលម្អសាលារៀននិងថវិកាប្រចាំឆ្នាំ របាយការណ៍វាយតម្លៃស្តង់ដាសាលារៀន របាយការណ៍ប្រចាំឆ្នាំ និងទិន្នន័យបិទផ្សាយជាសាធារណៈសុទ្ធតែត្រូវបានឆ្លងនិងទទួលការអនុម័តដោយគណៈកម្មការគ្រប់គ្រងសាលារៀន ឬក្រុមប្រឹក្សាសាលារៀន។ បើនិយាយអំពីបរិស្ថានបៃតងអនាម័យ អគារសិក្សា បន្ទប់រៀន សង្ហារឹម និងបរិក្ខារសិក្សាបានថែរក្សា និងពង្រីកបន្ថែម តាមបែបបច្ចេកវិទ្យាស្របតាមផែនការ។ ចំពោះកម្មវិធីមគ្គុទេសក៍អាជីព និងការផ្តល់ប្រឹក្សាអនុវត្តតាមផែនការបានត្រឹមត្រូវ គឺអនុវត្តជាប្រចាំខែ ឆមាស និងឆ្នាំទាំងអស់។

| *តារាង ៤.៣* **ស្តង់ដាទី៣ ភាពជាម្ចាស់នៃសហគមន៍សាលារៀន** | | |
|---|---|---|
| **ខ្លឹមសារ** | | **ចម្លើយ** |
| ៣២ | ចំនួននិងភាគរយគ្រួសារមានហិង្សា | 0% |
| ៣៣ | ចំនួនសមាសភាពគណៈកម្មការគ្រប់គ្រងសាលារៀន (គ.គ.ស) ឬ ក្រុមប្រឹក្សាសាលា (ក.ប.ស) | >10 |
| ៣៤ | ការប្រជុំប្រចាំត្រីមាស ឆមាស និងឆ្នាំ ដឹកនាំដោយ គ.គ.ស ឬក.ប.ស | ទាំងអស់ |
| ៣៥ | ភាគរយគ្រូបង្រៀនបានទទួលការសម្រេចចិត្តពីគណៈកម្មការគ្រប់គ្រងសាលារៀន ឬ ក្រុមប្រឹក្សាសាលា លើការវាយតម្លៃការអនុវត្តការងារប្រចាំឆ្នាំ | ≥៩៥% |
| ៣៦ | ចំនួននាយកនិងនាយករងបានទទួលការសម្រេចចិត្តពីគណៈកម្មការគ្រប់គ្រង សាលារៀន ឬក្រុមប្រឹក្សាសាលា លើការ វាយតម្លៃការអនុវត្តការងារប្រចាំឆ្នាំ | ទាំងអស់ |
| ៣៧ | ចំនួននិងភាគរយសិស្សអវត្តមាន ធ្លាក់មធ្យមភាគ ត្រៀមបោះបង់ ឬបោះបង់ការសិក្សាបានមករៀនវិញទៀងទាត់ | >៩0% |
| ៣៨ | លទ្ធផលវង្វាយតម្លៃស្តង់ដាលើសមត្ថភាពសិស្ស បានអនុម័ត និងបិទផ្សាយ | ទាំងអស់ |
| ៣៩ | ផែនការសកម្មភាពអនុវត្តសូចនាករគន្លឹះអនុម័តដោយគណៈកម្មការគ្រប់គ្រងសាលារៀន ឬ ក្រុមប្រឹក្សាសាលា | អនុម័តឆ្នាំទី៣ |

| | | |
|---|---|---|
| ៤០ | ផែនការកែលម្អសាលារៀន និងថវិកាប្រចាំឆ្នាំអនុម័តដោយគណៈកម្មការគ្រប់គ្រងសាលារៀន ឬ ក្រុមប្រឹក្សាសាលា | អនុម័តឆ្នាំទី៣ |
| ៤១ | របាយការណ៍វាយតម្លៃស្តង់ដាសាលារៀន អនុម័តដោយគណៈកម្មការគ្រប់គ្រងសាលារៀន ឬ ក្រុមប្រឹក្សាសាលា | អនុម័តឆ្នាំទី៣ |
| ៤២ | របាយការណ៍ប្រចាំឆ្នាំអនុម័តដោយគណៈកម្មការគ្រប់គ្រងសាលារៀនឬក្រុមប្រឹក្សសាលា | អនុម័តឆ្នាំទី៣ |
| ៤៣ | ទិន្នន័យបិទផ្សាយជាសាធារណៈអនុម័តដោយគណៈកម្មការគ្រប់គ្រងសាលារៀន ឬ ក្រុមប្រឹក្សាសាលា និងបិទផ្សាយ | អនុម័តឆ្នាំទី៣ |
| ៤៤ | បរិស្ថានបៃតង អនាម័យ អគារសិក្សា បន្ទប់រៀន សង្ហារឹម និងបរិក្ខាសិក្សាបានថែរក្សា និងពង្រីកបន្ថែម តាមបែបបច្ចេកវិទ្យា | តាមផែនការឆ្នាំទី៣ |
| ៤៥ | កម្មវិធីមគ្គុទេសក៍អាជីព និងការផ្តល់ប្រឹក្សាអនុវត្តតាមផែនការបានត្រឹមត្រូវ | ទាំងអស់ |

**តារាង ៤.៤** បង្ហាញពីលទ្ធផលនៃការអនុវត្តស្តង់ដាទី៤។ លទ្ធផលនេះបង្ហាញឱ្យឃើញថា ផែនការសមិទ្ធកម្មអនុវត្តសូចនាករគន្លឹះរយៈពេលមធ្យមបានរៀបចំតាមការណែនាំ។ ផែនការកែលម្អសាលារៀនបានរៀបចំតាមការណែនាំ ហើយផលសម្រេចរយៈពេល ៣ឆ្នាំ និងផែនការបង្រៀនរយៈពេល ៣ឆ្នាំបានរៀបចំតាមការណែនាំនៅរៀងរាល់ឆ្នាំទី៤។ ចំពោះការធ្វើតេស្តស្តង់ដាប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំគឺបានរៀបចំយ៉ាងទៀងទាត់។ លើសពីនេះ លទ្ធផលតេស្តស្តង់ដាប្រចាំខែ ត្រូវបានប្រើប្រាស់ដើម្បីជួយដល់ការសិក្សារបស់សិស្សរៀនយឺត រីឯលទ្ធផលតេស្តចុងត្រីមាសបានយកទៅប្រើប្រាស់ក្នុងការរៀបចំផែនការបង្រៀន៣ខែតាមថ្នាក់រៀនបានយ៉ាងទៀងទាត់។ ចំពោះការប្រជុំប្រចាំខែ ត្រីមាស និងឆមាសបានប្រជុំតាមការណែនាំ គឺធ្វើឡើងទៀងទាត់ ប្រចាំខែ ត្រីមាស និងឆមាស។ អ្វីដែលគួរឱ្យចាប់អារម្មណ៍នោះ ការអធិការកិច្ចផ្ទៃក្នុង និងការប្រជុំបច្ចេកទេសបានអនុវត្តតាមផែនការ (១០-១១ដង) ហើយការប្រើប្រាស់ និងដំណើរការបន្ទប់ពិសោធន៍តាមផែនការមានចំនួនច្រើនជាង៩៥%។ ចំពោះចំនួនគ្រូបង្រៀនបានចូលរៀនវគ្គអភិវឌ្ឍសមត្ថភាពជាប្រចាំគឺបានបណ្តុះបណ្តាលលើសពី៣ឆ្នាំមកហើយ។ បន្ថែមទៅទៀត ចំនួនគ្រូបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រទាំង៤ និងបរិវច្ឆការី ទទួលបានការបណ្តុះបណ្តាលការប្រើប្រាស់បន្ទប់ពិសោធន៍ និងសៀវភៅណែនាំពិសោធន៍ ហើយនិងចំនួនគ្រូបង្រៀនបានចូលរួមអនុវត្ត

ប្រព័ន្ធគ្រប់គ្រងការអនុវត្តការងាររបស់គ្រូបង្រៀនគឺមានចំនួនច្រើនជាង៩៥%។ ចំពោះនាយកសាលា និងនាយករងទាំងអស់គឺបានចូលរួមអនុវត្តប្រព័ន្ធគ្រប់គ្រងការអនុវត្តការងាររបស់នាយកសាលា ហើយស្វ័យវាយតម្លៃសាលារៀននៅចុងឆ្នាំសិក្សាបានអនុវត្ត និងបានរៀបចំរបាយការណ៍ហិរញ្ញវត្ថុតាមការណែនាំជារៀងរាល់ឆ្នាំ។ ពិសេសជាងនេះទៅទៀតនោះគឺ ទិន្នន័យជឿជាក់ បានផលិត ប្រើប្រាស់ និងបិទផ្សាយជាសាធារណៈតាមការណែនាំ ហើយកម្មវិធីអប់រំមាតាបិតា និងគ្រូបង្រៀនទប់ស្កាត់អំពើហិង្សានៅផ្ទះនិងសាលារៀនបានរៀបចំតាមការណែនាំ ព្រមទាំងការពិនិត្យស្វែងរកសិស្សខ្សោយគំហើញ និងស្តាប់បានអនុវត្តទៀងទាត់រាល់ដើមឆ្នាំសិក្សា។

| *តារាង ៤.៤* **ស្តង់ដាទី៤ ដំណើរប្រតិបត្តិការ និងរដ្ឋបាលសាលារៀន** | | |
|---|---|---|
| | **ខ្លឹមសារ** | **ចម្លើយ** |
| ៤៦ | ផែនការសមិទ្ធកម្មអនុវត្តសូចនាករគន្លឹះរយៈពេលមធ្យមបានរៀបចំតាមការណែនាំ | រៀបចំឆ្នាំទី៤ |
| ៤៧ | ផលសម្រេចរយៈពេល ៣ឆ្នាំ និងផែនការបង្រៀន រយៈពេល ៣ឆ្នាំបានរៀបចំតាមការណែនាំ | រៀបចំឆ្នាំទី៤ |
| ៤៨ | ផែនការកែលម្អសាលារៀនបានរៀបចំតាមការណែនាំ | រៀបចំឆ្នាំទី៤ |
| ៤៩ | ការធ្វើតេស្តស្តង់ដាប្រចាំខែ និងត្រីមាសបានរៀបចំទៀងទាត់ | ទាំងអស់ |
| ៥០ | លទ្ធផលតេស្តស្តង់ដាប្រចាំខែ បានប្រើប្រាស់ជួយដល់ការសិក្សារបស់សិសរៀនយឺត | ទៀងទាត់ឆ្នាំទី៤ |
| ៥១ | លទ្ធផលតេស្តចុងត្រីមាសបានយកប្រើប្រាស់ក្នុងការរៀបចំផែនការបង្រៀន៣ខែតាមថ្នាក់រៀន | ទៀងទាត់ឆ្នាំទី៤ |
| ៥២ | ការប្រជុំប្រចាំខែ ត្រីមាស និងឆមាសបានប្រជុំតាមការណែនាំ | បូកឆមាសទី២ |
| ៥៣ | ចំនួនដងអធិការកិច្ចផ្ទៃក្នុង និងការប្រជុំបច្ចេកទេសបានអនុវត្តតាមផែនការ | ១០-១១ |
| ៥៤ | ការប្រើប្រាស់ និងដំណើរការអគារធនធានតាមផែនការ | >៩៥% |
| ៥៥ | ចំនួនគ្រូបង្រៀនបានចូលរៀនវគ្គអភិវឌ្ឍសមត្ថភាពជាប្រចាំ | តាមគ្រោងឆ្នាំទី៣ |

| | | |
|---|---|---|
| ៥៦ | ចំនួនគ្រូបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រទាំង៤ និងបរិវច្ឆការី ទទួលបានការបណ្តុះបណ្តាលការប្រើប្រាស់បន្ទប់ពិសោធន៍ និងសៀវភៅណែនាំពិសោធន៍ | ≥៩៥% |
| ៥៧ | ចំនួនគ្រូបង្រៀនបានចូលរួមអនុវត្តប្រព័ន្ធគ្រប់គ្រងការអនុវត្តការងាររបស់គ្រូបង្រៀន | ≥៩៥% |
| ៥៨ | ចំនួននាយកសាលា និងនាយករង បានចូលរួម អនុវត្តប្រព័ន្ធគ្រប់គ្រងការអនុវត្តការងាររបស់នាយកសាលា | ទាំងអស់ |
| ៥៩ | ស្វ័យវាយតម្លៃសាលារៀននៅចុងឆ្នាំសិក្សាបានអនុវត្ត និងបានរៀបចំរបាយការណ៍ហិរញ្ញវត្ថុតាមការណែនាំ | អនុវត្តឆ្នាំទី៤ |
| ៦០ | ទិន្នន័យជឿជាក់ បានផលិត ប្រើប្រាស់ និងបិទផ្សាយសាធារណៈតាមការណែនាំ | អនុវត្តឆ្នាំទី៣ |
| ៦១ | កម្មវិធីអប់រំមាតាបិតា និងគ្រូបង្រៀនទប់ស្កាត់អំពើហិង្សានៅផ្ទះនិងសាលារៀនបានរៀបចំតាមការណែនាំ | អនុវត្តឆ្នាំទី៣ |
| ៦២ | ការពិនិត្យស្វែងរកសិស្សខ្សោយគំហើញ និងស្តាប់បានអនុវត្តទៀងទាត់រាល់ដើមឆ្នាំសិក្សា | អនុវត្តឆ្នាំទី៣ |

**តារាង ៤.៥** បកស្រាយពីការអនុវត្តស្តង់ដាទី៥។ ជាលទ្ធផលបានបង្ហាញឱ្យឃើញថា នាយក និងនាយករងសាលាទទួលការហ្វឹកហាត់អនុវត្តកម្មវិធីសាលារៀនគំរូតិចតួចណាស់ គឺចន្លោះពីចំនួនម្តងទៅពីរដងប៉ុណ្ណោះក្នុង១ឆ្នាំសិក្សា ដូចគ្នាទៅនឹងការទស្សនកិច្ចផ្តល់ការគាំទ្រពីមន្ទីរ អ.យ.ក ដែលបានអនុវត្តតាមផែនការ។ ចំពោះគ្រូបង្រៀនគឺបានទទួលការហ្វឹកហាត់ការបង្រៀនចម្រុះមុខវិជ្ជា (STEM) តាមផែនការជារៀងរាល់ឆ្នាំ។ យ៉ាងណាមិញ ការធ្វើទស្សនកិច្ចសិក្សាបានផ្តល់ការគាំទ្រពីក្រុមការងារថ្នាក់ជាតិ ហើយបានអនុវត្តតាមផែនការ។ ដោយឡែក ចំពោះការធ្វើទស្សនកិច្ចសិក្សាដែលផ្តល់ការគាំទ្រពីការិយាល័យអ.យ.ក បានអនុវត្តតាមផែនការ ពោលគឺមានចំនួន៣ទៅ៤ដង ក្នុង១ឆ្នាំ។ តែអ្វីដែលគួរឱ្យចាប់អារម្មណ៍នោះគឺ គ្រូបង្រៀនមិនដែលខ្វះនោះទេ ហើយនាយក និងនាយករងសាលាមានលក្ខណៈស្របតាមបទដ្ឋាន ដោយបានរៀបចំកាតរបាយការណ៍សាលារៀន បានផលិត និងបិទផ្សាយទៀងទាត់ជារៀងរាល់ឆ្នាំ។

| *តារាង ៤.៥* ស្តង់ដាទី៥ គណនេយ្យភាពថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិ | | |
|---|---|---|
| | ខ្លឹមសារ | ចម្លើយ |
| ៦៣ | ចំនួនដងនាយក និងនាយករងសាលាទទួលការហ្វឹកហាត់អនុវត្តកម្មវិធីសាលារៀនគំរូ | ១-២ |
| ៦៤ | ចំនួនដងគ្រូបង្រៀនបានទទួលការហ្វឹកហាត់ការបង្រៀនចម្រុះមុខវិជ្ជា (STEM) តាមផែនការ | តាមគ្រោងឆ្នាំទី៣ |
| ៦៥ | ចំនួនដងទស្សនកិច្ចផ្តល់ការគាំទ្រពីក្រុមការងារថ្នាក់ជាតិ បានអនុវត្តតាមផែនការ | ៣-៤ |
| ៦៦ | ចំនួនដងទស្សនកិច្ចផ្តល់ការគាំទ្រពីមន្ទីរ អ.យ.ក បានអនុវត្តតាមផែនការ | ១-២ |
| ៦៧ | ចំនួនដងទស្សនកិច្ចផ្តល់ការគាំទ្រពីការិយាល័យអ.យ.ក បានអនុវត្តតាមផែនការ | ៣-៤ |
| ៦៨ | ចំនួនគ្រូបង្រៀនខ្វះតាមមុខវិជ្ជាថយចុះតាមផែនការ | ០ |
| ៦៩ | ចំនួននាយក និងនាយករងសាលាស្របតាមបទដ្ឋាន | ស្របតាមបទដ្ឋាន |
| ៧០ | កាតរបាយការណ៍សាលារៀន បានផលិត និងបិទផ្សាយ | ផលិតនិងបិទផ្សាយឆ្នាំទី៣ |

## ៤.១.២ វិធីសាស្ត្រគ្រប់គ្រងបុគ្គលិករបស់នាយកសាលាវេស្ទើនអន្តរជាតិសាខាស្តេខៀម

សាលាវេស្ទើនអន្តរជាតិសាខាស្តេខៀមធ្វើផែនការយុទ្ធសាស្ត្រ៥ឆ្នាំ និងផែនការប្រត្តិបត្តិប្រចាំឆ្នាំ ដែលមានអ្នកចូលរួមដូចជាម្ចាស់ភាគហ៊ុន ក្រុមការងារបច្ចេកទេស ក្រុមការងារប្រតិបត្តិ និងក្រុមការងារហិរញ្ញវត្ថុ។ នាយកសាលាគឺជាអ្នកតំណាងម្ចាស់សាលាក្នុងការគ្រប់គ្រងការប្រតិបត្តិការនៅក្នុងសាលាទាំងមូល។ វិធីសាស្ត្រក្នុងការគ្រប់គ្រងគ្រូបង្រៀននៅក្នុងសាលាឱ្យបានល្អ គឺនាយកសាលាចាត់តាំងនាយករងឱ្យចុះអធិការកិច្ច តាមដានគ្រូផ្ទាល់ក្នុង១ឆ្នាំ២ដង រួចធ្វើរបាយការណ៍ជូននាយកសាលា។ ដោយសារនាយកសាលាមានកិច្ចការងារច្រើន នាយករងក៏ជាអ្នកត្រួតពិនិត្យការបង្រៀនរបស់គ្រូបង្រៀនជារៀងរាល់ថ្ងៃ តាមរយះកាំម៉េរ៉ានៅក្នុងថ្នាក់រៀនផងដែរ។ វិធីសាស្ត្រក្នុងការទាក់ទាញអ្នកអាណាព្យាបាលឱ្យបញ្ជូន

កូនមកសាលាវេស្ទើនអន្តរជាតិគឺគណៈគ្រប់គ្រងរៀបចំបញ្ចុះថ្លៃសិក្សា ផ្តល់អាហារូបករណ៍ ពង្រឹងគុណភាពគ្រូបង្រៀន ពិនិត្យមើលបរិស្ថាន អនាម័យ សន្តិសុខសណ្តាប់ធ្នាប់សាលា និងបណ្តុះបណ្តាលបុគ្គលិកឱ្យមានភាពរួសរាយរាក់ទាក់ទៅកាន់អ្នកអាណាព្យាបាលសិស្ស។ លើសពីនេះទៀត សាលាបានបង្កើតកម្មវិធីជាច្រើននៅក្នុងសាលា កម្មវិធីផ្លាស់ប្តូរការសិក្សាទៅក្រៅប្រទេស កម្មវិធីមនុស្សធម៌ និងការចូលរួមក្នុងសង្គមជាតិ។

## ៤.២ ការពិភាក្សាលើលទ្ធផលស្រាវជ្រាវ

សាលារៀនមួយចាត់ទុកថា ជាសាលារៀនដែលបំពេញបាននូវស្តង់ដាអប្បបរមាកម្មវិធីសាលារៀនគំរូ លុះត្រាតែសាលារៀននោះមានពិន្ទុសរុបលើការអនុវត្តស្តង់ដាទាំង៥យ៉ាងតិច ២១៣ ដោយស្តង់ដានីមួយៗគ្មានស្តង់ដាណាមួយ ដែលមិនបំពេញបាននូវពិន្ទុអប្បបរមាផងដែរ។ ក្នុងករណី សាលាមួយដែលមានពិន្ទុសរុប ២១៣ ឬ លើសនេះ តែមានស្តង់ដាណាមួយមិនមានពិន្ទុអប្បបរមា នោះមិនចាត់ទុកថាសាលាជាប់ស្តង់ដាអប្បបរមាសាលារៀនគំរូនោះឡើយ។

| ពិន្ទុ/ស្តង់ដា | ស្តង់ដាទី១ | ស្តង់ដាទី២ | ស្តង់ដាទី៣ | ស្តង់ដាទី៤ | ស្តង់ដាទី៥ | សរុបពិន្ទុ |
|---|---|---|---|---|---|---|
| ពិន្ទុអប្បបរិមា | ៣៩ | ៥៧ | ៤២ | ៥១ | ២៤ | ២១៣ |

### ៤.២.១ ស្តង់ដាទី១

លទ្ធផលស្រាវជ្រាវក្នុងតារាងទី៤.១ ដែលមាន១២សូចនាករបានបង្ហាញថា សាលាវេស្ទើនអន្តរជាតិសាខាស្តេចឡៀមទទួលបានពិន្ទុសរុបចំនួន ៤២ពិន្ទុ គឺលើសពិន្ទុអប្បបរិមាកំណត់ ៣ពិន្ទុ នៃស្តង់ដាទី១ ពីព្រោះ៖

- ចំនួនសិស្សចូលរៀនច្រើន
- អត្រាសិស្សបោះបង់តិច
- ភាគរយសិស្សឡើងថ្នាក់ខ្ពស់

### ៤.២.២ ស្តង់ដាទី២

លទ្ធផលស្រាវជ្រាវក្នុងតារាងទី៤.២ ដែលមាន១៩សូចនាករបានបង្ហាញថា សាលាវេស្ទើនអន្តរជាតិសាខាស្ពេខៀមទទួលបានពិន្ទុសរុបចំនួន ៥៩ពិន្ទុ គឺលើសពិន្ទុអប្បបរិមាកំណត់ ២ពិន្ទុ នៃស្តង់ដាទី២ ពីព្រោះ៖

- មានផែនការបង្រៀនប្រចាំឆ្នាំ និងបំណែងចែកកម្មវិធីសិក្សាតាមមុខវិជ្ជា
- មានផែនការបង្រៀន៣ខែ, មានការប្រជុំពិនិត្យតាមដានការរៀនសូត្រទៀងទាត់
- គ្រូមានចំនួនគ្រប់គ្រាន់ ហើយសិស្សអវមានតិច

### ៤.២.៣ ស្តង់ដាទី៣

លទ្ធផលស្រាវជ្រាវក្នុងតារាងទី៤.៣ ដែលមាន១៤សូចនាករបានបង្ហាញថា សាលាវេស្ទើនអន្តរជាតិសាខាស្ពេខៀមទទួលបានពិន្ទុសរុបចំនួន ៥៣ពិន្ទុ គឺលើសពិន្ទុអប្បបរិមាកំណត់ ១១ពិន្ទុ នៃស្តង់ដាទី៣ ពីព្រោះ៖

- មានការប្រជុំប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំទៀងទាត់
- មានការវាយតម្លៃការអនុវត្តការងារប្រចាំឆ្នាំទៅលើនាយក នាយករង
- មានរបាយការណ៍វាយតម្លៃស្តង់ដាសាលារៀន
- មានរបាយការណ៍ប្រចាំឆ្នាំអនុម័តដោយគណៈកម្មការគ្រប់គ្រងសាលារៀន

### ៤.២.៤ ស្តង់ដាទី៤

លទ្ធផលស្រាវជ្រាវក្នុងតារាងទី៤.៤ ដែលមាន១៧សូចនាករបានបង្ហាញថា សាលាវេស្ទើនអន្តរជាតិសាខាស្ពេខៀមទទួលបានពិន្ទុសរុបចំនួន ៦៨ពិន្ទុ គឺលើសពិន្ទុអប្បបរិមាកំណត់ ១៧ពិន្ទុ នៃស្តង់ដាទី៤ ពីព្រោះ៖

- មានផែនការកែលម្អសាលារៀនដែលបានរៀបចំតាមការណែនាំ
- មានការប្រជុំប្រចាំខែ ត្រីមាស និងឆមាសតាមការណែនាំ
- មានការធ្វើអធិការកិច្ចផ្ទៃក្នុង និងការប្រជុំបច្ចេកទេស

- មានស្វ័យវាយតម្លៃសាលារៀននៅចុងឆ្នាំសិក្សា

### ៤.២.៥ ស្តង់ដាទី៥

លទ្ធផលស្រាវជ្រាវក្នុងតារាងទី៤.៥ ដែលមាន៨សូចនាករបានបង្ហាញថា សាលារេស្មីនអន្តរជាតិសាខាស្តេខៀមទទួលបានពិន្ទុសរុបចំនួន ២២ពិន្ទុ គឺក្រោមពិន្ទុអប្បបរិមាកំណត់ ២ពិន្ទុ នៃស្តង់ដាទី៥ ពីព្រោះ៖

- កង្វះការហ្វឹកហាត់អនុវត្តកម្មវិធីសាលារៀនគំរូ
- ការទស្សនកិច្ចផ្តល់ការគាំទ្រពីការិយាល័យអ.យ.ក បានអនុវត្តតាមផែនការមានចំនួនតិចដង

សរុបមកពិន្ទុនៃសាលារេស្មីនអន្តរជាតិសាខាស្តេខៀមគឺទទួលបាន ២៤៤ពិន្ទុ។ តាមគោលការណ៍ សាលារៀនមួយចាត់ទុកថាបំពេញបាននូវស្តង់ដាអប្បបរមាកម្មវិធីសាលារៀនគំរូ លុះត្រាតែសាលារៀននោះមានពិន្ទុសរុបយ៉ាងតិច ២១៣ពិន្ទុ ហើយគ្មានស្តង់ដាណាមួយបានពិន្ទុទាបជាងពិន្ទុអប្បបរមាកំណត់។ នេះអាចនិយាយបានថាសាលារេស្មីនអន្តរជាតិសាខាស្តេខៀមមិនបានជាប់ជាសាលាស្តង់ដាគំរូនោះទេ បើទោះបីសាលានេះបានទទួលពិន្ទុសរុបលើសពីស្តង់ដាអប្បបរមាកំណត់រហូតដល់៣១ពិន្ទុក៏ដោយព្រោះមានស្តង់ដាទី៥មួយដែលសាលានេះអនុវត្តបានក្រោមស្តង់ដាអប្បបរមា។ តែទោះជាយ៉ាងនេះក៏ដោយ ក៏សាលានេះមានឧត្តមានុវត្តជាច្រើនដែលអាចឱ្យសាលាដទៃៗទៀតរៀនសូត្រតាម ពិសេសលើរបៀបនៃការអនុវត្តស្តង់ដាទី១ទី២ទី៣ និងទី៤លើគ្រប់សូចនាករ។

# ជំពូក៥

# សេចក្តីសន្និដ្ឋាន និង សំណូមពរ

# ជំពូក៥

# សេចក្តីសន្និដ្ឋាន និងសំណូមពរ

ជំពូកនេះ បង្ហាញពីសេចក្តីសន្និដ្ឋាន និងសំណូមពរ។ ក្នុងសេចក្តីសន្និដ្ឋាន អ្នកស្រាវជ្រាវនឹងបង្ហាញពីខ្លឹមសារសង្ខេបលើលទ្ធផលស្រាវជ្រាវសំខាន់ៗ រីឯសំណូមពរ អ្នកស្រាវជ្រាវនឹងលើកឡើងពីចំណុចគួរពង្រឹងបន្ថែមនៅក្នុងសាលាវេស្ទើនអន្តរជាតិរបស់សាខាស្តេខៀម។

## ៥.១ សេចក្តីសន្និដ្ឋាន

ការសិក្សាស្រាវជ្រាវនេះគឺមានគោលបំណងសិក្សាស្វែងយល់ពីឧត្តមានុវត្តនៃការដឹកនាំនិងគ្រប់គ្រងបុគ្គលិករបស់នាយកសាលាវេស្ទើនអន្តរជាតិ របៀបប្រើប្រាស់វិធីសាស្ត្រក្នុងការគ្រប់គ្រងគ្រូបង្រៀន និងទាក់ទាញអ្នកអាណាព្យាបាលសិស្សឱ្យបញ្ជូនកូនមកសិក្សានៅសាលាវេស្ទើនអន្តរជាតិសាខាស្តេខៀម។

លទ្ធផលស្រាវជ្រាវបានបង្ហាញថា សាលារៀនមានដំណើរការសម្រេចផលសម្រេចនៃការអប់រំ និងការសិក្សារបស់សិស្ស បានល្អដែលធ្វើឱ្យសិស្សជាប់ច្រើនហើយទទួលបាននិទ្ទេសល្អ សិស្សមានការបោះបង់ការសិក្សាតិច។ ថ្នាក់រៀនដំណើរការសម្រាប់ការបង្រៀន និងការសិក្សារៀនសូត្ររបស់សិស្សម្នាក់ៗល្អ ដោយសារសាលារៀនមានផែនការបង្រៀនប្រចាំឆ្នាំ មានបំណែងចែកកម្មវិធីសិក្សាបង្រៀនច្បាស់លាស់ មានកាលវិភាគលម្អិតតាមមេរៀន ហើយគ្រូនិងសិស្សរៀននិងបង្រៀនបានច្រើនម៉ោង។ ចំពោះភាពជាម្ចាស់នៃសហគមន៍សាលារៀន ដំណើរប្រតិបត្តិ និងការងាររដ្ឋបាលសាលារៀនមានលក្ខណៈល្អប្រសើរខ្លាំងដែលធ្វើឱ្យអ្នកអាណាព្យាបាលសិស្សជឿជាក់លើកេរ្តិ៍ឈ្មោះរបស់សាលាវេស្ទើនអន្តរជាតិ។ តែទោះ ជាយ៉ាងនេះក៏ដោយ គណនេយ្យភាពថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិរបស់សាលារៀន នៅមានកម្រិតគួរឱ្យកត់សម្គាល់នៅឡើយ ដោយសារតែនាយក នាយករងសាលាទទួលការហ្វឹកហាត់លើការអនុវត្តកម្មវិធីសាលារៀនគំរូនៅមានចំនួនតិចដង ហើយការទស្សនកិច្ចដែលផ្តល់ការគាំទ្រពីមន្ទីរ អ.យ.ក មានចំនួនមិនច្រើនដង។

សរុបមកការសិក្សានេះបានផ្តល់នូវអត្ថប្រយោជន៍ជាច្រើនដល់ការគ្រប់គ្រងរបស់ថ្នាក់ដឹកនាំសាលានិង វិធីសាស្ត្រល្អៗក្នុងការទាក់ទាញអ្នកអាណាព្យាបាលឱ្យបញ្ជូនកូនមកសាលារៀន។

## ៥.២ សំណូមពរ

ការសិក្សានេះបានសិក្សា និងស្វែងយល់ពីឧត្តមានុវត្តនៃការដឹកនាំ និងគ្រប់គ្រងរបស់នាយកសាលាវេស្ទើនអន្តរជាតិនៅសាខាស្តៅឡៀម ដើម្បីចង់ដឹងពីបទពិសោធន៍ល្អៗដែលបានប្រើកន្លងមក ដោយការសង្កេតឃើញថា សាលាវេស្ទើនអន្តរជាតិពិតជាមានកំណើនសិស្សកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំដោយសារតែភាពល្បីល្បាញរបស់សាលា និងការប្រតិ បត្តិរបស់គណៈគ្រប់គ្រង។ លើសពីនេះទៅទៀតគ្រូបង្រៀនមានគរុកោសល្យត្រឹមត្រូវ មានឆន្ទៈមនសិការ ក្នុងការបង្រៀនសិស្សច្បាស់លាស់ ធ្វើឱ្យសិស្សដែលចូលរៀននៅសាលានេះភាគច្រើនទទួលបានវិជ្ជាសម្បទា បំណិនសម្បទា និងចរិយា សម្បទាពេញលេញ សម្រាប់ក្លាយទៅជាពលរដ្ឋល្អ និងជាពលរដ្ឋសកល។ ទោះជាយ៉ាងនេះក៏ដោយ សាលាវេស្ទើនអន្តរជាតិក៏គួរតែគិតគូរបន្ថែមក្នុងការរៀបចំបណ្ណាល័យឱ្យសិស្សអានទៀងទាត់។ នាយក នាយករងគួរតែទទួលបានការហ្វឹកហាត់អនុវត្តកម្មវិធីសាលារៀនគំរូឱ្យបានច្រើនដង។ ការធ្វើទស្សនកិច្ចសិក្សាដែលផ្តល់ការគាំទ្រពីក្រុមការងារថ្នាក់ជាតិក៏ដូចជាទស្សនកិច្ចសិក្សាដែលផ្តល់ការគាំទ្រពីការិយាល័យអ.យ.ក គួរតែមានច្រើនដង ដើម្បីពង្រឹងសមត្ថភាពអ្នកគ្រប់គ្រងនិងគ្រូបង្រៀនបន្ថែមទៀត ហើយសាលាគួរតែរៀបចំផែនការថវិកាដោយដាក់បញ្ចូលនូវសកម្មភាពទាំងនេះរៀងរាល់ឆ្នាំ។

ការសិក្សានេះ នៅមានចំណុចខ្វះខាតដែលត្រូវបំពេញបន្ថែម។ ដើម្បីឱ្យមានភាពច្បាស់លាស់ ស្នើអ្នកស្រាវជ្រាវជំនាន់ក្រោយៗធ្វើការស្រាវជ្រាវបន្ថែម លើឧត្តមានុវត្តនៃការដឹកនាំ និងគ្រប់គ្រងរបស់នាយកសាលាវេស្ទើនអន្តរជាតិសាខាស្តៅឡៀម និងសូមពង្រីកឱ្យដល់គ្រប់សាខាទាំងអស់។

# ឯកសារយោង

- ក្រសួងអបរំ យុវជន និងកីឡា (២០២៣), ការសម្រេចអាទិភាពនៃកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡា សម្រាប់ឆ្នាំ( ២០២៣-២០២៨) ភ្នំពេញ
- ក្រសួងអបរំ យុវជន និងកីឡា (២០១៧), ស្តង់ដានាយកសាលារៀន ,នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ,២០១៧ ភ្នំពេញ
- ក្រសួងអបរំ យុវជន និងកីឡា (២០១៦), ការងារគ្រប់គ្រងនិងភាពជាអ្នកដឹកនាំ, នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ,២០១៦ ភ្នំពេញ
- ក្រសួងអបរំ យុវជន និងកីឡា (២០១៤), ផែនការយុទ្ធសាស្ត្រវិស័យអប់រំ( ២០១៤-២០១៨) ភ្នំពេញ
- ក្រសួងអបរំ យុវជន និងកីឡា (២០១០), ស្តង់ដាសមត្ថភាពនាយកសាលាគរុកោសល្យ
- SEAMEO INNOTECH, (2016) *Success competencies of Southeast Asian School Heads: a learning Guide (Khmer Translation)* Quezon City: SEAMEO INNOTECH. License: Creative Commons CC-BY-NC-SA 3.0 IGO
- Beatriz P., Deborah N., and Hunter M., (2008) *Improving School Leadership*: *VOLUME 1: POLICY AND PRACTICE.* Organization for Economic Co-operation and Development (OEC*)*, 2008
- Blase, J., & Blase, J. (1999*). Effective Instructional Leadership*: Teachers' Perspectives on How Principals Promote Teaching and Learning in School. *Journal of Educational Administration*, 130-141.
- Bredeson, P. V. (2000). The School Principal’s Role in Teacher Professional Development, Journal of In-Service Education, 26, 385-401
- Enueme, C. P., & Egwunyenga, E. J. (2008). *Principals' instructional leadership roles and effect on teachers' job performance*: A case study of secondary schools in Asaba Metropolis, Delta Sate, Nigeria.

- Hoy, W. K., & Miskel, C. G. (2008). *Educational Administration: Theory, Research and Practice.*
  New York: The McGraw-Hill Companies, Inc.,.
- Leithwood, K.,(2010).*Leading School Turnaound*. San Francisco, USA.
- O'Neil, S. (2009). *Basic Statistics for the utterly confused*. Pretoria, South Africa: University of
  Pretoria.
- Salleh, M. J., & Hatta, M. (2001). *The Relationship Between Instructional Leadership Practices
  and Students Academic Achievement of Secondary Schools*. Banda Aceh, Indonesia. 2nd Regional Conference on Educational Leadership and Management.
- Sallis, E. (2005). *Total Quality Management in Education* (3rd Ed.). London: Kogan Page Ltd.
- UNESCO. (2011). *UNESCO and Education: Everyone has the right to education.* Paris: United Nations Educational, Scientific and Cultural Organization.
- UNESCO. (2015). *Education for All 2000-2015: Achievement and Challenges.* Paris: United Nations Educational, Scientific and Cultural Organization.
- https://hslcorner.files.wordpress.com/2019/03/7.190325-e19e94e19e91e2808be19e94e19e84e19f92e19ea0e19eb6e19e89e2808be19e9fe19f92e19e8ae19eb8e2808be19e96e19eb8e19f96-e19e80e19eb6e19e9ae2808be19e82e19f92e19e9ae19e94e19f8be2808be19e82e1.pdf
- http://cpd.moeys.gov.kh/documents/1635842306_school_director_standards_final_combination_khmer.pdf
- https://www.mediafire.com/file/rygvqnibgqqztxb/Second_Edit_on_20_05_2017Presentation.pdf/file?fbclid=IwAR2Sx6SFDOcyqfM5teYeO1uCTt0IQIq33r7O11oyomo8ay3TOf5IRjtWsIY
- https://www.seameo-innotech.org/wp-content/uploads/2018/04/Comptency-Framework-Guidebook-Khmer-Final-version.pdf

# ឧបសម្ព័ន្ធទី១ លិខិតបង្គាប់ការ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

វិទ្យាស្ថានជាតិអប់រំ
លេខ : ៤៨០.....ឧជអ. លក

## លិខិតបង្គាប់ការ

យោង៖ - លិខិតឧទ្ទេសនាមលេខ៨៤៧៣ អយក.ឧទន ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៣ ស្តីពីគណៈកម្មការមេប្រយោគ សម្រាប់ការការពារនិក្ខេបបទស្រាវជ្រាវបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០។

- លិខិតឧទ្ទេសនាមលេខ៨៥០១ អយក. ឧទន ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៣ ស្តីពីគណៈកម្មការការពារនិក្ខេបបទស្រាវជ្រាវបញ្ចប់ ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០។
- លិខិតឧទ្ទេសនាមលេខ៨៤៧៤ អយក. ឧទន ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៣ ស្តីពី គណៈកម្មការរៀបចំ សម្រាប់ការការពារនិក្ខេបបទស្រាវជ្រាវបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០។
- លិខិតឧទ្ទេសនាមលេខ៨៤៧៦ អយក. ឧទន ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៣ ស្តីពី គណៈកម្មការគណនេយ្យ និងសម្ភារៈ សម្រាប់ការការពារនិក្ខេបបទស្រាវជ្រាវបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០។
- លិខិតឧទ្ទេសនាមលេខ៨៤៧៥ អយក. ឧទន ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៣ ស្តីពី គណៈកម្មការកណ្តាល សម្រាប់ការការពារនិក្ខេបបទស្រាវជ្រាវបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០។

បុគ្គលិកអប់រំនៃក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការការពារនិក្ខេបបទ** សម្រាប់និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី៨-៩ ខែធ្នូ ឆ្នាំ២០២៣ ចាប់ពីម៉ោង ០៨:០០នាទីព្រឹក នៅវិទ្យាស្ថានជាតិអប់រំ៖

I. **គណៈកម្មការការពារនិក្ខេបបទ**

**ក្រុមទី១ នៅអគារ** B07 **បន្ទប់** 101

| **គោត្តនាម និងនាម** | | **អង្គភាព** | **តួនាទី** |
|---|---|---|---|
| ១- ឯកឧត្តមបណ្ឌិត | ឌី ខាំបូលី | វិទ្យាស្ថានជាតិអប់រំ | ប្រធាន |
| ២- លោកស្រីបណ្ឌិត | បូ ច័ន្ទគុលិកា | នាយកដ្ឋានគោលនយោបាយ | សមាជិកា |
| ៣- លោកបណ្ឌិត | ឈាង សង្វាត | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៤- លោក | ម៉ន មុនិន្ទ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

| | | | |
|---|---|---|---|
| ៥- លោកស្រី | នូ ចន្នី | វិទ្យាស្ថានជាតិអប់រំ | សមាជិកា |
| ៦- លោកបណ្ឌិត | ឈន ថន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៧-លោក | លន លីណា | វិទ្យាស្ថានជាតិអប់រំ | លេខា |

**ក្រុមទី២ នៅអគារ** B07 **បន្ទប់** 105

| | | | |
|---|---|---|---|
| ១- ឯកឧត្តមបណ្ឌិត | សៀង សុវណ្ណា | វិទ្យាស្ថានជាតិអប់រំ | ប្រធាន |
| ២- ឯកឧត្តមបណ្ឌិត | ប៉ិច សៀង | វិទ្យាស្ថានបច្ចេកវិទ្យាកំពង់ឈើទាល | សមាជិក |
| ៣- លោកបណ្ឌិត | ម៉ម ចាន់សៀន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៤- លោក | ម៉ៅ សារឿន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៥- លោកបណ្ឌិត | គួយ សុគាន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៦- លោកបណ្ឌិត | ទៀង សោកទ្រា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៧- កញ្ញា | យុន គឹមរៀង | វិទ្យាស្ថានជាតិអប់រំ | លេខា |

**ក្រុមទី៣ នៅអគារ** B07 **បន្ទប់** 107

| | | | |
|---|---|---|---|
| ១- លោក | ឌី បុណ្ណា | វិទ្យាស្ថានជាតិអប់រំ | ប្រធាន |
| ២- លោកបណ្ឌិត | អែ សុងហ៊ាង | មជ្ឈមណ្ឌល SEAMEO TED | សមាជិក |
| ៣- លោកបណ្ឌិត | កាន់ ពុទ្ធី | នាយកដ្ឋានបឋមសិក្សា | សមាជិក |
| ៤- លោកស្រី | សាំង សុចិន្តា | វិទ្យាស្ថានជាតិអប់រំ | សមាជិកា |
| ៥- លោកស្រីបណ្ឌិត | ឡឹយ សុគា | វិទ្យាស្ថានជាតិអប់រំ | សមាជិកា |
| ៦- លោកបណ្ឌិត | អាន រ៉ូប្រាវ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៧- កញ្ញា | យុន ស៊ីណូត | វិទ្យាស្ថានជាតិអប់រំ | លេខា |

**ក្រុមទី៤ នៅអគារ** B07 **បន្ទប់** 109

| | | | |
|---|---|---|---|
| ១- លោក | ថៃ ហេង | វិទ្យាស្ថានជាតិអប់រំ | ប្រធាន |
| ២- លោកបណ្ឌិត | លី គឹមឡុង | សាកលវិទ្យាល័យភូមិន្ទភ្នំពេញ | សមាជិក |
| ៣- លោកបណ្ឌិត | មាឃ ចាន់ថេង | នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ | សមាជិក |
| ៤- លោកបណ្ឌិត | សោន វណ្ណៈ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៥- លោកបណ្ឌិត | ទី សុផល | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៦- លោក | ឡុប ចាន់ថន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៧- កញ្ញា | ណុច ស្រីនាង | វិទ្យាស្ថានជាតិអប់រំ | លេខា |

**ក្រុមទី៥ នៅអគារ** B07 **បន្ទប់** 110

| | | | |
|---|---|---|---|
| ១- ឯកឧត្តមបណ្ឌិត | ជ័យ សារិន | អគ្គាធិការដ្ឋាន | ប្រធាន |
| ២- លោកបណ្ឌិត | ឈូក ច័ន្ទធាយា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៣- លោកស្រី | ប៊ុន សុផានី | វិទ្យាស្ថានជាតិអប់រំ | សមាជិកា |
| ៤- លោកបណ្ឌិត | នី រដ្ឋា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៥- លោកបណ្ឌិត | សឿង សុផា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

| | | | |
|---|---|---|---|
| ៦- លោក | លឹម វ៉ាន់ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៧- លោក | ចាន់ ធឿន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៨- កញ្ញា | ភាព សុខនី | វិទ្យាស្ថានជាតិអប់រំ | លេខា |

**ក្រុមទី៦ នៅ** B07 **បន្ទប់** 111

| | | | |
|---|---|---|---|
| ១- លោកបណ្ឌិត | នូវ វីរ៉ា | វិទ្យាស្ថានជាតិអប់រំ | ប្រធាន |
| ២- ឯកឧត្តមបណ្ឌិត | សិត សេង | វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ | សមាជិក |
| ៣- លោក | ចាប រតនា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៤- លោកបណ្ឌិត | អ៊ឹម គឿន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៥- លោក | ចាន់ រ៉ាដា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៦- លោកស្រី | សុខ វណ្ណា | វិទ្យាស្ថានជាតិអប់រំ | លេខា |

II. **គណៈកម្មការកណ្ដាល** B07 **បន្ទប់** 103

| | | | |
|---|---|---|---|
| ១- លោកស្រី | ធុក ផល្លីនី | វិទ្យាស្ថានជាតិអប់រំ | ប្រធាន |
| ២- លោក | ប៉ូ ប៊ុន្នួន | វិទ្យាស្ថានជាតិអប់រំ | ធ្វើកំណត់ហេតុ |
| ៣- លោកស្រី | ទៀប ច័ន្ទវត្តី | វិទ្យាស្ថានជាតិអប់រំ | រៀបចំជាប់/ធ្លាក់ |
| ៤- កញ្ញា | ឈឹន លីន | វិទ្យាស្ថានជាតិអប់រំ | យកវត្តមាន |
| ៥- លោកស្រី | ម៉ម ចំប៉ី | វិទ្យាស្ថានជាតិអប់រំ | បូកពិន្ទុ/ផ្ទៀងផ្ទាត់ |

III. **គណៈកម្មការរដ្ឋបាល និងគណនេយ្យ**

| | | | |
|---|---|---|---|
| ១- លោក | គិន កោសល្ល | តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ប្រធាន |
| ២- លោក | ឡេង បូរី | វិទ្យាស្ថានជាតិអប់រំ | រៀបចំបន្ទប់/សម្ភារៈ |
| ៣- លោកស្រី | អ៊ុំ សុចិន្តា | វិទ្យាស្ថានជាតិអប់រំ | រៀបចំហិរញ្ញវត្ថុ |
| ៤- លោក | អ៊ុច ផលរដ្ឋ | វិទ្យាស្ថានជាតិអប់រំ | យកវត្តមាន |

ថ្ងៃ ច័ន្ទ ៩រោច ខែ កត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ៦ ខែ វិ ឆ្នាំ២០២៣

**នាយកវិទ្យាស្ថានជាតិអប់រំ**

បណ្ឌិត.សៀង សុវណ្ណា

**បានឃើញ និងឯកភាព**

**ប្រធានគណៈកម្មាធិការកំណែទម្រង់**

បណ្ឌិត ឌី_ខាំបូលី

**កន្លែងទទួល៖**

- ការិយាល័យ/ដេប៉ាតឺម៉ង់នៃ វជអ ដែលពាក់ព័ន្ធ
  "ដើម្បីជ្រាបជាព័ត៌មាន"
- សាមីជន "ដើម្បីអនុវត្ត"
- កាលប្បវត្តិ
- ឯកសារ.វជអ

3

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**លេខ ០៤៥០១ អយក.ឧមន**

(**ការសម្ងាត់**)

## លិខិតឧទ្ទេសនាម
## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

**យោង៖** - បទប្បញ្ញត្តិស្តីពីការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។
- ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០ ឆ្នាំសិក្សា២០២២-២០២៣ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២។
- សំណើសុំដូរកាលបរិច្ឆេទរៀបចំការការពារនិក្ខេបបទស្រាវជ្រាវបញ្ចប់ការសិក្សារបស់និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០ ឆ្នាំសិក្សា២០២២-២០២៣ នៅវិទ្យាស្ថានជាតិអប់រំ។

បុគ្គលិកអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការការពារនិក្ខេបបទស្រាវជ្រាវបញ្ចប់** ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី០៨-០៩ ខែធ្នូ ឆ្នាំ២០២៣ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | |
|---|---|---|
| ១. ឯកឧត្តមបណ្ឌិត ជ័យ សារិន | អគ្គាធិការដ្ឋាន | ប្រធាន |
| ២. លោកស្រីបណ្ឌិត បូ ច័ន្ទគុលិកា | នាយកដ្ឋានគោលនយោបាយ | អនុប្រធាន |
| ៣. លោកបណ្ឌិត កាន់ ពុទ្ធី | នា.បឋមសិក្សា អយក. | សមាជិក |
| ៤. លោក ម៉ៅ សារឿន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៥. លោកស្រី សាំង សុចិន្តា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៦. លោកបណ្ឌិត មាយ ចាន់ថេង | នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ | សមាជិក |
| ៧. លោកបណ្ឌិត អែ សុងហ៊ាង | SEAMEO TED អយក | សមាជិក |
| ៨. ឯកឧត្តមបណ្ឌិត ប៉ិច សៀង | វិ.បច្ចេកវិទ្យាកំពង់ឈើទាល | សមាជិក |
| ៩.លោកបណ្ឌិត លី គឹមឡុង | សាកលវិទ្យាល័យភូមិន្ទភ្នំពេញ | សមាជិក |
| ១០.លោក ចាប រតនា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១១.លោក លឹម វ៉ាន់ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១២. លោកបណ្ឌិត អាន វ៉ូប្រាវ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៣. លោកស្រី នូ ចន្ទី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៤. លោកស្រី បណ្ឌិត ឡឹយ សុខគា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៥. លោកបណ្ឌិត អ៊ឹម គឿន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៦. លោកបណ្ឌិត ទី សុផល | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៧. លោកបណ្ឌិត គួយ សុគាន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៨. លោកបណ្ឌិត សោន វណ្ណៈ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៩. លោកបណ្ឌិត ឈន ថន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២០. លោកបណ្ឌិត សឿង សុផា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២១. លោក ចាន់ ធឿន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

| | | |
|---|---|---|
| ២២. លោកបណ្ឌិត សោភទ្រា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៣. លោក ឡុច ចាន់ថន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៤. លោក ចាន់ រ៉ាដា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

លោក និងលោកស្រី ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារនិក្ខេបបទរបស់និស្សិត នៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២៣ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅ នៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃព្រហស្បតិ៍ ៣រោច ខែ កត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០២៣

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**

- អគ្គនាយកដ្ឋានរ.ហ អគ្គនាយកដ្ឋានឧស.
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី
- គ្រប់អង្គភាពក្រោមឱវាទអយកដែលមានការពាក់ព័ន្ធ "ដើម្បីជ្រាបជាព័ត៌មាន"
- សាមីខ្លួន " ដើម្បីអនុវត្ត "
- កាលប្បវត្តិ
- ឯកសារៈ វិទ្យាស្ថានជាតិអប់រំ

# ឧបសម្ព័ន្ធទី២ លិខិតចាត់តាំងគ្រូដឹកនាំ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ: ៣៤៧៣ អយក.ឧទ

## លិខិតឧទ្ទេសនាម

យោង៖ ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០ ឆ្នាំសិក្សា ២០២២-២០២៣ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២។

បុគ្គលិកអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជាគ្រូណែនាំគោល និងគ្រូណែនាំរង សម្រាប់ការសរសេរនិក្ខេបបទរបស់និស្សិតបង់ថ្លៃសេវាសិក្សា ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី១០ ឆ្នាំសិក្សា២០២២-២០២៣ ដែលបានទទួលការបណ្តុះបណ្តាលនៅវិទ្យាស្ថានជាតិអប់រំ៖

| ល.រ | គោត្តនាម-នាម គ្រូណែនាំគោល | គោត្តនាម-នាម គ្រូណែនាំរង | គោត្តនាម-នាម និស្សិត |
|---|---|---|---|
| ១ | លោក ម៉ៅ សារឿន | បណ្ឌិត អាន វ៉ូប្រាវ | គៀត គឹក |
| ២ | បណ្ឌិត សៀង សុវណ្ណា | លោក ម៉ៅ សារឿន | ឌី ភារុន |
| ៣ | បណ្ឌិត គួយ សូគាន | បណ្ឌិត ទៀង សោភទ្រា | ប៉ែន បារាំង |
| ៤ | លោក ម៉ន មុនិន្ទ | បណ្ឌិត ឈាង សង្វាត | រស់ វដ្ឋា |
| ៥ | បណ្ឌិត នី វដ្ឋា | បណ្ឌិត សិត សេង | លឿង កុសល |
| ៦ | បណ្ឌិត ឈន ថន | លោក ចាន់ ធឿន | វ៉ាន់ ចាន់វ៉ាត |
| ៧ | បណ្ឌិត សោន វណ្ណៈ | លោកស្រី សាំង សុចិន្តា | សន សុភារ៉ា |
| ៨ | បណ្ឌិត មាឃ ចាន់ថេង | បណ្ឌិត អែ សុងហ៊ាង | សុខ កែវរតនា |
| ៩ | លោក ថៃ ហេង | បណ្ឌិត នូវ វីរ៉ា | សេង សាដាត់ |
| ១០ | បណ្ឌិត ឈាង សង្វាត | លោកស្រី នូ ចន្នី | ហុង លក្ខិណា |
| ១១ | បណ្ឌិត សឿង សុផា | បណ្ឌិត ម៉ម ចាន់សៀន | អ៊ុក រតនា |

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

ឯកឧត្តម លោក លោកស្រី ដូចមាននាមខាងលើ ត្រូវទទួលភារកិច្ចអនុវត្តការងារឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ ព្រហ ៥កើត ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែតុលា ឆ្នាំ២០២៣

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**

-អគ្គនាយដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ

-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី "ដើម្បីជ្រាបជាព័ត៌មាន"

-គ្រប់អង្គភាពក្រោមឱវាទក្រសួងអយក ដែលមានការពាក់ព័ន្ធ "ដើម្បីជ្រាបជាព័ត៌មាន"

-សាមីខ្លួន "ដើម្បីអនុវត្ត"

-កាលប្បវត្តិ -ឯកសារ រដអ

# ឧបសម្ព័ន្ធទី៣ លិខិតអនុញ្ញាតរបស់ក្រសួង

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
លេខ: ៤០៨២ អយក.វិសអ

ថ្ងៃ ច័ន្ទ ៨រោច ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៣

**ជម្រាបជូន**

- **ឯកឧត្តម លោកជំទាវ លោក លោកស្រី ប្រធានអង្គភាពក្រោមឱវាទទីស្តីការក្រសួងអប់រំ យុវជន និងកីឡា**
- **លោក លោកស្រីប្រធានមន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត**

កម្មវត្ថុ៖ ការចុះប្រមូលទិន្នន័យ ដើម្បីសរសេរនិក្ខេបបទបញ្ចប់ការសិក្សារបស់និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០។

យោង៖ ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០ ឆ្នាំសិក្សា២០២២-២០២៣ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាប **ឯកឧត្តម លោកជំទាវ លោក លោកស្រី** ថា៖ និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០ នៃវិទ្យាស្ថានជាតិអប់រំ ចំនួន ៤៣នាក់ ស្រី ១០នាក់ ត្រូវបានអនុញ្ញាតឱ្យចុះប្រមូលទិន្នន័យនៅតាមបណ្តាអង្គភាពមួយចំនួន ក្រោមឱវាទទីស្តីក្រសួងអប់រំ យុវជន និងកីឡា និងមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ដើម្បីសរសេរនិក្ខេបបទស្រាវជ្រាវបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ **ចាប់ពីថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២៣។**

អាស្រ័យហេតុនេះ សូម **ឯកឧត្តម លោកជំទាវ** លោក លោកស្រី ផ្តល់កិច្ចសហការដល់ការចុះប្រមូលទិន្នន័យខាងលើឱ្យមានប្រសិទ្ធភាពខ្ពស់។

សូម **ឯកឧត្តម លោកជំទាវ** លោក លោកស្រី ទទួលនូវគោរពរាប់អានដ៏ស្មោះពីខ្ញុំ។

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**ចម្លងជូន៖**
- អង្គភាពពាក់ព័ន្ធនានាក្រោមឱវាទក្រសួង អ.យ.ក "ដើម្បីជ្រាបព័ត៌មាន និងសហការ"
- សាមីខ្លួន "ដើម្បីអនុវត្ត"
- កាលប្បវត្តិ
- ឯកសារ៖ វិទ្យាស្ថានជាតិអប់រំ

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

# ឧបសម្ព័ន្ធទី៤ កម្រងសំណួរ

**កម្រងសំណួរសម្រាប់ការស្រាវជ្រាវ**

**ប្រធានបទ**

**ឧត្តមានុវត្តនៃការដឹកនាំនិងគ្រប់គ្រងរបស់នាយកសាលាវេស្ទើនអន្តរជាតិ " ករណីសិក្សាៈ សាលាវេស្ទើនអន្តរជាតិសាខា ស្ទឹងមានជ័យ"**

## សូមគោរពជូន

## លោកនាយកសាលាវេស្ទើនអន្តរជាតិសាខា ស្ទឹងមានជ័យ

ខ្ញុំបាទឈ្មោះ **ឌី ភារុន** ជានិស្សិតស្រាវជ្រាវថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៃវិទ្យាស្ថានជាតិអប់រំបានកំពុងសរសេរនិក្ខេបទបញ្ចប់ការសិក្សាក្រោមប្រធានបទ **ឧត្តមានុវត្តនៃការដឹកនាំនិងគ្រប់គ្រងរបស់នាយកសាលាវេស្ទើនអន្តរជាតិ " ករណីសិក្សាៈ សាលាវេស្ទើនអន្តរជាតិសាខា ស្ទឹងមានជ័យ"** ដែលដឹកនាំដោយ **ឯកឧត្តមបណ្ឌិត សៀង សុវណ្ណា** និងគ្រូដឹកនាំរង **លោកគ្រូ ម៉ៅ សារឿន** ក្នុងការណែនាំនិងកែលម្អលើកម្រងសំណួរស្រាវជ្រាវនេះ។

ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះកិច្ចសហការរបស់លោកនាយកក្នុងការបំពេញកម្រងសំណួរទាំងនេះ បើទោះបីជាមានការមមារញឹកក្នុងការងារក៏ដោយ។ កម្រងចម្លើយរបស់លោកនាយកនឹងត្រូវរក្សាការសម្ងាត់ និងយកមកប្រើសម្រាប់តែការស្រាវជ្រាវនេះតែប៉ុណ្ណោះ។

**សេចក្ដីណែនាំ**

កម្រងសំណួរស្រាវជ្រាវនេះគឺនិងសួរអំពីទស្សនៈរបស់នាយកទាក់ទងនឹងការអនុវត្តដែលជាបទពិសោធន៍ដ៏ប្រសើរកន្លងមក ព្រមទាំងការដឹកនាំនិងគ្រប់គ្រងបុគ្គលិកនៅសាលាវេស្ទើនអន្តរជាតិសាខា ស្ទឹងមានជ័យ

សូមមេត្តាជួយឆ្លើយឱ្យបានគ្រប់សំណួរតាមការពិតជាក់ស្ដែងមុននឹងប្រគល់ជូនអ្នកស្រាវជ្រាវវិញដោយមិនបាច់បញ្ជាក់ឈ្មោះ និងត្រកូលឡើយ។ អ្នកស្រាវជ្រាវសូមធានាអះអាងថា ចម្លើយរបស់លោកនាយក នឹងត្រូវរក្សាការសម្ងាត់បំផុត ពុំមានប៉ះពាល់ដល់សាលាឡើយ។

**កម្រងសំណួរស្រាវជ្រាវនេះចែកជាពីរផ្នែក គឺៈ**

- ផ្នែកទី១ៈ **ព័ត៌មានអំពីស្ថានភាពទូទៅរបស់លោក/លោកស្រីនាយក/នាយិកាសាលារៀន**
- ផ្នែកទី២ៈ **សំណួរទាក់ទងនឹងឧត្តមានុវត្តនៃការដឹកនាំនិងគ្រប់គ្រងរបស់នាយកសាលាវេស្ទើនអន្តរជាតិ**

សេចក្ដីណែនាំៈ សូមបំពេញចម្លើយ ឬគូសសញ្ញា (✓) ក្នុងប្រអប់ ☐ ដែលត្រូវនឹងស្ថានភាពទូទៅរបស់អ្នក (**សូមគូសចម្លើយដែលត្រូវ**)

**ផ្នែកទី១ៈ** ព័ត៌មានអំពីស្ថានភាពទូទៅរបស់នាយក/នាយិកា

សាលាវេស្ទើនអន្តរជាតិសាខា..........................

☐ ជានាយក

☐ នាយករង

១. ភេទ

☐ ប្រុស

☐ ស្រី

២. កម្រិតវប្បធម៌

☐ មធ្យមសិក្សាទុតិយភូមិ

☐ បរិញ្ញាបត្រ

☐ បរិញ្ញាបត្រជាន់ខ្ពស់

☐ បណ្ឌិត

៣.បទពិសោធន៍បម្រើការងារជានាយក/នាយិកាសាលារៀន

☐ ពី១ឆ្នាំ ដល់៣ឆ្នាំ

☐ ពី៤ឆ្នាំ ដល់៦ឆ្នាំ

☐ ពី៧ឆ្នាំ ដល់៩ឆ្នាំ

☐ លើសពី៩ឆ្នាំ

## ផ្នែកទី២៖ ស្តង់ដាសាលារៀនគំរូ

| ស្តង់ដាទី១ សាលារៀនមានដំណើរការសម្រេចផលសម្រេចនៃការអប់រំ និងការសិក្សារបស់សិស្ស | | | | | |
|---|---|---|---|---|---|
| ១ | តើនៅសាលារៀនរបស់លោក/លោកស្រីនាយក/នាយិកាមាន សិស្ស ចុះឈ្មោះចូលរៀនជាក់ស្តែងបានប៉ុន្មានភាគរយ ធៀបនឹងចំនួនសិស្សក្នុងផែនការ? | >90% | >95% | >97% | >99% |
| ២ | តើនៅសាលារៀនរបស់លោក/លោកស្រីនាយក/នាយិកាមាន សិស្សបោះបង់ការសិក្សាសរុបចុងឆ្នាំសិក្សា ប៉ុន្មានភាគរយ? | >3% | 3-2% | 2-1% | <1% |
| ៣ | តើនៅសាលារៀនរបស់លោក/លោកស្រីនាយក/នាយិកា មាន សិស្សបានឡើងថ្នាក់ប៉ុន្មានភាគរយ? | ≥95% | ≥96% | ≤98% | >98% |
| ៤ | ចំនួននិងភាគរយសិស្សមាននិទ្ទេស A និង B លើមុខវិជ្ជាភាសាខ្មែរ | ≤19% | 20%-29% | 30%-39% | 40%-50% (20/30) |
| ៥ | ចំនួននិងភាគរយសិស្សមាននិទ្ទេស A និង B លើមុខវិជ្ជាគណិតវិទ្យា | ≤19% | 20%-29% | 30%-39% | 40%-50% (20/30) |
| ៦ | ចំនួននិងភាគរយសិស្សមាននិទ្ទេសមធ្យមឡើងលើមុខវិជ្ជារូបវិទ្យា (A, B, C) | ≤19% | 20%-39% | 40%-59% | 60%-80% (20/30/30) |
| ៧ | ចំនួននិងភាគរយសិស្សមាននិទ្ទេសមធ្យមឡើងលើមុខវិជ្ជាគីមីវិទ្យា (A, B, C) | ≤19% | 20%-39% | 40%-59% | 60%-80% (20/30/30) |
| ៨ | ចំនួនភាគរយសិស្សមាននិទ្ទេសមធ្យមឡើងលើមុខវិជ្ជាជីវវិទ្យា (A, B, C) | ≤19% | 20%-39% | 40%-59% | 60%-80% (20/30/30) |
| ៩ | ចំនួននិងភាគរយសិស្សមាននិទ្ទេសមធ្យមឡើងលើមុខវិជ្ជាប្រវត្តិវិទ្យា (A, B, C) | ≤19% | 20%-39% | 40%-59% | 60%-80% (20/30/30) |
| ១០ | ចំនួននិងភាគរយសិស្សថ្នាក់ទី៧/១០ មាន  សមត្ថភាពអានតាមស្តង់ដា(១០០ទៅ១២០ពាក្យ/២៥០ទៅ២៧០ពាក្យក្នុងមួយនាទី) | ≥45% | ≥60% | ≥75% | ≥80% |
| ១១ | ចំនួននិងភាគរយសិស្សថ្នាក់ជាតិទី៩/១២ មានសមត្ថភាពអានតាមស្តង់ដា(៣០០ទៅ៣៥០ពាក្យក្នុងមួយនាទី) | ≥45% | ≥60% | ≥75% | ≥80% |
| ១២ | ចំនួននិងភាគរយសិស្សប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ (ថ្នាក់ជាតិ) | ≥60% | ≥70% | ≥80% | ≥90% |
| ស្តង់ដាទី២ ថ្នាក់រៀនដំណើរការសម្រាប់ការបង្រៀន និងការសិក្សារៀនសូត្ររបស់សិស្សម្នាក់ៗ | | | | | |

| | | | | | |
|---|---|---|---|---|---|
| ១៣ | តើនៅសាលារៀនរបស់លោក/លោកស្រីនាយក/នាយិកា ថ្នាក់រៀនប៉ុន្មានភាគរយដែលមានផែនការបង្រៀន៣ឆ្នាំនិងប្រចាំឆ្នាំតាមមុខវិជ្ជា? | ≥85% | ≥90 | ≥95 | 100% |
| ១៤ | តើនៅសាលារៀនរបស់លោក/លោកស្រីនាយក/នាយិកា ថ្នាក់រៀនប៉ុន្មានភាគរយ ដែលមានផែនការបង្រៀនប្រចាំឆ្នាំតាមមុខវិជ្ជា? | ≥85% | ≥90 | ≥95 | 100% |
| ១៥ | តើនៅសាលារៀនរបស់លោក/លោកស្រីនាយក/នាយិកា មុខវិជ្ជាមានបំណែងចែកកម្មវិធីសិក្សាបង្រៀនប្រចាំសប្តាហ៍ និងកាលវិភាគបង្រៀនលម្អិតតាមមេរៀនមានចំនួនប៉ុន្មានមុខវិជ្ជា? | 6 | 7-8 | 9-10 | 11-12 |
| ១៦ | តើនៅសាលារៀនរបស់លោក/លោកស្រីនាយក/នាយិកា ពីថ្នាក់ទី៧/១០ ដល់១២ មានប្លង់មេរៀនតាមគ្រប់មេរៀន ចំនួនប៉ុន្មានមុខវិជ្ជា? | 6 | 7-8 | 9-10 | 11-12 |
| ១៧ | តើនៅសាលារៀនរបស់លោក/លោកស្រីនាយក/នាយិកា ថ្នាក់រៀនដែលមានផែនការបង្រៀន៣ខែ មានប៉ុន្មានភាគរយ? | ≥85% | ≥90% | ≥95% | 100% |
| ១៨ | តើនៅសាលារៀនរបស់លោក/លោកស្រីនាយក/នាយិកា បានអនុវត្តម៉ោងសិក្សាសរុបប្រចាំឆ្នាំបានប៉ុន្មានភាគរយ ធៀបនឹងចំនួនម៉ោងកំណត់? | ≥85% | ≥90% | ≥95% | 100% |
| ១៩ | តើនៅសាលារៀនរបស់លោក/លោកស្រីនាយក/នាយិកា ថ្នាក់រៀនប៉ុន្មានភាគរយ ដែលបានប្រជុំពិនិត្យតាមដានការរៀនសូត្រទៀងទាត់? | ≥85% | ≥90% | ≥95% | 100% |
| ២០ | តើនៅសាលារៀនរបស់លោក/លោកស្រីនាយក/នាយិកា សិស្សប៉ុន្មានភាគរយ ដែលបានរៀបចំ និងអនុវត្តតាមផែនការសិក្សាប្រចាំឆ្នាំសិក្សា? | ≥85% | ≥90% | ≥95% | 100% |
| ២១ | តើនៅសាលារៀនរបស់លោក/លោកស្រីនាយក/នាយិកា សិស្សប៉ុន្មានភាគរយ បានចូលរួមសកម្មភាពមគ្គុទេសន៍អាជីព និងការផ្តល់ប្រឹក្សា? | ≥50% | ≥60% | ≥70% | ≥80% |
| ២២ | តើនៅសាលារៀនរបស់លោក/លោកស្រីនាយក/នាយិកា សិស្សប៉ុន្មានភាគរយ ដែលបានធ្វើកិច្ចការគម្រោងទាំងអស់ និងក្លឹបសិក្សា( ៨ក្លឹបសិក្សា )? | ≥85% | ≥90% | ≥95% | 100% |
| ២៣ | តើនៅសាលារៀនរបស់លោក/លោកស្រីនាយក/នាយិកា បើកដំណើរការបន្ទប់កុំព្យូទ័រ បានប៉ុន្មានភាគរយ ធៀបនឹងផែនការ? | ≥85% | ≥90% | ≥95% | 100% |

| | | | | | |
|---|---|---|---|---|---|
| ២៤ | តើនៅសាលារៀនរបស់លោក/លោកស្រីនាយក/នាយិកា បើកដំណើរការបន្ទប់ពិសោធន៍វិទ្យាសាស្ត្រទាំង៤ បានប៉ុន្មានភាគរយធៀបនឹងផែនការ ? | ≥85% | ≥90% | ≥95% | 100% |
| ២៥ | តើនៅសាលារៀនរបស់លោក/លោកស្រីនាយក/នាយិកា ដំណើរការ និងអភិវឌ្ឍបណ្ណាល័យ ទៀងទាត់កម្រិតណា ? | សប្តាហ៍ទៀងទាត់ | ខែទៀងទាត់ | ត្រីមាសទៀងទាត់ | ឆ្នាំទៀងទាត់ |
| ២៦ | តើនៅសាលារៀនរបស់លោក/លោកស្រីនាយក/នាយិកា ដំណើរការ គាំទ្រ និងអភិវឌ្ឍបន្ទប់ពហុបំណង ទៀងទាត់កម្រិតណា ? | សប្តាហ៍ទៀងទាត់ | ខែទៀងទាត់ | ត្រីមាសទៀងទាត់ | ឆ្នាំទៀងទាត់ |
| ២៧ | តើនៅសាលារៀនរបស់លោក/លោកស្រីនាយក/នាយិកា រៀបចំឱ្យសិស្សប្រកួតប្រជែងអានអក្សរ ប៉ុន្មានដង ? | ≤6 | 6-7 | 8-9 | 10 |
| ២៨ | តើនៅសាលារៀនរបស់លោក/លោកស្រីនាយក/នាយិកា រៀបចំឱ្យសិស្សប្រកួតប្រជែងធ្វើលំហាត់គណិតវិទ្យា ប៉ុន្មានដង ? | ≤6 | 6-7 | 8-9 | 10 |
| ២៩ | តើនៅសាលារៀនរបស់លោក/លោកស្រីនាយក/នាយិកា សិស្សប៉ុន្មានភាគរយ ដែលអវត្តមានលើសពី៤ដង ? | 2% | 1.5% | 1.0% | 0.5% |
| ៣០ | តើនៅសាលារៀនរបស់លោក/លោកស្រីនាយក/នាយិកា គ្រូអវត្តមានប៉ុន្មានដង ដោយមិនមានគ្រូជំនួស ? | ≤20 | ≤15 | ≤10 | ≤5 |
| ៣១ | តើនៅសាលារៀនរបស់លោក/លោកស្រីនាយក/នាយិកា បិទទ្វារខុសពីប្រតិទិនឈប់សម្រាកប្រចាំឆ្នាំរបស់រាជរដ្ឋាភិបាល ចំនួនប៉ុន្មានថ្ងៃ ? | 5 | 3-4 | 2 | 1 |
| **ស្តង់ដាទី៣ ភាពជាម្ចាស់នៃសហគមន៍សាលារៀន** | | | | | |
| ៣២ | តើនៅសាលារៀនរបស់លោក/លោកស្រីនាយក/នាយិកា គ្រួសារប៉ុន្មានភាគរយ ដែលមានហិង្សា ? | ≤1.5% | ≤1.0% | ≤0.5% | 0% |
| ៣៣ | តើនៅសាលារៀនរបស់លោក/លោកស្រីនាយក/នាយិកា សមាសភាពគណៈកម្មការគ្រប់គ្រងសាលារៀន( គ.គ.ស ) ឬក្រុមប្រឹក្សាសាលា( ក.ប.ស ) មានចំនួនប៉ុន្មាននាក់ ? | <7 | 7-8 | 9-10 | >10 |
| ៣៤ | តើនៅសាលារៀនរបស់លោក/លោកស្រីនាយក/នាយិកា គណៈកម្មការគ្រប់គ្រងសាលារៀន ឬក្រុមប្រឹក្សាសាលា ដឹកនាំប្រជុំប្រចាំត្រីមាស ឆមាស និងឆ្នាំ ទៀងទាត់កម្រិតណា ? | ត្រីមាសម្តងម្កាល | ត្រីមាសទៀងទាត់ | ប្រចាំឆ្នាំទៀងទាត់ | ទាំងអស់ |
| ៣៥ | តើនៅសាលារៀនរបស់លោក/លោកស្រីនាយក/នាយិកា គ្រូបង្រៀនប៉ុន្មានភាគរយ ទទួលបានការសម្រេចចិត្តពីគណៈកម្ម | ≥80% | ≥85% | ≥90% | ≥95% |

| | | | | | |
|---|---|---|---|---|---|
| | ការគ្រប់គ្រងសាលារៀន ឬក្រុមប្រឹក្សាសាលា លើការវាយតម្លៃការអនុវត្តការងារប្រចាំឆ្នាំ ? | | | | |
| ៣៦ | តើនៅសាលារៀនរបស់លោក/លោកស្រីនាយក/នាយិកា នាយក និងនាយករង ប៉ុន្មាននាក់ បានទទួលការសម្រេចចិត្តពីគណៈកម្មការគ្រប់គ្រងសាលារៀន ឬក្រុមប្រឹក្សាសាលា លើការវាយតម្លៃការអនុវត្តការងារប្រចាំឆ្នាំ ? | 0 | 1 | 2-3 | ទាំងអស់ |
| ៣៧ | តើនៅសាលារៀនរបស់លោក/លោកស្រីនាយក/នាយិកា សិស្សអវត្តមាន ធ្លាក់មធ្យមភាគ ត្រៀមបោះបង់ ឬបោះបង់ការសិក្សាប៉ុន្មានភាគរយ បានមករៀនទៀងទាត់វិញ ? | >90% | >94% | >99% | 100% |
| ៣៨ | តើនៅសាលារៀនរបស់លោក/លោកស្រីនាយក/នាយិកា ផែនការវង្វាយតម្លៃស្តង់ដាលើសមត្ថភាពសិស្សបានអនុម័ត និងបិទផ្សាយ ទៀងទាត់កម្រិតណា ? | តេស្តខែ | បូកឆមាសទី១ | បូកឆមាសទី២ | ទាំងអស់ |
| ៣៩ | តើនៅសាលារៀនរបស់លោក/លោកស្រីនាយក/នាយិកា ផែនការសកម្មភាពអនុវត្តសូចនាករគន្លឹះអនុម័តដោយគណៈគ្រប់គ្រងសាលារៀន ឬក្រុមប្រឹក្សាសាលា បានកម្រិតណា ? | ផលិត | អនុម័តឆ្នាំទី១ | អនុម័តឆ្នាំទី២ | អនុម័តឆ្នាំទី៣ |
| ៤០ | តើនៅសាលារៀនរបស់លោក/លោកស្រីនាយក/នាយិកា ផែនការកែលម្អសាលារៀន និងថវិកាប្រចាំឆ្នាំ អនុម័តដោយគណៈគ្រប់គ្រងសាលារៀន ឬក្រុមប្រឹក្សាសាលា បានកម្រិតណា ? | ផលិត | អនុម័តឆ្នាំទី១ | អនុម័តឆ្នាំទី២ | អនុម័តឆ្នាំទី៣ |
| ៤១ | តើនៅសាលារៀនរបស់លោក/លោកស្រីនាយក/នាយិកា របាយការណ៍វាយតម្លៃស្តង់ដាសាលារៀន អនុម័តដោយគណៈគ្រប់គ្រងសាលារៀន ឬក្រុមប្រឹក្សាសាលា បានកម្រិតណា ? | ផលិត | អនុម័តឆ្នាំទី១ | អនុម័តឆ្នាំទី២ | អនុម័តឆ្នាំទី៣ |
| ៤២ | តើនៅសាលារៀនរបស់លោក/លោកស្រីនាយក/នាយិកា របាយការណ៍ប្រចាំឆ្នាំ អនុម័តដោយគណៈគ្រប់គ្រងសាលារៀន ឬក្រុមប្រឹក្សាសាលា បានកម្រិតណា ? | ផលិត | អនុម័តឆ្នាំទី១ | អនុម័តឆ្នាំទី២ | អនុម័តឆ្នាំទី៣ |
| ៤៣ | តើនៅសាលារៀនរបស់លោក/លោកស្រីនាយក/នាយិកា ទិន្នន័យបិទផ្សាយជាសាធារណៈ  អនុម័តដោយគណៈគ្រប់គ្រងសាលារៀន ឬក្រុមប្រឹក្សាសាលា បានកម្រិតណា ? | ផលិត | អនុម័តឆ្នាំទី១ | អនុម័តឆ្នាំទី២ | អនុម័តឆ្នាំទី៣ |
| ៤៤ | តើនៅសាលារៀនរបស់លោក/លោកស្រីនាយក/នាយិកា បរិស្ថានបៃតង អនាម័យ អគារសិក្សា បន្ទប់រៀន សង្ហារឹម និងបរិក្ខាសិក្សា បានថែរក្សា និងពង្រីកបន្ថែម តាមបែបបច្ចេកវិទ្យា បានកម្រិតណា ? | គ្រោង | តាមផែនការឆ្នាំទី១ | តាមផែនការឆ្នាំទី២ | តាមផែនការឆ្នាំទី៣ |

| | | | | | |
|---|---|---|---|---|---|
| ៤៥ | តើនៅសាលារៀនរបស់លោក/លោកស្រីនាយក/នាយិកា កម្មវិធីមគ្គុទេសក៍អាជីព និងការផ្តល់ប្រឹក្សាអនុវត្តតាមផែនការបានត្រឹមត្រូវ កម្រិតណា? | ខែ ទៀតទាត់ | ត្រីមាស ទៀតទាត់ | ឆ្នាំ ទៀតទាត់ | ទាំងអស់ |
| **ស្តង់ដាទី៤ ដំណើរការប្រតិបត្តិការ និងរដ្ឋបាលសាលារៀន** | | | | | |
| ៤៦ | តើនៅសាលារៀនរបស់លោក/លោកស្រីនាយក/នាយិកា ធ្វើផែនការសមិទ្ធកម្មអនុវត្តសូចនាករគន្លឹះរយៈពេលមធ្យម បានរៀបចំតាមការណែនាំ បានកម្រិតណា? | រៀបចំ ឆ្នាំទី១ | រៀបចំ ឆ្នាំទី២ | រៀបចំ ឆ្នាំទី៣ | រៀបចំ ឆ្នាំទី៤ |
| ៤៧ | តើនៅសាលារៀនរបស់លោក/លោកស្រីនាយក/នាយិកា ផលសម្រេចរយៈពេល ៣ឆ្នាំ និងផែនការបង្រៀនរយៈពេល៣ឆ្នាំ បានរៀបចំតាមការណែនាំ បានកម្រិតណា? | រៀបចំ ឆ្នាំទី១ | រៀបចំ ឆ្នាំទី២ | រៀបចំ ឆ្នាំទី៣ | រៀបចំ ឆ្នាំទី៤ |
| ៤៨ | តើនៅសាលារៀនរបស់លោក/លោកស្រីនាយក/នាយិកា ផែនការកែលម្អសាលារៀន បានរៀបចំតាមការណែនាំ បានកម្រិតណា? | រៀបចំ ឆ្នាំទី១ | រៀបចំ ឆ្នាំទី២ | រៀបចំ ឆ្នាំទី៣ | រៀបចំ ឆ្នាំទី៤ |
| ៤៩ | តើនៅសាលារៀនរបស់លោក/លោកស្រីនាយក/នាយិកា ការធ្វើតេស្តង់ដាប្រចាំខែ និងត្រីមាស បានទៀងទាត់កម្រិតណា? | តេស្តខែ | ឆមាសទី ១ | ប្រចាំឆ្នាំ | ទាំងអស់ |
| ៥០ | តើនៅសាលារៀនរបស់លោក/លោកស្រីនាយក/នាយិកា លទ្ធផលតេស្តង់ដាប្រចាំខែ បានប្រើប្រាស់ជួយដល់ការសិក្សារបស់សិស្សរៀនយឺត បានទៀងទាត់កម្រិតណា? | ទៀង ទាត់ឆ្នាំ ទី១ | ទៀងទាត់ ឆ្នាំទី២ | ទៀងទាត់ ឆ្នាំទី៣ | ទៀងទាត់ ឆ្នាំទី៤ |
| ៥១ | តើនៅសាលារៀនរបស់លោក/លោកស្រីនាយក/នាយិកា លទ្ធផលតេស្តង់ដាចុងត្រីមាស បានប្រើប្រាស់ក្នុងការរៀបចំផែនការបង្រៀន៣ខែតាមថ្នាក់រៀន បានទៀងទាត់កម្រិតណា? | ទៀង ទាត់ឆ្នាំ ទី១ | ទៀងទាត់ ឆ្នាំទី២ | ទៀងទាត់ ឆ្នាំទី៣ | ទៀងទាត់ ឆ្នាំទី៤ |
| ៥២ | តើនៅសាលារៀនរបស់លោក/លោកស្រីនាយក/នាយិកា ការប្រជុំប្រចាំខែ ត្រីមាស និងឆមាស បានប្រជុំតាមការណែនាំ កម្រិតណា? | ប្រចាំខែ | បូកត្រីមាស | បូក ឆមាសទី ១ | បូកឆមាស ទី២ |
| ៥៣ | តើនៅសាលារៀនរបស់លោក/លោកស្រីនាយក/នាយិកា បានធ្វើអធិការកិច្ចផ្ទៃក្នុងចំនួនប៉ុន្មានដង? | 7-7 | 8-8 | 9-9 | 10-11 |
| ៥៤ | តើនៅសាលារៀនរបស់លោក/លោកស្រីនាយក/នាយិកា ការប្រជុំបច្ចេកទេសបានអនុវត្តតាមផែនការ បានប៉ុន្មានដង? | 7-7 | 8-8 | 9-9 | 10-11 |
| ៥៥ | តើនៅសាលារៀនរបស់លោក/លោកស្រីនាយក/នាយិកា ប្រើប្រាស់ និងដំណើរការអគារធនធានតាមផែនការ បានប៉ុន្មានភាគរយ? | >80% | >85% | >90% | >95% |

| | | | | | |
|---|---|---|---|---|---|
| ៥៦ | តើនៅសាលារៀនរបស់លោក/លោកស្រីនាយក/នាយិកា គ្រូបង្រៀនប៉ុន្មាននាក់ បានចូលរៀនវគ្គអភិវឌ្ឍសមត្ថភាពជាប្រចាំ? | គ្រោង | តាមគ្រោងឆ្នាំទី១ | តាមគ្រោងឆ្នាំទី២ | តាមគ្រោងឆ្នាំទី៣ |
| ៥៧ | តើនៅសាលារៀនរបស់លោក/លោកស្រីនាយក/នាយិកា គ្រូបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រទាំង៤ និងបរិវិច្ឆការី ប៉ុន្មានភាគរយ ទទួលបានការបណ្តុះបណ្តាលការប្រើប្រាស់បន្ទប់ពិសោធន៍ និងសៀវភៅណែនាំពិសោធន៍? | >80% | >85% | >90% | ≥95% |
| ៥៨ | តើនៅសាលារៀនរបស់លោក/លោកស្រីនាយក/នាយិកា គ្រូបង្រៀនប៉ុន្មានភាគរយ បានចូលរួមអនុវត្តប្រព័ន្ធគ្រប់គ្រងការអនុវត្តការងាររបស់គ្រូបង្រៀន? | >80% | >85% | >90% | ≥95% |
| ៥៩ | តើនៅសាលារៀនរបស់លោក/លោកស្រីនាយក/នាយិកា នាយក និងនាយករង ប៉ុន្មាននាក់ បានចូលរួមអនុវត្តប្រព័ន្ធគ្រប់គ្រងការអនុវត្តការងាររបស់នាយកសាលា? | 0 | 1 | 2-3 | ទាំងអស់ |
| ៦០ | តើនៅសាលារៀនរបស់លោក/លោកស្រីនាយក/នាយិកា បានអនុវត្តស្វ័យវាយតម្លៃសាលារៀន និងរៀបចំរបាយការណ៍ហិរញ្ញវត្ថុតាមការណែនាំ បានកម្រិតណា? | អនុវត្តឆ្នាំទី១ | អនុវត្តឆ្នាំទី២ | អនុវត្តឆ្នាំទី៣ | អនុវត្តឆ្នាំទី៤ |
| ៦១ | តើនៅសាលារៀនរបស់លោក/លោកស្រីនាយក/នាយិកា ទិន្នន័យជឿជាក់ បានផលិត ប្រើប្រាស់ និងបិទផ្សាយសាធារណៈតាមការណែនាំ កម្រិតណា? | ចងក្រងទិន្នន័យ | អនុវត្តឆ្នាំទី១ | អនុវត្តឆ្នាំទី២ | អនុវត្តឆ្នាំទី៣ |
| ៦២ | តើនៅសាលារៀនរបស់លោក/លោកស្រីនាយក/នាយិកា កម្មវិធីអប់រំមាតាបិតា និងគ្រូបង្រៀន ទប់ស្កាត់អំពើហិង្សានៅផ្ទះ និងសាលារៀន បានរៀបចំតាមការណែនាំកម្រិតណា? | ប្រមូលទិន្នន័យ | អនុវត្តឆ្នាំទី១ | អនុវត្តឆ្នាំទី២ | អនុវត្តឆ្នាំទី៣ |
| ៦៣ | តើនៅសាលារៀនរបស់លោក/លោកស្រីនាយក/នាយិកា ការពិនិត្យស្វែងរកសិស្សខ្សោយគំហើញ និងស្តាប់ បានអនុវត្តទៀងទាត់រាល់ដើមឆ្នាំសិក្សាកម្រិតណា? | គ្រោង | អនុវត្តឆ្នាំទី១ | អនុវត្តឆ្នាំទី២ | អនុវត្តឆ្នាំទី៣ |
| | **ស្តង់ដាទី៥ គណនេយ្យភាពថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិ** | | | | |
| ៦៤ | តើនៅសាលារៀនរបស់លោក/លោកស្រីនាយក/នាយិកា នាយក និងនាយករងសាលាទទួលការហ្វឹកហាត់អនុវត្តកម្មវិធីសាលារៀនគំរូ ប៉ុន្មានដង? | 1-2 | 3-4 | 5-6 | 7-8 |
| ៦៥ | តើនៅសាលារៀនរបស់លោក/លោកស្រីនាយក/នាយិកា គ្រូបង្រៀន បានទទួលការហ្វឹកហាត់ការបង្រៀនចម្រុះមុខវិជ្ជា (STEM)តាមផែនការ ប៉ុន្មានដង? | គ្រោង | តាមគ្រោងឆ្នាំទី១ | តាមគ្រោងឆ្នាំទី២ | តាមគ្រោងឆ្នាំទី៣ |

| | | | | | |
|---|---|---|---|---|---|
| ៦៦ | តើនៅសាលារៀនរបស់លោក/លោកស្រីនាយក/នាយិកា បានទទួលទស្សនកិច្ចផ្ដល់ការគាំទ្រពីក្រុមការងារថ្នាក់ជាតិ បានអនុវត្តតាមផែនការ ចំនួនប៉ុន្មានដង? | 1-2 | 3-4 | 5-6 | 7-8 |
| ៦៧ | តើនៅសាលារៀនរបស់លោក/លោកស្រីនាយក/នាយិកា បានទទួលទស្សនកិច្ចផ្ដល់ការគាំទ្រពីមន្ទីរ អ.យ.ក បានអនុវត្តតាមផែនការ ចំនួនប៉ុន្មានដង? | 1-2 | 3-4 | 5-6 | 7-8 |
| ៦៨ | តើនៅសាលារៀនរបស់លោក/លោកស្រីនាយក/នាយិកា បានទទួលទស្សនកិច្ចផ្ដល់ការគាំទ្រពីការិយាល័យ អ.យ.ក បានអនុវត្តតាមផែនការ ចំនួនប៉ុន្មានដង? | 1-2 | 3-4 | 5-6 | 7-8 |
| ៦៩ | តើនៅសាលារៀនរបស់លោក/លោកស្រីនាយក/នាយិកា ចំនួនគ្រូបង្រៀនខ្វះតាមមុខវិជ្ជាថយចុះតាមផែនការ ប៉ុន្មាននាក់? | ≥10 | 6-9 | 2-5 | 0 |
| ៧០ | តើនៅសាលារៀនរបស់លោក/លោកស្រីនាយក/នាយិកា ចំនួននាយក និងនាយករងសាលា ស្របតាមបទដ្ឋានឬទេ? | ខ្វះ ២ | ខ្វះ ១ | ស្របតាមបទដ្ឋាន | ស្របតាមបទដ្ឋាន |
| ៧១ | តើនៅសាលារៀនរបស់លោក/លោកស្រីនាយក/នាយិកា កាតរបាយការណ៍សាលារៀន បានផលិត និងបិទផ្សាយ កម្រិតណា? | គ្រោង | ផលិតនិងបិទផ្សាយឆ្នាំទី១ | ផលិតនិងបិទផ្សាយឆ្នាំទី២ | ផលិតនិងបិទផ្សាយឆ្នាំទី៣ |

៧២. តើនៅសាលារៀនស្នើនអន្តរជាតិមានផែនការយុទ្ធសាស្ត្រ៥ឆ្នាំនិងផែនការប្រត្តិបត្តិប្រចាំឆ្នាំដែរឬទេ?

……………………………………………………………………………………………………………

……………………………………………………………………………………………………………

……………………………………………………………………………………………………………

……………………………………………………………………………………………………………

៧៣. តើអ្នកណាខ្លះដែលចូលរួមធ្វើផែនការយុទ្ធសាស្ត្រ៥ឆ្នាំនិងផែនការប្រត្តិបត្តិប្រចាំឆ្នាំ?

……………………………………………………………………………………………………………

……………………………………………………………………………………………………………

……………………………………………………………………………………………………………

……………………………………………………………………………………………………………

៧៤. តើលោកនាយកប្រើប្រាស់វិធីសាស្ត្រអ្វីខ្លះក្នុងការគ្រប់គ្រងលោកគ្រូអ្នកគ្រូ?តើប្រើប្រព័ន្ធតាមដាន

យ៉ាងដូចម្ដេច?

………………………………………………………………………………………………

………………………………………………………………………………………………

………………………………………………………………………………………………

……………………………………………………………………………………………….

៧៥. តើលោកនាយកមានវិធីសាស្ត្រអ្វីខ្លះក្នុងការទាក់ទាញអ្នកអាណាព្យាបាលឱ្យបញ្ជូនកូនមកសាលា

វេស្ទើនអន្តរជាតិ?

………………………………………………………………………………………………

………………………………………………………………………………………………

………………………………………………………………………………………………

……………………………………………………………………………………………….

**ខ្ញុំសូមថ្លែងអំណរគុណចំពោះលោកនាយកដែលបានចំណាយពេលវេលាដ៏មានតម្លៃដើម្បីបំពេញកំរងសំនួរទាំងនេះ។ សូមជូនពរលោកនាយកឱ្យជួបប្រទះតែពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។ សូមអរគុណ!!!**